ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ការវាយតម្លៃទៅលើការបង្រៀនរបស់គ្រូ ស្តីពីអំណាន នៅកម្រិតបឋមសិក្សាក្នុងខេត្តព្រៃវែង

AN EVALUATION OF THE TEACHING OF READING COMPREHENSION KHMER LANGUAGE AT PRIMARY SCHOOL IN PREY VENG PROVINCE, CAMBODIA

**ចែម នី**

CHEM NY

**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧**

**ឯកទេសៈ គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា ២០១៨ - ២០២០**

ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ការវាយតម្លៃទៅលើការបង្រៀនរបស់គ្រូ ស្តីពីអំណាន នៅកម្រិតបឋមសិក្សាក្នុងខេត្តព្រៃវែង

# AN EVALUATION OF THE TEACHING OF READING COMPREHENSION KHMER LANGUAGE AT PRIMARY SCHOOL IN PREY VENG PROVINCE, CAMBODIA

ចែម នី

CHEM NY

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០១៨- ២០២០

គ្រូដឹកនាំបង្គោល៖ បណ្ឌិត ឈាង សទ្ធាត

គ្រូដឹកនាំរង៖ លោក ម៉ន មុនិន្ទ

# សេចក្តីអះអាងរបស់បេក្ខជន

ខ្ញុំបាទសូមបញ្ជាក់ថា និក្ខេបបទសិក្សាស្រាវជ្រាវស្តីពី «**ការវាយតម្លៃទៅលើការបង្រៀនរបស់គ្រូ ស្តីពីអំណាននៅកម្រិតបឋមសិក្សាក្នុងខេត្តព្រៃវែង**» សម្រាប់បំពេញលក្ខខណ្ឌក្នុងការបណ្តុះបណ្តាលបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ពិតជាស្នាដៃរបស់ខ្ញុំបាទពិតប្រាកដមែន។ ស្នាដៃនេះពុំទាន់បានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់ទទួលសញ្ញាបត្រនៅវិទ្យាស្ថាននេះ ឬសាកលវិទ្យាល័យណា ឬវិទ្យាស្ថានថ្នាក់ស្មើណាមួយនៅឡើយទេ។ ពុំមានសេចក្តីដកស្រង់ ឬខ្លឹមសារអ្វីមួយត្រូវបានប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះ ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ។ និក្ខេបបទសិក្សាស្រាវជ្រាវខាងលើនេះពិតជាត្រូវបាន ស្រាវជ្រាវនិងចងក្រងដោយខ្ញុំបាទពិតប្រាកដមែន។

ថ្ងៃ ខែ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២០

**ហត្ថលេខា**

**ចែម នី**

# **លិខិតបញ្ជាក់**

**បណ្ឌិត ឈាង សទ្ធាត** គ្រូដឹកនាំបង្គោល

**លោក ម៉ន មុនិន្ទ** គ្រូដឹកនាំរង

## **សូមបញ្ជាក់ និងទទួលស្គាល់ថា**

លោក **ចែម នី** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ ពិតជាបាន សរសេរនិក្ខេបបទស្រាវជ្រាវ «**ការវាយតម្លៃទៅលើការបង្រៀនរបស់គ្រូ ស្តីពីអំណាននៅកម្រិតបឋមសិក្សាក្នុងខេត្តព្រៃវែង**» ពិតប្រាកដមែន។

ថ្ងៃ ខែ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២០

....................................... .....................................

| | |
|---|---|
| **បណ្ឌិត ឈាង សទ្ធាត** | **លោក ម៉ន មុនិន្ទ** |
| គ្រូឧទ្ទេស | ប្រធានដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការ |
| វិទ្យាស្ថានជាតិអប់រំ | វិទ្យាស្ថានជាតិអប់រំ |

# លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខៈ** ៥៣៧៧ **អយក.**ខទ

(**ការសម្ងាត់**)

**លិខិតឧទ្ទេសនាម**

យោង ៖ -លិខិតលេខ២៩៥៥ អយក.វជអ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០។

-បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ និងទី៨ ឆ្នាំសិក្សា២០១៩-២០២០ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារសារណា** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២០ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-ឯ.ឧបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិត | ម៉ុក សារ៉ុម | អគ្គ.អប់រំ | អនុប្រធាន |
| ៣- ឯកឧត្តម | នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៤-លោក | ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-លោកបណ្ឌិត | នូវ វីរ៉ា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦-លោកស្រី | ប៊ុន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧-លោក | ថៃ ហេង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-លោកបណ្ឌិត | នី រដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៩-លោក | ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១០-លោក | ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១១-លោកបណ្ឌិត | ឈាង សង្ហាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២-លោកបណ្ឌិត | អាន រ៉ូប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោកស្រី | នូ ចន្នី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤-លោក | សៀង វាសនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារសារណា របស់និស្សិតពីថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២០ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ ចន្ទ ៣ កើត ខែ កត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ១០ ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

-អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"

-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"

-សាមីខ្លួន "ដើម្បីអនុវត្ត"

-កាលប្បវត្តិ -ឯកសារ វជអ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

# សេចក្តីថ្លែងអំណរគុណ

សូមថ្លែងអំណរគុណដល់ក្រសួងអប់រំ យុវជន និងកីឡា និងវិទ្យាស្ថានដែលផ្តល់កិច្ចគាំទ្រ និងឱកាសដល់រូបខ្ញុំបាទបានសិក្សាបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ នៅវិទ្យាស្ថានជាតិអប់រំ។

ខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះឯកឧត្តមបណ្ឌិត **សៀង សុវណ្ណា** នាយកវិទ្យាស្ថានជាតិអប់រំ លោក/លោកស្រីសាស្ត្រាចារ្យទាំងអស់ ដែលបានខិតខំចំណាយពេលវេលាដ៏មមាញឹក និងមានតម្លៃមកបង្ហាត់បង្រៀន ចែករំលែកបទពិសោធន៍ដល់រូបខ្ញុំ ក៏ដូចជាមិត្តភក្តិរួមជំនាន់ទាំងអស់គ្នា។ សូមថ្លែងអំណរគុណដល់លោក **ប៉ាវ សុធីរ** ប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្តព្រៃវែង លោកប្រធានការិយាល័យអប់រំស្រុក គណៈគ្រប់គ្រងសាលារៀន និងលោកគ្រូ-អ្នកគ្រូនៅសាលាបឋមសិក្សាទាំង៩ ដែលបានចូលរួមសហការក្នុងការប្រមូលទិន្នន័យតាមកម្រងសំណួរនៅខេត្តព្រៃវែង ធ្វើឱ្យការសិក្សាស្រាវជ្រាវសម្រេចបានលទ្ធផលល្អប្រសើរ និងទាន់ពេលវេលា។

ខ្ញុំបាទសូមគោរពថ្លែងអំណរគុណ ចំពោះលោកបណ្ឌិត **ឈាង សទ្ធាត** ដែលបានដឹកនាំក្នុងដំណើរការសរសេរនិក្ខេបបទ ពន្យល់ណែនាំលើខ្លឹមសាររួម បង្ហាញជាផែនទីគំនិត និងចំណេះដឹងល្អៗព្រមទាំងបទពិសោធន៍នានា ជំរុញដល់លទ្ធផលនៃការសរសេរនិក្ខេបបទរបស់ខ្ញុំទទួលបានជោគជ័យ និងជានាបាននូវគុណភាពនៃការបណ្តុះបណ្តាល។ ខ្ញុំបាទក៏សូមអរគុណដល់លោកសាស្ត្រាចារ្យ **ម៉ន មុនិន្ទ** ជាគ្រូដឹកនាំរង ដែលតែងតែផ្តល់កិច្ចគាំទ្រ ចំណេះដឹង និងចែករំលែកបទពិសោធន៍ជាច្រើន ដល់រូបខ្ញុំរហូតដល់សម្រេចបានជាលទ្ធផលល្អប្រសើរ។

ខ្ញុំបាទសូមថ្លែងនូវការដឹងគុណ និងសេចក្តីស្រឡាញ់អស់ពីបេះដូង ចំពោះក្រុមគ្រួសារ លោកពុក និងអ្នកម្តាយ ពូមីង បងប្អូន និងភរិយា ព្រមទាំងកូនៗ ដែលបានផ្តល់ការគាំទ្រជានិច្ច តែងតែលើកទឹកចិត្តរហូតមក និងផ្តល់ឱកាសឱ្យរូបខ្ញុំបានបន្តការសិក្សារហូតដល់ចប់សព្វគ្រប់ តាមក្តីប្រាថ្នា។

សូមអរគុណ!

# មាតិកា

សេចក្តីអះអាងរបស់បេក្ខជន ........ i

លិខិតបញ្ជាក់ ........ ii

លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ ........ iii

សេចក្តីថ្លែងអំណរគុណ ........ iv

មាតិកា ........ v

បញ្ជីតារាង ........ ix

បញ្ជីអក្សរកាត់ ........ x

មូលន័យសង្ខេប ........ xi

Abstract ........ xiii

ជំពូកទី១ សេចក្តីផ្តើម ........ 1

១.១ លំនាំបញ្ហានៃការសិក្សាស្រាវជ្រាវ ........ 1

១.២ ចំណោទបញ្ហានៃការសិក្សាស្រាវជ្រាវ ........ 3

១.៣ គោលបំណងនៃការស្រាវជ្រាវ ........ 5

១.៤ សំណួរស្រាវជ្រាវ ........ 6

១.៥ សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ ........ 6

១.៦ វិសាលភាព និងដែនកំណត់នៃការសិក្សាស្រាវជ្រាវ ........ 6

១.៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ 7

ជំពូកទី២ រំឭកទ្រឹស្តី ........ 8

២.១ ព័ត៌មានពីការអប់រំនៅខេត្តព្រៃវែង ........ 8

**២.២ និយមន័យ** ........................................ 8
២.២.១. អំណាន ........................................ 8
២.២.២. ការវាយតម្លៃ ........................................ 9
**២.៣ ការវាយតម្លៃទៅលើការបង្រៀនរបស់គ្រូ** ........................................ 10
**២.៤ ទ្រឹស្តីពីការបង្រៀនអំណាន** ........................................ 13
**២.៥ ទ្រឹស្តីពីបញ្ហាប្រឈម លើការបង្រៀនអំណាន** ........................................ 15
**២.៦ តួនាទីរបស់គ្រូបង្រៀនក្នុងសតវត្សទី២១** ........................................ 16
**២.៧ កម្មវិធីសិក្សានៅកម្រិតបឋមសិក្សា** ........................................ 18
**២.៨ ម៉ោងសិក្សាលម្អិតលើមុខវិជ្ជាភាសាខ្មែរ** ........................................ 19
**២.៩ ស្តង់ដារបង្រៀនអំណាន** ........................................ 20
**២.១០ គន្លងអាជីពគ្រូបង្រៀន** ........................................ 21
**២.១១ គន្លឹះសំខាន់ៗ ក្នុងការបណ្តុះទម្លាប់អាន** ........................................ 22
**ជំពូកទី៣ វិធីសាស្ត្រស្រាវជ្រាវ** ........................................ 24
**៣.១ គម្រោងវិភាគ** ........................................ 24
**៣.២ ការប្រមូលទិន្នន័យ** ........................................ 24
**៣.៣ ឧបករណ៍ស្រាវជ្រាវ** ........................................ 25
៣.៣.១ កម្រិតចង្អុលបង្ហាញ ........................................ 26
៣.៣.២ កម្រងសំណួរ ........................................ 27
**៣.៤ ការជ្រើសរើសភាគសំណាក** ........................................ 29

**៣.៥ ការវិភាគទិន្នន័យ** ........ 30

**ជំពូកទី៤ លទ្ធផល និងការពិភាក្សា** ........ 31

**៤.១.ការវិភាគទិន្នន័យលើកម្រងសំណួរទី១ពីគ្រូបង្រៀន និងគណៈគ្រប់គ្រង** ..... 31

៤.១.១.ព័ត៌មានទូទៅរបស់គ្រូ ........ 31

៤.១.២ ព័ត៌មានទូទៅរបស់គណៈគ្រប់គ្រង ........ 32

៤.១.៣. ទិន្នន័យឆ្លើយរបស់គ្រូ លើការបង្រៀនអំណានមុខវិជ្ជាភាសាខ្មែរ ........ 32

**៤.២. ទិន្នន័យឆ្លើយតបពី គណៈគ្រប់គ្រងសាលារៀន លើការអនុវត្តកម្មវិធីសិក្សា និងដំណើរការក្នុងការបង្រៀនអំណាន លើមុខវិជ្ជាភាសាខ្មែរ** ........ 36

**៤.៣. ការពិភាក្សាលើបញ្ហាប្រឈមរបស់គ្រូបង្រៀនអំណានមុខវិជ្ជាភាសាខ្មែរ** .... 40

**៤.៤. ទិន្នន័យឆ្លើយតបរបស់គ្រូទៅលើភាពខុសគ្នារវាងការបង្រៀនអំណានមុខវិជ្ជាភាសាខ្មែរ និងមុខវិជ្ជាផ្សេង** ........ 44

**៤.៥. ការពិភាក្សាលើភាពខុសគ្នារវាងការបង្រៀនអំណានមុខវិជ្ជាភាសាខ្មែរ និងមុខវិជ្ជាផ្សេង** ........ 46

**ជំពូកទី៥ សេចក្តីសន្និដ្ឋាន និងសំណូមពរ** ........ 50

**៥.១.សេចក្តីសន្និដ្ឋាន** ........ 50

**៥.២.សំណូមពរ** ........ 52

៥.២.១ ក្រសួងអប់រំ យុវជន និងកីឡា ........ 52

៥.២.២ មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ........ 52

៥.២.៣ គណៈគ្រប់គ្រងសាលារៀន ........ 53

៥.២.៤ គ្រូបង្រៀនមុខវិជ្ជាភាសាខ្មែរ ........ 53

៥.២.៥. សម្រាប់ការសិក្សាស្រាវជ្រាវបន្ត ....................................................53

**ឧបសម្ព័ន្ធ "ក"** ....................................................57

**គម្រោងសំណួរស្រាវជ្រាវសម្រាប់លោកគ្រូ-អ្នកគ្រូ បង្រៀនអំណាន មុខវិជ្ជាភាសាខ្មែរនៅកម្រិតបឋមសិក្សាក្នុងខេត្តព្រៃវែង** ....................................................57

**ឧបសម្ព័ន្ធ "ខ" គម្រោងសំណួរក្នុងការប្រមូលទិន្នន័យសម្រាប់គណៈគ្រប់គ្រង សាលារៀនបឋមសិក្សាក្នុងខេត្តព្រៃវែង**....................................................64

**ឧបសម្ព័ន្ធ "គ" លិខិតឧទ្ទេសនាម និងឯកសារពាក់ព័ន្ធ**....................................................69

# បញ្ជីតារាង


| តារាង | បរិយាយ | ទំព័រ |
|---|---|---|
| ២.១ | តារាងកម្មវិធីសិក្សាកម្រិតបឋមសិក្សា | 18 |
| ២.២ | តារាងបំណែងចែកម៉ោងសិក្សាលម្អិតមុខវិជ្ជាភាសាខ្មែរ | 19 |
| ៣.១ | ចំនួនភាគសំណាកដែលបានទទួលទិន្នន័យពីកម្រងសំណួរ | 29 |
| ៤.១ | ទិន្នន័យពីគ្រូលើការអនុវត្តកម្មវិធីសិក្សា | 32 |
| ៤.២ | ទិន្នន័យពីគ្រូលើការប្រើវិធីសាស្ត្របង្រៀនអំណាន | 33 |
| ៤.៣ | ទិន្នន័យពីគ្រូលើការរៀបចំ និងប្រើប្រាស់សម្ភារឧបទេសសម្រាប់បង្រៀនអំណាន | 34 |
| ៤.៤ | ទិន្នន័យពីគ្រូលើការសិក្សាអំណានមុខវិជ្ជាភាសាខ្មែរ | 35 |
| ៤.៥ | ទិន្នន័យសរុបពីគ្រូទៅលើបញ្ហាប្រឈមក្នុងការបង្រៀនអំណានមុខវិជ្ជាភាសាខ្មែរ | 36 |
| ៤.៦ | ទិន្នន័យឆ្លើយតបពីគណៈគ្រប់គ្រងលើកិច្ចគាំទ្រលើការងារពង្រឹងអំណាន | 37 |
| ៤.៧ | ទិន្នន័យឆ្លើយតបពីគណៈគ្រប់គ្រងលើដំណើរការនៃការបង្រៀនអំណានមុខវិជ្ជាភាសាខ្មែរ | 38 |
| ៤.៨ | ទិន្នន័យឆ្លើយតបពីគណៈគ្រប់គ្រងលើឥរិយាបថសិក្សាអំណានរបស់សិស្ស | 39 |
| ៤.៩ | ទិន្នន័យឆ្លើយតបរបស់គណៈគ្រប់គ្រងសាលា លើកិច្ចគាំទ្រក្នុងការបង្រៀនអំណានមុខវិជ្ជាភាសាខ្មែរ | 39 |
| ៤.១០ | ទិន្នន័យលើការពិភាក្សាលើបញ្ហាប្រឈមការបង្រៀនអំណានមុខវិជ្ជាភាសាខ្មែរ | 40 |
| ៤.១១ | ទិន្នន័យពីគ្រូអំពីភាពខុសគ្នារវាងការបង្រៀនអំណាន និងមុខវិជ្ជាផ្សេង | 44 |
| ៤.១២ | ទិន្នន័យពីគណៈគ្រប់គ្រងសាលាអំពីភាពខុសគ្នារវាងការបង្រៀនអំណាន និងមុខវិជ្ជាផ្សេង | 45 |
| ៤.១៣ | ទិន្នន័យលើការពិភាក្សាអំពីភាពខុសគ្នារវាងការបង្រៀនអំណាន និងមុខវិជ្ជាដទៃ | 47 |
| | ព័ត៌មានទូទៅគ្រូបង្រៀន | 63 |
| | ព័ត៌មានទូទៅគណៈគ្រប់គ្រងសាលារៀន | 69 |

# បញ្ជីអក្សរកាត់

| | | |
|---|---|---|
| ក្រសួង អយក | : | ក្រសួងអប់រំ យុវជន និងកីឡា |
| មន្ទីរ អយកខេត្ត | : | មន្ទីរអប់រំ យុវជន និងកីឡាខេត្ត |
| ការិ. អយក | : | ការិយាល័យអប់រំ យុវជន និងកីឡា ស្រុក/ក្រុង |
| EGRA | : | Early Grade Reading Assessment |
| EGMA | : | Early Grade Mathematic Assessment |
| PISA | : | Program for International Student Assessment |
| TIMSS | : | Trends International Mathematics and Science Study |
| SEA-PLM | : | Southeast Asia Primary Learning Matric |
| ICT | : | Information and Communication Technology |

# មូលន័យសង្ខេប

ការសិក្សាស្រាវជ្រាវពីការវាយតម្លៃទៅលើការបង្រៀនរបស់គ្រូស្ដីពីការបង្រៀនអំណានមុខវិជ្ជាភាសាខ្មែរក្នុងខេត្តព្រៃវែង មានគោលបំណងសិក្សាស្វែងយល់ពីស្ថានភាពគ្រូដែលកំពុងតែបង្រៀនអំណានដល់សិស្សានុសិស្ស បញ្ហាប្រឈមរបស់គ្រូក្នុងការបង្រៀនអំណាន និងភាពខុសគ្នារវាងការបង្រៀនអំណានមុខវិជ្ជាភាសាខ្មែរ និងមុខវិជ្ជាផ្សេងនៅតាមសាលាកម្រិតបឋមសិក្សាក្នុងខេត្តព្រៃវែង។

វិធីសាស្ត្រស្រាវជ្រាវគឺអនុវត្តតាមបែបបរិមាណវិស័យ។ ការប្រមូលទិន្នន័យ តាមរយៈកម្រងសំណួរស្រាវជ្រាវដែលសិក្សាចំនួន ៩ សាលាបឋមសិក្សានៅខេត្តព្រៃវែង ដែលមានចំនួនសំណាកសរុប ៨១នាក់ លោកគ្រូ-អ្នកគ្រូ ចំនួន៦៣នាក់ និងគណៈគ្រប់គ្រងសាលារៀនចំនួន១៨នាក់។ ការវិភាគទិន្នន័យ សិក្សាលើចំនួនភាគរយ តាមអថេរនីមួយៗ និងចំនួនមធ្យមភាគនៃសូចនាករតាមផ្នែក និងកម្រិតចង្អុលបង្ហាញចំនួន ៥កម្រិត ដោយគណនាតាមរូបមន្តកំណត់ជាក់លាក់។

តាមរយៈលទ្ធផលនៃការស្រាវជ្រាវលើប្រធានបទ ការវាយតម្លៃទៅលើការបង្រៀនរបស់គ្រូស្ដីពីអំណានមុខវិជ្ជាភាសាខ្មែរគឺមានស្ថានភាពល្អដែលទទួលបានមធ្យមភាគ ៤.១៣ ដែលគ្រូបង្រៀនបានអនុវត្តបានល្អទៅលើការបង្រៀនចប់តាមកម្មវិធីសិក្សាដែលក្រសួងបានដាក់ឱ្យ គ្រូបង្រៀនមានកិច្ចតែងការបង្រៀននឹងវិធីសាស្ត្របង្រៀនអំណានសម្បូរបែបឆ្លើយតបទៅនឹងស្ថានភាពនៃការសិក្សាអំណានរបស់សិស្ស ហើយសិស្សានុសិស្សមានស្មារតីខ្ពស់នៅក្នុងការសិក្សាអំណានមុខវិជ្ជាភាសាខ្មែរ។ ការបង្រៀនអំណានក៏នៅមានបញ្ហាប្រឈមទៅលើ ការរៀបចំ និងប្រើប្រាស់សម្ភារឧបទេសសម្រាប់បង្រៀនអំណានដែលធ្វើឱ្យសិស្សមានអារម្មណ៍ធុញថប់ក្នុងការសិក្សាអំណាន ព្រមទាំងធ្វើឱ្យប៉ះពាល់ដល់ដំណើរការនៃការអនុវត្តវិធីសាស្ត្របង្រៀនមិនបានពេញលេញ មិនឆ្លើយតបទៅនឹងវត្ថុបំណងរបស់មេរៀន និងធ្វើឱ្យមានផលប៉ះពាល់ដល់ប្រសិទ្ធភាពនៃការរៀនអំណានមុខវិជ្ជាភាសាខ្មែរនៅកម្រិតបឋមសិក្សា។

សរុបសេចក្ដីមកការវាយតម្លៃទៅលើការបង្រៀនរបស់គ្រូស្ដីពីការបង្រៀនអំណានមុខវិជ្ជាភាសាខ្មែរនៅខេត្តព្រៃវែង បានបង្ហាញពីកម្រិតល្អ នៃការបង្រៀនរបស់គ្រូនៅកម្រិតបឋមសិក្សា ក្នុងខេត្តព្រៃវែងក្នុងកម្រិតល្អ ឆ្លុះបញ្ចាំងថាគ្រូបង្រៀនបានអនុវត្តតាមកម្មវិធីសិក្សា វិធីសាស្ត្របង្រៀន និងស្មារតីសិក្សាអំណាន

របស់សិស្ស។ ក្នុងចំណុចវិជ្ជមានរបស់គ្រូក្នុងការបង្រៀនអំណានមុខវិជ្ជាភាសាខ្មែរ ដែលបានបំពេញក្នុងកម្រិតល្អហើយនោះ ក៏នៅមានចំណុចដែលតម្រូវឱ្យមានការលើកកម្ពស់គឺ គ្រូបង្រៀនត្រូវប្រើប្រាស់សម្ភារឧបទេសបង្រៀនអំណានជាប្រចាំ សម្ភារឧបទេសត្រូវរៀបចំឱ្យមានភាពទាក់ទាញអារម្មណ៍សិស្ស និងមានគុណភាពឆ្លើយតបនឹងខ្លឹមសារមេរៀន ដើម្បីជានាបានការអប់រំពលរដ្ឋពេញលេញ និងមូលធនមនុស្សឆ្លើយតបនឹងគោលដៅអប់រំឆ្នាំ ២០៣០ និង គោលដៅអប់រំសហវត្សឆ្នាំ ២០៥០។

ការបង្រៀនអំណានមុខវិជ្ជាភាសាខ្មែរនៅកម្រិតបឋមសិក្សាក៏មានភាពខុសប្លែកគ្នាជាមួយមុខវិជ្ជាផ្សេង ដោយមុខវិជ្ជាអំណានទទួលបានការយកចិត្តទុកដាក់ក្នុងដំណើរការរៀន និងបង្រៀនឱ្យកាន់តែមានប្រសិទ្ធភាពដូចជាមានការរៀបចំទិវាជាតិអំណាន ការដាក់ម៉ោងអំណានបន្ថែមនៅក្នុងបណ្ណាល័យដើម្បីបង្កើនសមត្ថភាពនៃអំណានរបស់សិស្ស គ្រូបង្រៀនបានយកចិត្តទុកដាក់នៅក្នុងការបង្រៀនអំណានដោយគោរពតាមនិយាមឬក្បួនខ្នាតក្នុងការបង្រៀនអំណាន ផ្តល់ភាពជាគំរូ ក្នុងការប្រកប ការបញ្ចេញសូរសំឡេង និងទំនាញសូរព្យញ្ជនៈស្រៈដល់សិស្សជាដើម។ លើពីនេះគ្រូបង្រៀនមានស្មារតីខ្ពស់ក្នុងការលើកកម្ពស់ដល់ការសិក្សាអំណានមុខវិជ្ជាភាសាខ្មែរដោយផ្តោតសំខាន់ទៅលើភាពត្រឹមត្រូវនៃការអាន ការគោរពសញ្ញា សម្ព័ន្ធ ការលើកដាក់សំឡេងក្នុងពេលអាន ជាងមុខវិជ្ជាផ្សេង។ ចំពោះដំណើរការនៃបង្រៀនអំណានមុខវិជ្ជាភាសាខ្មែរ និងមុខវិជ្ជាផ្សេងមានភាពប្រហាក់ប្រហែលគ្នានៅក្នុងក្របខណ្ឌរយៈពេលសិក្សាក្នុងមួយឆ្នាំសិក្សាដោយមុខវិជ្ជានីមួយៗមានរយៈពេល៣៥សប្តាហ៍ក្នុង១ឆ្នាំសិក្សាដូចគ្នា ដែលចែកជា៣០ម៉ោងសិក្សាក្នុង១សប្តាហ៍ដូចគ្នា។

# Abstract

The purpose of an Evaluation of the Teaching of Reading Comprehension Khmer Language at Primary School in Prey Veng Province is to understand the current teachers' teaching students how to read, the issues teachers are facing and the differences between teaching how to read Khmer language and other subjects at the primary schools in Prey Veng.

The methodology of this research is conducted based on numeracy. The data is collected based on questionnaires from 9 primary schools in Prey Veng from 81 participants, 63 male and female teachers and 18 of the school managements. Analysis of the data is based on instability and percentage of questions and level of 5 indicators which are calculated based on certain methodology.

Based on the results of this study, the evaluation of teachers teaching on reading Khmer is good with average of 4,13 percent are conducted in accordance with the Ministry of Education curriculum , teachers have prepared their teaching and the method of teaching are convening accordingly to students situations in learning how to read and student are highly anticipated to learn how to read Khmer. The teaching is also facing some issues such as preparation and utilization of teaching materials which in turn making students feel bored to learn how to read Khmer, it also impacts on the implementation of the teaching methodology from carrying out comprehensively and reflecting the purpose of teaching and consequently influents on the effectiveness of learning Khmer language across primary schools.

In conclusion, the evaluation on teaching how to read Khmer in Prey Veng has shown high level of teaching methodology used by teachers across Prey Veng primary school, which are reflecting the implementation of their study program, teaching method and student confidence. Even though there are positive outcomes, certain issues must be addressed such as the utilization of teaching materials which should be on regular basis, the preparation of teaching materials should appeal to students' attention, shall reflecting the cores of the lessons to ensure that population education and human resources are met in order to achieve the target by 2030 and 2050 educational objective.

The teaching on how to read Khmer in primary school are different form teaching other subjects, as the teaching how to read Khmer has focus its attention on how to teach effectively such as the reading day, the additional reading time in the library to strengthen students ability to read and the pronunciation of consonants Etc. On top of this, teachers are highly motivated to learn Khmer subject by focusing on correct reading, respecting consolidation and pronunciation of words during reading than any other subjects. The similarity of teaching Khmer language and other subjects are 35 weeks per year and 30 per weeks.

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការសិក្សាស្រាវជ្រាវ

សង្គមមួយដែលរីកចម្រើនខ្លាំង គឺជាសង្គមដែលប្រជាជនអានច្រើន និងនិយមចូលចិត្តការសិក្សារៀនសូត្រជាប្រចាំ ដែលអាចហៅបានថា ការអានឬអំណាន គឺជាផ្នែកមួយនៃជីវិត។ ពេលខ្លះ កុំថាដល់យើងប្រឹងអានដើម្បីសង្គម តែបើប្រឹងអានដើម្បីអនាគតខ្លួនឯង គឺអាចហៅបានថាស្រឡាញ់សង្គមពិតទៅហើយ។ យើងចំណាយលុយទិញឡេលាបមុខ លាបស្បែក ដើម្បីឱ្យរូបរាងស្អាត សាច់សខ្ចី មុខម៉ត់រលោងស្អាត។ មិនត្រឹមតែប៉ុណ្ណោះ យើងចំណាយលុយទិញការហូបញុំាស្ទើររាល់ថ្ងៃ។ អ្វីៗទាំងអស់នេះបំពេញតម្រូវការសម្បកកាយ។ ចំណែកខួរក្បាល់យើងវិញក៏ត្រូវការអាហារដែរ អាហារទាំងគឺជាការគិត ការវិភាគ ការត្រិះរិះពិចារណាដ៏ត្រឹមត្រូវតាមរយៈការអានសៀវភៅ។ រាងកាយត្រូវការអាហារដើម្បីចិញ្ចឹម ហើយខួរក្បាលត្រូវការអាហារគំនិតផងដែរ។

យោងតាមអង្គការយូណេស្កូ(២០១៥) បានលើឡើងថាប្រទេសមួយចំនួននៅលើពិភពលោកតែងតែខិតខំប្រឹងប្រែង និងយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការផលិតធនធានមនុស្ស ដើម្បីធានាបាននូវការអភិវឌ្ឍន៍ប្រទេស ប្រកបទៅដោយនិរន្តរភាព ភាពសុខដុមរមនា និង ចីរភាព។ ក្នុងនោះវិស័យអប់រំមានកាតព្វកិច្ចយ៉ាងសំខាន់ ក្នុងការបង្កើត និងធ្វើឱ្យមានការរីកលូតលាស់លើគ្រប់វិស័យ និងឆ្ពោះទៅមុខជានិច្ច ព្រោះថាការអប់រំគឺជាកតាលីករដ៏ចម្បងបំផុត ក្នុងការបំពេញតម្រូវការធនធានមនុស្ស ដែលពេញទៅដោយចំណេះដឹង ជំនាញឯកទេស ឥរិយាបថ និងក្រមសីលធ៌មពេញលេញ ដែលសក្តិសមជាធនធានដ៏មានសក្តានុពល ហើយជាតម្រូវការរបស់ប្រទេសទាំងនោះ។ ការលើកកម្ពស់វិស័យអប់រំរបស់ពិភពលោកនៅតែបន្តឥតឈប់ឈរ ដោយឆ្លុះបញ្ចាំងតាមរយៈចក្ខុវិស័យ ឆ្ពោះទៅរកឆ្នាំ២០៣០ និងផ្តោតសំខាន់ទៅលើការផ្លាស់ប្តូរជីវិត ឱ្យកាន់តែប្រសើរឡើង តាមរយៈការអប់រំ។ ដើម្បីឆ្លើយតបទៅនឹងគោលដៅទាំងនេះទើបមានការលើកឡើងថា "ការអប់រំធានាឱ្យបាននូវ គុណភាព ប្រសិទ្ធភាព សមធម៌ បរិយាបន្ន រួមទាំងលើកកម្ពស់ឱកាសការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា"។

ដើម្បីឆ្លើយតបទៅនឹងនិន្នាការរបស់ពិភពលោក ដែលកំពុងផ្តោតការយកចិត្តទុកដាក់ទៅលើ ការលើកកម្ពស់វិស័យអប់រំ ទើបសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ហៅកាត់ថាអាស៊ាន បានកំណត់ចក្ខុវិស័យរបស់ខ្លួន ដោយជំរុញឱ្យប្រទេសនីមួយៗ នៅក្នុងតំបន់ដែលជាសមាជិកខិតខំធ្វើការកំណែទម្រង់លើគ្រប់វិស័យដើម្បីឱ្យមានស្តង់ដាប្រហាក់ប្រហែលគ្នារវាងប្រទេសជាសមាជិកទាំងអស់ តាមរយៈការធ្វើ សមាហរណកម្មអាស៊ាននៅឆ្នាំ២០១៥។ ក្នុងនោះវិស័យអប់រំជាវិស័យអាទិភាពមួយ ដែលប្រទេសទាំងអស់ក្នុងតំបន់ជាសមាជិក ត្រូវធានាលើកកម្ពស់គុណភាពអប់រំ របស់ខ្លួនធ្វើយ៉ាងណារៀបចំប្រជាពលរដ្ឋរបស់ខ្លួនឱ្យក្លាយទៅជាធនធានមនុស្ស ដែលប្រកបដោយចំណេះដឹង ជំនាញឯកទេស និងក្លាយជាកម្មករជំនាញ។

ដោយផ្អែកទៅលើបរិបទពិភពលោក និងប្រទេសក្នុងតំបន់ ដែលផ្តោតការយកចិត្តទុកដាក់ចំពោះវិស័យអប់រំ រាជរដ្ឋាភិបាលកម្ពុជានៅក្នុងអាណត្តិទី៦នេះបាន ផ្តល់អាទិភាពទី១ទៅលើការអភិវឌ្ឍន៍ធនធានមនុស្សទៅក្នុងយុទ្ធសាស្ត្រចតុកោណរបស់ខ្លួន ក៏ព្រោះតែកម្ពុជាក៏មានមហិច្ឆតាចង់ប្រែក្លាយខ្លួនឱ្យទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងឈានទៅប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០ យោងតាមឯកសារ យុទ្ធសាស្ត្រចតុកោណដើម្បីកំណើនការងារសមធម៌ និងប្រសិទ្ធភាពនៅកម្ពុជាដំណាក់កាលទី៣ រាជរដ្ឋាភិបាលកម្ពុជា(២០១៨)។

ប្រទេសកម្ពុជាមានមហិច្ឆតា ប្រែក្លាយខ្លួនជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់ឆ្នាំ២០៣០ និងឈានឡើងទៅជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ ដើម្បីសម្រេចមហិច្ឆតានេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ ដែលការអភិវឌ្ឍន៍ធនធានមនុស្ស គឺជាផ្នែកមួយនៃការសម្របសម្រួលគោលនយោបាយគាំទ្រ។ កំណែទម្រង់វិស័យអប់រំសំដៅលើកកម្ពស់គុណភាពអប់រំ និងអភិវឌ្ឍធនធានមនុស្ស ស្របទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព២០១៥-២០៣០។ ការអប់រំនៅកម្រិតថ្នាក់ដំបូងគឺត្រូវបានយកចិត្តទុកដាក់បំផុត ព្រោះវាជាមូលដ្ឋានគ្រឹះក្នុងការសិក្សាលើមុខវិជ្ជាផ្សេង និងជំនាញវិជ្ជាជីវៈផ្សេងៗ ព្រមទាំងអាចជួយឱ្យមនុស្សបន្តការសិក្សាពេញមួយជីវិត យោងតាមបុព្វកថាឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា( ទី០៦ ខែកក្កដា ឆ្នាំ២០១៨)។

ក្នុងនោះផងដែរ រាជរដ្ឋាភិបាល ក៏ដូចជាក្រសួងអប់រំ យុវជន និងកីឡាក៏បានខិតខំ រៀបចំនូវកម្មវិធីផ្សេងៗជាច្រើន ដើម្បីលើកកម្ពស់គុណភាពអប់រំ ជាពិសេសគឺរៀបចំ ទិវាជាតិអំណានក្នុងទិសដៅបណ្តុះទម្លាប់អាន ជំរុញវប្បធ៌មអាន លើកកម្ពស់សមត្ថភាពតែងនិពន្ធរួមចំណែកការពារនិងពង្រឹងវប្បធម៌ខ្មែរ។ គ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ សង្គមស៊ីវិល អង្គការអន្តរជាតិ វិស័យឯកជន និងគ្រឹះស្ថានសិក្សា ចូលរួមបំផុសមន្ត្រីរាជការ សិស្ស និស្សិត កម្មករ និយោជិត និយោជក កងកម្លាំងប្រដាប់អាវុធ និងប្រជាជន បង្កើតស្មារតីប្រឡងប្រណាំងអំណាននិងតែងនិពន្ធ យោងតាមអនុក្រឹតស្តីពីទិវាអំណានជាតិ រាជរដ្ឋាភិបាល (២០១៥)។ ក្នុងនោះផងដែរបណ្ណាល័យជាតិកម្ពុជា សហការជាមួយអង្គការនានា បានរៀបចំកម្មវិធីពិព័ណ៌សៀវភៅជារៀងរាល់ឆ្នាំ ដើម្បីជួយដល់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការលើកកម្ពស់ការអានរបស់សិស្សានុសិស្សព្រមទាំងលើកកម្ពស់ទៅលើស្មារដែរបស់អ្នកតែងនិពន្ធសៀវភៅឬសម្ភារៈអំណានជូនដល់មហាជន។ ក្រសួងអប់រំ យុវជន និងកីឡាក៏បានបង្កើតយុទ្ធនាការ តោះអានរាល់ថ្ងៃ ជាចលករមួយដ៏សំខាន់ដែលជួយបង្កើនទម្លាប់អាននៅកម្ពុជា ដើម្បីសម្រេចគោលដៅអប់រំប្រកបដោយគុណភាព និងការសិក្សារៀនសូត្រពេញមួយជីវិត។

## ១.២ ចំណោទបញ្ហានៃការសិក្សាស្រាវជ្រាវ

អំណានមានសារៈសំខាន់ណាស់ក្នុងការរួមចំណែកក្នុងការកាត់បន្ថយអនក្ខរភាពនៅកម្ពុជា។ ចំណេះដឹង និងព័ត៌មានជាច្រើនទទួលបានតាមរយៈការអាន ហើយការអានក៏រួមចំណែកក្នុងការបើកគំនិតឱ្យចក្ខុវិស័យទូលំទូលាយ ឆ្លើយតបទៅតាមបរិបទសកល។ ក្នុងយុគសម័យសកលភាវូបនីយកម្ម ប្រទេសជាច្រើននៅលើពិភពលោកបានយកចិត្តទុកដាក់ឱ្យប្រជាពលរដ្ឋមានទម្លាប់អានសៀវភៅ និងទទួលបានឱកាសក្នុងការសិក្សាពេញមួយជីវិត។ ដោយឡែកប្រទេសកម្ពុជា វប្បធ៌មអានត្រូវបានកាត់ផ្តាច់ទាំងស្រុងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យរយៈពេល ០៣ឆ្នាំ ០៨ខែនិង២០ថ្ងៃ។ បន្ទាប់ពីថ្ងៃរំដោះ ០៧ មករា ឆ្នាំ ១៩៧៩មក រដ្ឋាភិបាលបានខិតខំស្តារឡើងវិញនូវវប្បធ៌មអាន ប៉ុន្តែប្រជាជនកម្ពុជាភាគច្រើនបានបាត់បង់ទម្លាប់អានដោយសារតែសង្គ្រាមស៊ីវិល ភាពក្រីក្រ អនក្ខរភាព និងមិនមានឯកសារដែលលើកទឹកចិត្តដល់អ្នកអានឡើយ។

ការសិក្សាអំណានភាសាខ្មែរត្រូវផ្តោតសំខាន់លើបំណិនបួនសំខាន់ៗមាន បំណិនអាន បំណិនស្តាប់ បំណិននិយាយ និងបំណិនសរសេរ ទើបអាចធ្វើឱ្យដំណើរការនៃការសិក្សាភាសាខ្មែរទទួលបានលទ្ធផលជាផ្លែផ្កា។ ដោយសារស្ថានភាពពេលវេលា ចំណូលចិត្ត ឧបនិស្ស័យ ក៏ដូចជាភាពចង់ចេះចង់ដឹងរបស់អ្នកសិក្សាស្រាវជ្រាវ ទើបអ្នកសិក្សាជ្រើសរើសយកតែបំណិនមួយគត់ក្នុងចំណោមបំណិនទាំងបួននៅក្នុងការសិក្សាមុខវិជ្ជាភាសាខ្មែរមកធ្វើការសិក្សាស្រាវជ្រាវគឺ បំណិនអាន។

បំណិនអានគឺ ជាបំណិនមួយដ៏សំខាន់សម្រាប់អ្នកសិក្សាមុខវិជ្ជាភាសាខ្មែរ មិនតែប៉ុណ្ណោះមុខវិជ្ជាគណិតវិទ្យា វិទ្យាសាស្ត្រ និងសិក្សាសង្គមក៏ត្រូវការមុខវិជ្ជាអំណានដើម្បីកសាងមូលដ្ឋាននៃចំណេះដឹងក្នុងការបម្រើដល់ដំណើរនៃការសិក្សាមុខវិជ្ជាទាំងនោះបានល្អ។ ដើម្បីឱ្យការសិក្សាបំណិនអានប្រកបដោយគុណភាព និងប្រសិទ្ធភាពបាន លុះត្រាតែកុមារសិក្សាលើសមាសភាគប្រាំសម្រាប់អំណានថ្នាក់ដំបូងគឺៈ(១) សមត្ថភាពក្នុងការស្គាល់សូរអក្សរ(២) សមត្ថភាពក្នុងការស្គាល់តួអក្សរ(៣) សមត្ថភាពក្នុងការផ្សំប្រកបដើម្បីអានព្យាង្គ និងពាក្យ(៤)សមត្ថភាពក្នុងការអានស្ទាត់ទៅលើល្បះខ្លីៗ និងអត្ថបទ(៥)សមត្ថភាពក្នុងការសរសេរអក្សរ ព្យាង្គ ពាក្យ ល្បះ និងអត្ថបទ ព្រមទាំងមានវិធីសាស្ត្របង្រៀនបំណិនអានប្រកបដោយគុណភាពស្របតាមគោលវិធីសិស្សមជ្ឈមណ្ឌល សៀវភៅណែនាំសម្រាប់គ្រូបង្រៀនថ្នាក់ទី១(២០២០)។

អ្នកដែលអាន គឺជាមនុស្សដែលរស់ តែអ្នកដែលមិនអាន គឺតែងតែស្លាប់រាល់ថ្ងៃ។ មានឧបសគ្គជាច្រើនដែលរារាំងយើងមិនឱ្យចូលចិត្តអានសៀវភៅ តែបើមិនព្រមជម្នះឱ្យឈ្នះទេ គឺយើងនឹងជួបឧបសគ្គដែលលំបាកជាងការអានទៅទៀត។ អ្នកដែលមិនអាន គឺដូចជាមនុស្សឥតវិញ្ញាណ។ យើងតែងនិយាយថាការអានគឺជាថ្នាំងងុយគេងដ៏មានប្រសិទ្ធភាព ដ្បិតឱ្យតែពេលណាយើងកាន់សៀវភៅអាន គឺដឹងតែយើងមានអារម្មណ៍ងងុយគេងភ្លាម។ ប៉ុន្តែ បើយើងមិនមានចិត្តអត់ធ្មត់ប្រឹងអានឱ្យបានច្រើនទេគឺយើងនឹងគេងជារៀងរហូតហើយ សៀវភៅអំណានជាអំណាច(២០១៩)។

សរុបសេចក្តីមក ការអានគឺបានជះឥទ្ធិពលយ៉ាងខ្លាំងដល់ការគិត និងការសិក្សារបស់កុមារ និងមនុស្សទូទៅឆ្លើយតបទៅនឹងការអប់រំពលរដ្ឋពេញលេញ ព្រមទាំងកិច្ចកសាងមនសិការរបស់មនុស្សជាតិផងដែរ។ ការអានជួយមនុស្សទទួលឱ្យទទួលបានព័ត៌មានផ្សេងៗ មានការត្រិះរិះពិចារណាទៅលើហេតុ

ការណ៍ច្បាស់លាស់ មានសមត្ថភាពក្នុងការគ្រប់គ្រងអារម្មណ៍ខ្លួនឯងមិនឱ្យឆេវឆាវ អាចដោះស្រាយបញ្ហាផ្សេងៗ ព្រមទាំងមានការគិតស៊ីជម្រៅជាដើម។ ចំពោះកុមារដែលចេះអាន គេងាយក្នុងសិក្សាមុខវិជ្ជាផ្សេងៗ មានឱកាសក្នុងការធ្វើស្វ័យសិក្សាដោយខ្លួនឯងនៅក្នុងដំណើរការសិក្សារៀនសូត្រ ព្រោះអំណានជាមូលដ្ឋានគ្រឹះមួយផ្នែកនៃការរៀនអក្សរ តាមរយៈព្យញ្ជនៈ និងស្រៈ។ អំណាន បានជួយឱ្យដំណើរការសិក្សារបស់សិស្សានុសិស្សនៅកម្រិតបឋមសិក្សាមានភាពល្អប្រសើរឡើង និងជំរុញកិច្ចខិតខំប្រឹងប្រែងក្នុងវិស័យសិក្សាធិការទៅពេលអនាគតផងដែរ។ បើសិស្សអាចចេះអាន ចាប់តាំងពីរៀននៅកម្រិតបឋមសិក្សា នោះដំណើរការនៃការសិក្សារៀនសូត្រនឹងទទួលបានជោគជ័យ ព្រមទាំងក្លាយជាអ្នកដែលមានបំណិនអាន និងទម្លាប់អាននៅពេលអនាគត ចូលរួមឆ្លើយតបទៅនឹង "ការអប់រំដើម្បីទាំងអស់គ្នា ទាំងអស់គ្នាដើម្បីការអប់រំ" និង "ការសិក្សាពេញមួយជីវិត"ផងដែរ។ ដោយឈរលើមូលដ្ឋាននៃកម្រិតដំបូងនៅបឋមសិក្សាដែលជាថ្នាលចាក់គ្រឹះ ការអប់រំដល់ទំពាំងនោះ ការសិក្សាស្រាវជ្រាវពីប្រធានបទ "ការវាយតម្លៃលើការបង្រៀនរបស់គ្រូ ស្តីពីអំណាននៅកម្រិតបឋមសិក្សា" ត្រូវយកមកធ្វើការសិក្សាស្រាវជ្រាវ ដើម្បីសិក្សាស្វែងយល់ទស្សនៈពាក់ព័ន្ធទៅនឹងការបង្រៀនអំណាន ក៏ដូចជាបញ្ហាប្រឈម សំដៅបង្កលក្ខណៈធានាដល់កិច្ចការងារបង្រៀនអំណានទទួលបានគុណភាពកាន់តែល្អប្រសើរនៅកម្រិតបឋមសិក្សា។ ការសិក្សាស្រាវជ្រាវពីអំណានមុខវិជ្ជាភាសាខ្មែរនៅកម្រិតបឋមសិក្សា បានបង្កបរិយាកាសសិក្សារបស់សិស្សមានប្រសើរឡើង បានចូលរួមជួយលើកកម្ពស់ភាសាជាតិទាំងការអានតាមអក្ខរក្រម ការបញ្ចេញសូរសព្ទ និងការសរសេរអក្ខរាវិរុទ្ធ គ្រូបង្រៀនធ្វើបច្ចុប្បន្នភាពលើវិធីសាស្ត្របង្រៀនដើម្បីបំពេញតម្រូវការសិក្សាអំណាន ពង្រឹងការអនុវត្តគោលនយោបាយអប់រំស្តីពីអំណាន និងកិច្ចការចូលរួមគាំទ្រពីភាគីពាក់ព័ន្ធនានាផងដែរ។

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាប្រធានបទ ការវាយតម្លៃការបង្រៀនរបស់គ្រូស្តីពីអំណានមុខវិជ្ជាភាសាខ្មែរនៅកម្រិតបឋមសិក្សាក្នុងខេត្តព្រៃវែងមានគោលបំណងពីរគឺ៖

១. សិក្សាពីបញ្ហាប្រឈមរបស់គ្រូក្នុងការបង្រៀនអំណាននៅសាលាកម្រិតបឋមសិក្សា។

២. សិក្សាអំពីភាពខុសគ្នារវាងការបង្រៀនអំណានមុខវិជ្ជាភាសាខ្មែរ និងមុខវិជ្ជាផ្សេងទៀតនៅតាមសាលាកម្រិតបឋមសិក្សា។

## ១.៤ សំណួរស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងគោលបំណង អ្នកសិក្សាស្រាវជ្រាវបានលើកយកនូវសំណួរស្រាវជ្រាវចំនួនពីរគឺ៖

១. តើគ្រូបង្រៀនអំណាន លើមុខវិជ្ជាភាសាខ្មែរនៅកម្រិតបឋមសិក្សា មានបញ្ហាប្រឈមអ្វីខ្លះ?

២. តើការបង្រៀនអំណានលើមុខវិជ្ជាភាសាខ្មែរ នៅកម្រិតបឋមសិក្សា ខុសគ្នាជាមួយការបង្រៀនមុខវិជ្ជាផ្សេងទៀត យ៉ាងដូចម្តេច?

## ១.៥ សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះមានសារៈសំខាន់ណាស់ ពីព្រោះវានឹងបង្ហាញឱ្យឃើញនូវបញ្ហាប្រឈមមួយចំនួនសម្រាប់ជួយដល់គ្រូបង្រៀនក្នុងការដោះស្រាយឱ្យបានទាន់ពេលវេលា និងកែលម្អគុណភាពប្រសិទ្ធភាពនៃការបង្រៀនអំណាន នៅបឋមសិក្សាដើម្បីរួមចំណែកជាមួយរាជរដ្ឋាភិបាល និងក្រសួងអប់រំក្នុងការដោះស្រាយ និងពង្រឹងវិស័យអប់រំរបស់រដ្ឋ ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ជាងពេលបច្ចុប្បន្ន។ ការស្រាវជ្រាវនេះ នឹងផ្តល់របកគំហើញថ្មីមួយ សម្រាប់ចូលរួមវិភាគទានដល់អ្នកសិក្សាជំនាន់ក្រោយៗ។

## ១.៦ វិសាលភាព និងដែនកំណត់នៃការសិក្សាស្រាវជ្រាវ

ការស្រាវជ្រាវលើប្រធានបទស្តីពី "ការវាយតម្លៃទៅលើការបង្រៀនរបស់គ្រូស្តីពីអំណាននៅកម្រិតបឋមសិក្សាក្នុងខេត្តព្រៃវែង" អ្នកសិក្សាស្រាវជ្រាវផ្តោតទៅលើការបង្រៀនអំណានមុខវិជ្ជាភាសាខ្មែរ និងភាពខុសគ្នារវាងការបង្រៀនអំណានមុខវិជ្ជាភាសាខ្មែរ និងការបង្រៀនមុខវិជ្ជាផ្សេងទៀតនៅកម្រិតបឋមសិក្សា។ ទិន្នន័យដែលប្រមូលយកមកវិភាគ ដើម្បីបង្ហាញលទ្ធផលនៃការសិក្សាគឺមានការចូលរួមពីគណៈគ្រប់គ្រងសាលារៀន និងគ្រូដែលកំពុងបង្រៀននៅកម្រិតបឋមសិក្សាក្នុងខេត្តព្រៃវែង។ ការសិក្សាស្រាវជ្រាវគឺផ្តោតតែអំណានមុខវិជ្ជាភាសាខ្មែរ នៅកម្រិតបឋមសិក្សា។ ចំនួនភាគសំណាក គឺមានចំនួន ៩សាលាកម្រិតបឋមសិក្សា ស្ថិតនៅក្នុងស្រុកចំនួន៣ គ្រូបង្រៀនចំនួន ៦៣នាក់ និងគណៈគ្រប់គ្រងសាលាចំនួន ១៨នាក់។

## ១.៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ត្រូវបានបែងចែកជា ៥ជំពូក៖

**ជំពូកទី១៖** សេចក្តីផ្តើម ក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវនឹងលើកឡើងពីលំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ សំណួរស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ ដែនកំណត់ និងវិសាលភាពនៃការសិក្សាស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

**ជំពូកទី២៖** រំឭកទ្រឹស្តី នៅក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវបានសិក្សាលើនិយមន័យពាក្យគន្លឹះ សិក្សាទ្រឹស្តីពាក់ព័ន្ធនឹងប្រធានបទ ឯកសារគតិយុត្តិនានា និងអត្ថបទស្រាវជ្រាវដែលពាក់ព័ន្ធនឹងប្រធានបទសិក្សាស្រាវជ្រាវ។

**ជំពូកទី៣៖** វិធីសាស្ត្រស្រាវជ្រាវ ជំពូកនេះ អ្នកសិក្សាស្រាវជ្រាវនឹងបង្ហាញនូវឧបករណ៍ស្រាវជ្រាវវិធីសាស្ត្រប្រមូលទិន្នន័យ វិធីជ្រើសរើសសំណាក ព្រមទាំងវិធីសាស្ត្រក្នុងការវិភាគទិន្នន័យជាដើម។

**ជំពូកទី៤៖** លទ្ធផលនិងការពិភាក្សា ជំពូកនេះអ្នកសិក្សាស្រាវជ្រាវនឹងបង្ហាញនូវលទ្ធផលនៃការស្រាវជ្រាវតាមរយៈកម្រងសំណួរ និងការពិភាក្សាលើលទ្ធផល។

**ជំពូកទី៥៖** សេចក្តីសន្និដ្ឋាន និងសំណូមពរ ជំពូកនេះអ្នកសិក្សាស្រាវជ្រាវនឹងធ្វើសេចក្តីសន្និដ្ឋាន ឆ្លើយតបទៅលើសំណួរស្រាវជ្រាវ ដោយបង្ហាញលទ្ធផលតាមរយៈទិន្នន័យដែលបានពីកម្រងសំណួរ និងការសង្ខេបខ្លឹមសារពិភាក្សាតាមរយៈការឆ្លុះបញ្ចាំងពីចំណុចវិជ្ជមាន និង ចំណុចត្រូវកែលម្អ។ លើកសំណូមពរតាមរយៈប្រធានបទសិក្សា ដល់ភាគីពាក់ព័ន្ធ និងអ្នកសិក្សាស្រាវជ្រាវបន្តនៅថ្ងៃអនាគត ដើម្បីពង្រីកវិសាលភាពនៃលទ្ធផលលើប្រធានបទដែលបានលើកយកមកសិក្សាស្រាវជ្រាវរួច។

# ជំពូកទី២
# រំលឹកទ្រឹស្តី

## ២.១ ព័ត៌មានពីការអប់រំនៅខេត្តព្រៃវែង

ខេត្តព្រៃវែង ជាខេត្តមួយដែលស្ថិតនៅភាគអាគ្នេយ៍នៃព្រះរាជាណាចក្រកម្ពុជាដែលមានចម្ងាយ ៩០ គីឡូម៉ែត្រពីរាជធានីភ្នំពេញ និងមានព្រំប្រទល់ជាប់ ខេត្តស្វាយរៀង ខេត្តត្បូងឃ្មុំ ខេត្តកំពង់ចាម ខេត្តកណ្តាល និងប្រទេសវៀតណាម។ មានប្រជាជនសរុប៩៤៧ ៣៥៧ ផ្ទៃដីសរុប ៤ ៨៨៣ គីឡូម៉ែត្រការ៉េ ដែលមានដងស៊ីតេប្រជាជន១៩៤នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ។ ខេត្តព្រៃវែងមានស្រុកសរុបចំនួន១២ ក្រុង១ មានឃុំចំនួន១១៦ ភូមិចំនួន១១៣៩ និងមានសាលារៀនកម្រិតបឋមសិក្សា៥៤៧ មានថ្នាក់រៀនសរុប៤៥៦២ ថ្នាក់គួបចំនួន១៤៤ ថ្នាក់ពីរវេន១៧៧៣ គ្រូសរុប៤០៦០នាក់ គ្រូជាប់កិច្ចសន្យា២៤៧នាក់ មានសិស្សសរុប ១៤៨៩៣៣នាក់ ដែល ១៥៥៥៧ ជាសិស្សក្រីក្រ គិតត្រឹមឆ្នាំសិក្សា២០១៩ -២០២០ ។ ប្រជាជននៅខេត្តព្រៃវែងភាគច្រើនប្រកបមុខរបរកសិកម្ម ធ្វើស្រែនិងដាំដំណាំ។ ខេត្តព្រៃវែងជាទូទៅហៅឈ្មោះថា "ខ្សែក្រវាត់បៃតងធំ" និងបានរួមចំណែកក្នុងការផលិតស្រូវបានចំនួន១០ភាគរយនៃផលិតផលស្រូវសរុបរបស់ប្រទេសហើយអត្រាប្រជាជនរស់នៅក្រោមខ្សែបន្ទាត់ក្រីក្រជាមធ្យមប្រហែល ៥៣% ពោលគឺ៣៦% ភាគរយក្រោមខ្សែបន្ទាត់នៃភាពក្រីក្រទូទាំងប្រទេស។

## ២.២ និយមន័យ

### ២.២.១. អំណាន

យោងតាមប្រសាសន៍របស់ឯកឧត្តមបណ្ឌិតសភាចារ្យ ណាត ប៊ុនរឿន រដ្ឋលេខាធិការ របស់ក្រសួងអប់រំ(០៥ កុម្ភៈ ២០២០) បានលើកឡើងថាអំណានគឺ មានសារៈសំខាន់ណាស់សម្រាប់មនុស្សគ្រប់វ័យកាលណាមនុស្សអានច្រើន ធ្វើឱ្យមនុស្សគិតច្រើន ព្រមទាំងធ្វើឱ្យមានអាយុវែង។

យោងតាមវចនានុក្រម សម្តេចព្រះសង្ឃរាជ ជួន ណាត បោះពុម្ពលើទី៥ (១៩៦៧) បានលើកឡើងថា អំណានឬអានគឺជាការមើលថាតាមអក្សរ មានដូចជាអានបាលី និងសំបុត្រជាដើម។

យោងតាមអត្ថបទវេបសាយ CAMHR (2020) ស្តីពីអត្ថប្រយោជន៍ ១០យ៉ាងនៃការអានសៀវភៅ បានលើកឡើងថា អំណានគឺជាការបង្កើតសមត្ថភាពខួរក្បាល កាត់បន្ថយជំងឺថប់អារម្មណ៍ បង្កើនចំណេះដឹងផ្នែកវាក្យស័ព្ទ មានជំនាញគិត និងវិភាគស៊ីជម្រៅ បង្កើនការចងចាំ បង្កើនសមត្ថភាពក្នុងការផ្តោតឬផ្ចង់អារម្មណ៍ មានជំនាញក្នុងការសរសេរជាការកម្សាន្តនិងធ្វើឱ្យមនុស្សមានអារម្មណ៍ស្ងប់។

សរុបសេចក្តីមក អំណានគឺជាការមើលអក្សរ ដែលមានដូចជាអានសំបុត្រ អានបាលី ដែលអាចធ្វើឱ្យមនុស្សមានការគិតដើម្បីបង្កើនសមត្ថភាពខួរក្បាល កាត់បន្ថយជំងឺធុញថប់ បង្កើនចំណេះដឹងថ្មីៗ មានការវិភាគស៊ីជម្រៅ បង្កើនការចងចាំ បង្កើនសមត្ថភាពក្នុងការផ្ចង់អារម្មណ៍ ជំនួយដល់ជំនាញក្នុងការសរសេរ ហើយវាក៏ជាការកម្សាន្តមួយ ដែលជួយឱ្យមនុស្សមានអារម្មណ៍ស្ងប់ និងមានអាយុវែង។

### ២.២.២. ការវាយតម្លៃ

យោងតាមឯកសាររបស់អង្គការ CONCERN(2003) បានលើកឡើងថា ការវាយតម្លៃគឺជាការសិក្សាវិភាគ ហើយរកឱ្យឃើញនូវទំនាក់ទំនងរបស់ដំណើរការគម្រោង ដែលរៀបចំឡើងដើម្បីប៉ាន់ប្រមាណថាតើកម្មវិធីឬសកម្មភាពនោះកំពុងតែមានដំណើរការយ៉ាងសកម្មតាមអ្វីដែលយើងបានរៀបចំឡើងហើយអាចកែប្រែបានដើម្បីឱ្យមានប្រសិទ្ធភាពនៃគម្រោងសេចក្តីត្រូវការកម្រិតជោគជ័យ និងប្រសិទ្ធភាពនៃគម្រោង។

យោងតាមសៀវភៅណែនាំស្តីអំពីការវាយតម្លៃការបណ្តុះបណ្តាល របស់គម្រោងកែលម្អមូលដ្ឋាននៅកម្ពុជា(២០០៧) បានឱ្យនិយមន័យថា ការវាយតម្លៃគឺជាការប៉ាន់ប្រមាណដែលមានលក្ខណៈជាប្រព័ន្ធ និងជាគោលដៅលើគម្រោងដែលបានកំពុងបន្តឬគម្រោងដែលបានបញ្ចប់លើកម្មវិធី ឬគោលនយោបាយ លើការបង្កើតគម្រោង ការអនុវត្តគម្រោង និងលទ្ធផលនានារបស់គម្រោង។ គោលបំណងនៃការវាយតម្លៃគឺកំណត់លើភាពជាប់ទាក់ទង និងផលសម្រេចបានលើ គោលបំណង ការអភិវឌ្ឍ ប្រសិទ្ធភាព ផលប៉ះពាល់ និងស្ថេរភាព។

យោងតាម Patton (2002) បានឱ្យនិយមន័យថា ការវាយតម្លៃគឺជាការប្រមូលព័ត៌មានដែលមានលក្ខណៈជាប្រព័ន្ធពីសកម្មភាព ចរិកលក្ខណៈ និងទិន្នផលរបស់កម្មវិធីដើម្បីធ្វើការកែតម្រូវកម្មវិធី បង្កើនប្រសិទ្ធភាពកម្មវិធី និង/ឬ ផ្តល់ព័ត៌មានសម្រាប់ធ្វើសេចក្តីសម្រេចចិត្តលើកម្មវិធីនាពេលអនាគត។

យោងតាមការសែត The Glossary of Education Reform(2015) បានឱ្យនិយមន័យថា ការវាយតម្លៃ គឺជាពាក្យសំដៅទៅលើវិធីសាស្ត្រឬឧបករណ៍ផ្សេងៗគ្នាជាច្រើនដែលអ្នកអប់រំប្រើដើម្បីវាយតម្លៃ វាស់និងចងក្រងឯកសារត្រៀមការសិក្សាវឌ្ឍនភាពនៃការរៀនសូត្រការទទួលបានជំនាញឬតម្រូវការសិក្សារបស់សិស្ស។

សរុបមកការវាយតម្លៃគឺជាដំណើរការក្នុងការសិក្សាវិភាគ ហើយរកឱ្យឃើញនូវទំនាក់ទំនងរបស់ដំណើរការគម្រោង ដែលរៀបចំឡើងដើម្បីប៉ាន់ប្រមាណថាតើកម្មវិធីឬសកម្មភាពនោះកំពុងតែមានដំណើរការយ៉ាងសកម្មតាមអ្វីដែល យើងបានរៀបចំឡើង ហើយថាអាចកែប្រែបានដើម្បីឱ្យមានប្រសិទ្ធភាព នៃគម្រោង សេចក្ដីត្រូវការ កម្រិតជោគជ័យ និងប្រសិទ្ធភាពនៃគម្រោង។ ការវាយតម្លៃគឺជាការប៉ាន់ប្រមាណដែលមានលក្ខណៈជាប្រព័ន្ធ និងជាគោលដៅលើគម្រោងដែលបានកំពុងបន្តឬគម្រោងដែលបានបញ្ចប់លើកម្មវិធី ឬគោលនយោបាយ លើការបង្កើតគម្រោង ការអនុវត្តគម្រោង និងលទ្ធផលនានារបស់គម្រោង។ គោលបំណងនៃការវាយតម្លៃគឺកំណត់លើភាពជាប់ទាក់ទង និងផលសម្រេចបានលើ គោលបំណង ការអភិវឌ្ឍ ប្រសិទ្ធភាព ផលប៉ះពាល់ និងស្ថេរភាព។ ការវាយតម្លៃគឺជាការប្រមូលព័ត៌មានដែលមានលក្ខណៈជាប្រព័ន្ធពីសកម្មភាព ចរិកលក្ខណៈ និងទិន្នផលរបស់កម្មវិធីដើម្បីធ្វើការកែតម្រូវកម្មវិធី បង្កើនប្រសិទ្ធភាពកម្មវិធី និង/ឬ ផ្ដល់ព័ត៌មានសម្រាប់ធ្វើសេចក្ដីសម្រេចចិត្តលើកម្មវិធីនាពេលអនាគត។

## ២.៣ ការវាយតម្លៃទៅលើការបង្រៀនរបស់គ្រូ

យោងតាមសៀវភៅតេស្តវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស(២០១៥) បានលើកឡើងថា ការវាយតម្លៃសំដៅទៅដល់វិធីសាស្ត្រ និងនីតិវិធីដែលផ្ដល់ជាព័ត៌មានដល់អ្នកប្រើប្រាស់សំខាន់ៗ មានដូចជាគ្រូបង្រៀន បុគ្គលិករដ្ឋបាល អ្នកបង្កើតគោលនយោបាយ សិស្ស និងគ្រួសាររបស់ពួកគេស្ដីពីការសិក្សារបស់សិស្ស។ ជំនាញអំណានរបស់សិស្សគួរតែត្រូវបានត្រួតពិនិត្យធៀបនឹងបទដ្ឋាន និងវឌ្ឍនភាព មាតិកា និងវិធីសាស្ត្រនៃការណែនាំដែលគួរត្រូវបានកំណត់ដោយសមស្រប។ ប្រព័ន្ធវាយតម្លៃសិស្សមានសារប្រយោជន៍ នៅពេលព័ត៌មានបច្ចេកទេសមានលក្ខណៈសមស្របត្រូវបានផ្សាយ។ ការវាយតម្លៃអាចត្រូវបានអនុវត្តតាមរយៈការកំណត់តាមកត្តាផ្សេងៗ ដែលអាចជះឥទ្ធិពលជាអវិជ្ជមានលើលទ្ធផលសិក្សាក្នុងប្រទេស

កំពុងអភិវឌ្ឍន៍ដូចជា ការពន្យាពេលការអភិវឌ្ឍន៍ ម៉ោងបង្រៀនមានកម្រិត ការអនុវត្តមានតិច គរុកោសល្យមិនសមស្រប និងឧបសគ្គផ្នែកភាសា(ភាពស្មុគស្មាញនៃការប្រកបពាក្យ)។ កត្តាទាំងនេះអាចនឹងបង្កឱ្យជំនាញអំណានមានកម្រិតទាបពីថ្នាក់ទី១ ដល់ថ្នាក់ទី៣។ ចំណុចទាំងនេះ នឹងបង្កជាផលវិបាកក្នុងការដោះស្រាយលំហាត់គណិតវិទ្យាពីថ្នាក់ទី៣ ដល់ថ្នាក់ទី៦ ហើយនឹងធ្វើឱ្យទទួលបានពិន្ទុលើការវាយតម្លៃក្នុងតំបន់ និងថ្នាក់ជាតិ ឬការវាយតម្លៃថ្នាក់ជាតិដូចជា កម្មវិធីវាយតម្លៃសិស្សកម្រិតអន្តរជាតិ (PISA) និងនិន្នាការក្នុងការសិក្សាលើគណិតវិទ្យា និងវិទ្យាសាស្ត្រអន្តរជាតិ (TIMSS) ក្នុងរយៈពេលខ្លី ជំនាញមូលដ្ឋានទាបនៅពេលបញ្ចប់ការសិក្សា ព្រមទាំងចំណូល និងគុណភាពជីវិតទាមទាររយៈពេលវែង។ ចំណុចគោល និងការវាយតម្លៃលើចំណុចគោលគឺមានចំណុចគន្លឹះនៃការធ្វើផែនការ និងទម្រង់វិស័យអប់រំសំដៅការពង្រឹងគុណភាពអប់រំ។ ការវាយតម្លៃផ្នែកអប់រំមានបីប្រភេទ៖ (១) គ្រូបង្រៀនអនុវត្តការវាយតម្លៃក្នុងថ្នាក់រៀនរបស់ខ្លួនដើម្បីត្រួតពិនិត្យវឌ្ឍភាពរបស់សិស្ស(២) ប្រព័ន្ធអប់រំរៀបចំការប្រឡងសម្រាប់មុខនាទីនៃការជ្រើសរើស ឬការបញ្ជាក់ ដូចជាការប្រឡងជាប់ថ្នាក់មធ្យមសិក្សា ឬបន្តការសិក្សានៅថ្នាក់ឧត្តមសិក្សា(៣) ការវាយតម្លៃលើសំណាកជាច្រើនត្រូវបានអនុវត្ត ជាទូទៅក្នុងក្របខ័ណ្ឌសាលារៀន ដែលមានវិធីសាស្ត្រមួយក្នុងការអនុវត្តការវិភាគលើប្រព័ន្ធដោយសង្កត់ធ្ងន់ទៅលើការវិភាគនិងគោលនយោបាយ។ ពិន្ទុគឺជាចំណុចកណ្តាលនៃការវាយតម្លៃទាំងអស់ ហើយពិន្ទុទាំងនេះគឺជាលទ្ធផលដែលទទួលបានការយកចិត្តទុកដាក់ខ្លាំងបំផុត ដោយប្រព័ន្ធគោលបំណងនៃការវាយតម្លៃ។ ពេលខ្លះពិន្ទុបានបង្វែរការយកចិត្តទុកដាក់របស់សិស្ស និងសាលាទៅលើការទទួលបានលទ្ធផលប្រឡងដែលល្អទៅវិញ ដោយកាត់បន្ថយក្នុងការទទួលជំនាញផ្សេងៗលើផ្នែកសិក្សាដែលសំខាន់ៗ ដូច្នេះការវាយតម្លៃគួរត្រូវបានប្រើប្រាស់ដើម្បីទទួលបានព័ត៌មានស្តីពីសមិទ្ធិផលនៃ ប្រព័ន្ធអប់រំទាំងមូលសម្រាប់ការធ្វើផែនការ និងកំណែទម្រង់ផ្អែកលើភស្តុតាង ហើយប្រព័ន្ធទាំងនេះមិនគួរផ្អែកតែទៅលើការវាយតម្លៃតែមួយទម្រង់នោះទេ ដូចជាការប្រឡងថ្នាក់ជាតិជាដើម។ ក្របខ័ណ្ឌគតិយុត្តិក្នុងការអនុវត្តការវាយតម្លៃក្នុងប្រទេសកម្ពុជា ស្ថិតនៅក្នុងច្បាប់ស្តីពីការអប់រំ ជាពិសេសក្នុងមាត្រាទី២១ ស្តីពីគុណភាព និងប្រសិទ្ធផលនៃការអប់រំនិងមាត្រា២២ស្តីពីយន្តការនៃការធានាគុណភាព។ នៅឆ្នាំ២០០៥ និង ២០១០ ក្រោមការសម្របសម្រួលរបស់ធនាគារពិភពលោក គម្រោងគាំទ្រ

វិស័យអប់រំនៅកម្ពុជា តេស្តវាយតម្លៃថ្នាក់ជាតិត្រូវបានអនុវត្តសម្រាប់សម្រាប់ថ្នាក់ទី៣ថ្នាក់ទី៦និងថ្នាក់ទី៩។ ការវាយតម្លៃអំណានកម្រិតដំបូង (EGRA) និងការវាយតម្លៃគណិតវិទ្យាកម្រិតដំបូង (EGMA) ក៏ត្រូវបានលើកឡើងជាវិធីសាស្រ្តសំខាន់ក្នុងការជំរុញគុណភាពអប់រំនៅកម្ពុជាផងដែរ។

យោងតាមសៀវភៅក្របខណ្ឌវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សកម្រិតមត្តេយ្យ និងអប់រំចំណេះទូទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា (២០១៨) បានលើកឡើងថា វង្វាយតម្លៃការអប់រំត្រូវបានប្រើប្រាស់តាមមធ្យោបាយផ្សេងៗក្នុងគោលបំណងខុសៗគ្នានៅក្នុងប្រទេសកម្ពុជា។ តាំងពីដើមមកគ្រូបង្រៀនបានប្រើប្រាស់វង្វាយតម្លៃជាមធ្យោបាយដើម្បីវាស់ស្ទង់លទ្ធផលសិក្សារបស់សិស្ស។ ឧទាហរណ៍ គ្រូប្រើប្រាស់ការវង្វាយតម្លៃប្រចាំខែ ឬប្រចាំឆមាស ដើម្បីកំណត់ថាតើ សិស្សរបស់ខ្លួនសម្រេចបានតាមលទ្ធផលសិក្សាដែលបានកំណត់ដែរឬទេ ហើយថាតើ សិស្សទាំងនោះគួរឱ្យឡើងទៅថ្នាក់(ឬកម្រិត) បន្ទាប់ដែរឬទេ។ ជាធម្មតា ក្រសួងអប់រំ យុវជន និងកីឡា បានប្រើប្រាស់ការប្រឡងថ្នាក់ជាតិ ដើម្បីវាយតម្លៃឱ្យសិស្សឆ្លងភូមិសិក្សា ដូចជាការប្រឡងថ្នាក់ទី៩ និងការប្រឡងថ្នាក់ជាតិថ្នាក់ទី១២ ដែលត្រូវបានប្រើប្រាស់ដើម្បីធ្វើតេស្តសិស្សសម្រាប់ការឡើងថ្នាក់ពីបឋមសិក្សាទៅអនុវិទ្យាល័យ ពីអនុវិទ្យាល័យទៅវិទ្យាល័យ និងពីវិទ្យាល័យទៅឧត្តមសិក្សា។ ថ្វីត្បិតតែមនុស្សទូទៅស្គាល់ដំណើរការ និងវង្វាយតម្លៃទាំងនេះតាមប្រព័ន្ធអប់រំក្តី(ឧទាហរណ៍ គ្រូ សិស្ស ភាគីពាក់ព័ន្ធ។ល។) ប៉ុន្តែមានការវង្វាយតម្លៃផ្សេងៗទៀត ដែលពុំត្រូវបានយល់ដឹងទូលំទូលាយនៅឡើយទេ។ ចាប់តាំងពីការស្តារឡើងវិញនូវប្រព័ន្ធអប់រំឆ្នាំ១៩៧៩ រហូតមកដល់ឆ្នាំ ២០០០ ការវង្វាយតម្លៃទ្រង់ទ្រាយធំ មិនទាន់មាននៅឡើយនៅក្នុងប្រព័ន្ធអប់រំនៅកម្ពុជា។ ជំនួសមកវិញប្រព័ន្ធអប់រំសម្បូរទៅដោយវង្វាយតម្លៃ "ទ្រង់ទ្រាយតូច" (ដែលជាទូទៅត្រូវបានស្គាល់ជា វង្វាយតម្លៃកម្រិតសាលារៀន និងថ្នាក់រៀន) ដូចបានរៀបរាប់ខាងលើ។ នៅឆ្នាំ២០០៥ ក្រសួងអប់រំ យុវជន និងកីឡា បានផ្តួចផ្តើមឱ្យមានវង្វាយតម្លៃសិស្សថ្នាក់ជាតិ ដោយមានការគាំទ្រពីធនាគារពិភពលោក។ ជាលទ្ធផល វង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សថ្នាក់ជាតិ ថ្នាក់ទី៣ ទី៦ និងទី៨ ត្រូវបានអនុវត្តជាផ្លូវការចាប់តាំងពីឆ្នាំ ២០០៧ ចំណែកវង្វាយតម្លៃថ្នាក់ជាតិថ្នាក់ទី១១ ត្រូវបានអនុវត្តសាកល្បងជាផ្លូវការនៅក្នុងឆ្នាំ២០១៨។ ហើយកាលពីពេលថ្មីៗនេះ ប្រទេសកម្ពុជាបានចូលរួមនៅក្នុងវង្វាយតម្លៃទ្រង់ទ្រាយធំកម្រិតអន្តរជាតិ និង

តំបន់ថែមទៀត (PISA-D នៅឆ្នាំ ២០១៦ និង SEA-PLM នៅឆ្នាំ ២០១៥)។ ជាលទ្ធផលប្រព័ន្ធអប់រំនៅកម្ពុជាអនុវត្តនូវវង្វាយតម្លៃចម្រុះជាច្រើនសម្រាប់ពិនិត្យមើលការសិក្សារបស់សិស្ស។ តែជាអកុសល គោលបំណង និងភាពពាក់ព័ន្ធនៃការវង្វាយតម្លៃទាំងអស់នេះជារឿយៗ មិនត្រូវបានស្វែងយល់ច្បាស់លាស់ដោយអ្នកអនុវត្ត និងអ្នកអប់រំឡើយ។ ដូច្នេះ ក្រសួងអប់រំ យុវជន និងកីឡា បានសម្រេចអភិវឌ្ឍក្របខ័ណ្ឌមួយដែលមានប្រសិទ្ធភាព និងអាចយកទៅអនុវត្តបានសម្រាប់ប្រទេសទាំងមូល ដើម្បីសង្ខេបនិងធ្វើសុខដុមនីយកម្មលើដំណើរការវង្វាយតម្លៃដែលខុសៗគ្នាទាំងអស់នេះ។ ហេតុអ្វីត្រូវធ្វើវង្វាយតម្លៃ? គោលដៅចុងក្រោយបំផុតនៃការវង្វាយតម្លៃនៅក្នុងប្រព័ន្ធអប់រំ គឺដើម្បីផ្តល់ជាមធ្យោបាយមួយសម្រាប់ស្វែងយល់និងកែលម្អលទ្ធផលសិក្សារបស់សិស្ស។ ជាទូទៅ វង្វាយតម្លៃ អាចវិនិច្ឆ័យលើ គុណភាព ប្រសិទ្ធភាព គុណតម្លៃ និងតម្លៃរបស់ប្រព័ន្ធ កម្មវិធី ផលិតផល និងការអនុវត្តផ្សេងៗបាន។ តាមរយៈវង្វាយតម្លៃ យើងក៏អាចរកឃើញពីលទ្ធផលសិក្សា និងឥរិយាបថផ្សេងៗថែមទៀតផង(ឧទាហរណ៍ ការយល់ដឹងពីខ្លឹមសារ ជំនាញ អក្ខរភាព លេខនព្វន្ត ជំនាញត្រិះរិះ។ល។)។ ដូច្នេះការវង្វាយតម្លៃមានសារៈសំខាន់ចំពោះភាពជោគជ័យរបស់ប្រព័ន្ធអប់រំ ពីព្រោះវង្វាយតម្លៃអាចជួយដល់អ្នកអប់រំ និងភាគីពាក់ព័ន្ធមានការសម្រេចចិត្តលើប្រព័ន្ធ កម្មវិធី ផលិតផល ឬការអនុវត្តទាំងនោះបាន។ តែទោះជាយ៉ាងណាក៏ដោយ វង្វាយតម្លៃចាំបាច់ត្រូវតែអនុវត្តឱ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាព។

## ២.៤ ទ្រឹស្តីពីការបង្រៀនអំណាន

យោងតាម សៀវភៅណែនាំសម្រាប់គ្រូបង្រៀនថ្នាក់ទី១(២០២០) បានលើកឡើងថា ដើម្បីឱ្យដំណើរការនៃការសិក្សាមុខវិជ្ជាភាសាខ្មែរមានប្រសិទ្ធភាព អ្នកសិក្សាត្រូវសិក្សាលើសមត្ថភាព៤ នៃការរៀនភាសារួមមាន បំណិននិយាយ បំណិនស្តាប់ បំណិនអាន និងបំណិនសរសេរ ដែលបំណិនទាំង៤មានទំនាក់ទំនងគ្នាទៅវិញទៅមក។ បំណិននិយាយនិងស្តាប់គាំទ្រដល់បំណិនអាន និងសរសេរ ហើយគ្រប់សកម្មភាពអាន និងសរសេរ ក៏ត្រូវការការនិយាយ និងការស្តាប់ផងដែរ។ ការសរសេរជួយដល់ការអាន ហើយ បញ្ច្រាស់មកវិញ ការអានក៏ជួយដល់ការសរសេរផងដែរ។ ដូច្នេះ ការបញ្ជ្រាប ឬបញ្ចូលបំណិនទាំង៤ ចូលគ្នាក្នុងដំណើរការបង្រៀនភាសាធ្វើឱ្យមេរៀនកាន់តែមានប្រសិទ្ធភាពខ្ពស់។ សមាសភាគទាំង៥

នៃអំណាន(និងសំណេរ) បានជួយសិស្សឱ្យទទួលបានខ្លឹមសារមេរៀន ក្នុងសៀវភៅសិក្សាគោល ដែលត្រូវបានប្រមូលផ្តុំសម្រាប់មេរៀនណាមួយហៅថា កម្រិតស្តង់ដា។ ដើម្បីឱ្យកម្រិតស្តង់ដាអំណាន(និងសរសេរ) មានប្រសិទ្ធភាព គ្រូបង្រៀនត្រូវដឹងអំពីសមាសភាគគន្លឹះទាំង៥ ដែលឆ្លុះបញ្ចាំងកម្រិតស្តង់ដានីមួយៗ។ ការកត់សម្គាល់សមាសភាគទាំងនោះ ត្រូវបានយោងតាមការស្រាវជ្រាវអន្តរជាតិ ដែលត្រូវបានទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា។ និយមន័យនៃសមាសភាគទាំង៥នោះមានដូចតទៅៈសមាសភាគទី១ ការស្គាល់សូរ គឺសំដៅលើការបង្រៀន ដើម្បីជួយសិស្សឱ្យមានសមត្ថភាពក្នុងការកំណត់ ប្រើប្រាស់ និងញែកសូរ ក្នុងភាសានិយាយ។ ការស្គាល់សូរគឺបង្រៀនដោយផ្ទាល់មាត់ និងស្តាប់ តែគ្មានការសរសេរទេ។ សមាសភាគទី២ ការស្គាល់តួអក្សរថ្មី គឺសំដៅដល់ការបង្រៀនដែលជួយសិស្សអាន និងអនុវត្តចំណេះដឹងស្តីពីទំនាក់ទំនងរវាងតួអក្សរនិងសូរ។ បំណិននេះមានសារៈសំខាន់ណាស់ឱ្យសិស្សចេះប្រកបអក្សរហើយអានព្យាង្គឬពាក្យក្នុងភាសាខ្មែរបានត្រឹមត្រូវ។ សមាសភាគទី៣ ការចេះវាក្យសព្ទគឺសំដៅលើការបង្រៀន ដើម្បីឱ្យសិស្សមានចំណេះដឹងស្តីពីពាក្យ ជាការយល់ន័យនៃពាក្យថ្មី និងដឹងពីរបៀបប្រើប្រាស់ពាក្យនោះ តាមរយៈការបង្កើតល្បះខ្លីៗ ឬយល់ន័យពាក្យពិបាកតាមរយៈការអានអត្ថបទណាមួយ។ សិស្សរៀនពាក្យថ្មីបានប្រសើរកាលណាគ្រូបង្រៀនប្រាប់អំពីនិយមន័យនៃពាក្យទាំងនោះដោយប្រើភាសាសាមញ្ញ ងាយៗ ដែលធ្វើសិស្សងាយយល់ហើយហាត់តែងល្បះដោយប្រើពាក្យនោះបាន។សមាសភាគទី៤ ការចេះអានស្ទាត់ គឺសំដៅលើការបង្រៀន ដែលជួយពង្រឹងសមត្ថភាពអានបានត្រឹមត្រូវក្នុងល្បឿនសមស្របនិងមានការលើកដាក់សំឡេង ប្រសិនបើសិស្ស អានយឺតពេកហើយរវល់តែប្រកបពាក្យនីមួយៗគេនឹងភ្លេចន័យពាក្យនោះនៅពេលអានល្បះចប់។ សមាសភាគទី៥ ការអានដើម្បីយល់ន័យគឺសំដៅលើការបង្រៀនដែលឱ្យសិស្សមានសមត្ថភាពចូលរួមបញ្ចេញន័យដោយប្រើពាក្យសម្តីផ្ទាល់ខ្លួនពីអត្ថបទដែលបានអាន។ វាជាការយល់ន័យនៃអត្ថបទទាំងមូលបន្ទាប់ពីកុមារបានអានអត្ថបទនោះរួច។

យោងតាម សៀវភៅកម្មវិធីសិក្សាលម្អិតមុខវិជ្ជាភាសាខ្មែរកម្រិតបឋមសិក្សា(២០១៨)បានលើកឡើងថា ដើម្បីធានាបានការបង្រៀនអំណានប្រកបដោយប្រសិទ្ធភាព គ្រូបង្រៀនគប្បីមានវិធីសាស្ត្របង្រៀនសម្បូរបែបស្របតាមសមត្ថភាពសិក្សារបស់សិស្ស ពោលគឺមិនបង្រៀនត្រឹមតែឱ្យសិស្សថាតាមឬ

ឱ្យសិស្សទន្ទេញចាំមាត់តាមគ្រូឡើយ គ្រូត្រូវផ្តល់ភាពជាគំរូនៃការអានដល់សិស្ស ដោយអានឱ្យសិស្សស្តាប់ជាគំរូជាមុន បន្ទាប់មកនាំសិស្សអានជាមួយគ្នា ចុងក្រោយឱ្យសិស្សអនុវត្តការអានដោយខ្លួនឯងជាដៃគូ ឬបុគ្គល ការធ្វើបែបនេះអាចធានាបានប្រសិទ្ធផលនៃការរៀន និងបង្រៀនអំណាននៅកម្រិតបឋមសិក្សា។

## ២.៥ ទ្រឹស្តីពីបញ្ហាប្រឈម លើការបង្រៀនអំណាន

យោងតាម សៀវភៅអំណានជាអំណាច(២០១៩) បានលើកឡើងថា ចំណេះដឹងដែលយើងមានក្រោយពីបានសិក្សារៀនសូត្រជាពិសេសបានមកពីការអានសៀវភៅក៏មានតួនាទីធ្វើការទៅតាមផ្នែករៀងៗខ្លួនដែរ។ ចំណេះដឹងដែលបានមកពីការអានខ្លះគឺយើងមិនអាចប្រើពេលភ្លាមៗបានទេ តែអាចប្រើបាននៅពេលក្រោយ។ បើកាលៈទេសៈមិនទាន់មកដល់ ចំណេះដឹងដែលបានមកពីការអានខ្លះ គឺមើលទៅប្រៀបដូចជាឥតប្រយោជន៍ តែដល់ពេលណាមានបញ្ហាមកដល់ទើបយើងអាចយកវាមកអនុវត្តកើត។ ថ្វីត្បិតតែការមានចំណេះដឹងចេញពីអំណាន គឺវាគ្រាន់តែទុកសម្រាប់ឱ្យយើងបង្ការបញ្ហាប៉ុណ្ណោះ។ ពេលណាបញ្ហាមកដល់ចំណេះដឹងនោះត្រូវបានប្រើប្រៀបដូចជាភាពងងឹតមកដល់ព្រះចន្ទក៏រះមកឱ្យយើងឃើញផងដែរ។ ជីវិតគឺជាការរៀនសូត្រពេញមួយជីវិត តែមិនប្រាកដថាអ្វីៗដែលយើងរៀនអាចយកទៅប្រើបានទាំងអស់នោះទេ។ មនុស្សខ្លាំងចាប់កំណើតចេញពីបញ្ហា។ អ្នកដែលមនុស្សទូទៅហៅថាសេដ្ឋី គឺកើតចេញពីការលំបាកនិងការប្រឹងប្រែងពីបាតដៃទទេ។ អ្នកអានគឺត្រូវយកចំណេះដឹងមកសាបព្រួស តាមរយៈការធ្វើគំរូដល់មនុស្សដទៃ ឬដល់អ្នកជំនាន់ក្រោយ។ អ្នកអានត្រូវយកចំណេះដឹងមកដុះខាត់ខ្លួនឯងឱ្យក្លាយទៅជាមនុស្សពេញលេញ។ អ្នកអានមិនចាំបាច់ធ្វើអ្វីច្រើនក៏បានដែរតែសំខាន់ត្រូវរស់នៅក្នុងនាមជាមនុស្សមានសីលធម៌ មានមេត្តាធម៌ ចេះយកចំណេះរកសេចក្តីសុខឱ្យខ្លួនដោយវិធីសុចរិត ក៏ល្មមចាត់ទុកថាបានអនុវត្តចំណេះដឹងអំណានទៅហើយ។

យោងតាមអត្ថបទ ទស្សនៈព្រឹត្តិការណ៍ខ្មែរ(០៩ មករា ២០១៣) បានលើកឡើងថាការសិក្សាមានសារៈសំខាន់ណាស់ ប្រទេសមួយមិនអាចពឹងលើធនធានមនុស្សគ្មានគុណភាពបានទេ។ មានមូលហេតុជាច្រើនដែលបណ្តាលឱ្យការបណ្តុះបណ្តាលធនធានមនុស្សនៅកម្ពុជាមិនសូវមានគុណភាព។ មូលហេតុសំខាន់ជាងគេគឺប្រពន្ធ័អប់រំដែលមិនអាចផ្តល់គ្រឹះរឹងមាំដល់សិស្ស។ ទម្លាប់នៃការបង្រៀននិងការរៀនជា

ពិសេសចាប់ពីថ្នាក់បឋមដល់វិទ្យាល័យមិនអំណោយផលទាល់តែសោះដល់ការសរសេរ និងការជជែកវែកញែករបស់សិស្ស។ ក្នុងប្រពន្ធ័អប់រំកម្ពុជា ជាទូទៅសិស្សអង្គុយចាំតែស្តាប់គ្រូ ចំណែកឯគ្រូវិញចូលចិត្តនិយាយឲ្យសិស្សស្តាប់ច្រើនជាង ឱ្យសិស្សបង្កើតគំនិត ជជែកពិភាក្សាគ្នា និងសរសេរឲ្យបានច្រើន។ ទម្លាប់នេះបានធ្វើឱ្យសិស្សបាត់បង់ឱកាសក្នុងការសរសេរ ឬក្នុងការពិចារណា និងស្រាវជ្រាវដើម្បីបង្កើនធនធានបញ្ញារបស់ខ្លួន។ និយាយពីវិស័យអប់រំកម្ពុជា មានកត្តាច្រើនយ៉ាងប្រទាក់ក្រឡាគ្នាដែលធ្វើឱ្យធនធានមនុស្សនៅទន់ខ្សោយ។ កត្តាគ្រូ កត្តាសិស្ស កត្តាឪពុកម្តាយ ទម្លាប់មិនចូលចិត្តអាន រួមផ្សំនឹងនិន្នាការសង្គមដែលផ្តល់តម្លៃលើប្រាក់និងសម្ភារៈជាងមនសិការនិងចំណេះវិជ្ជា សុទ្ធតែជាឧបសគ្គដែលធ្វើឱ្យក្រិនបញ្ញាស្មារតីរបស់យុវវ័យខ្មែរ។ ជីវភាពខ្វះខាតមិនអនុញ្ញាតឱ្យគ្រូបង្រៀនថ្នាក់ក្រោមបំពេញតួនាទីរបស់ខ្លួនបានល្អឡើយ។ ចំណែកឯសិស្សវិញក៏ហាក់ដូចជាមិនសូវមានការតាំងចិត្តខំរៀនប៉ុន្មានដែរ តែពួកគេភាគច្រើនត្រូវបានអូសទាញដោយនិន្នាការសម្ភារៈនិយម និងការសប្បាយភ្លើតភ្លើនទៅតាមវប្បធម៌មិនល្អមួយចំនួនដែលហូរចូលពីបរទេស។

## ២.៦ តួនាទីរបស់គ្រូបង្រៀនក្នុងសតវត្សទី២១

យោងតាមអត្ថបទ ការរៀននិងបង្រៀនក្នុងបរិបទថ្មី(២០១៩) បានលើកឡើងថាក្នុងសតវត្សទី២១ បច្ចេកវិទ្យាមានការរីកចម្រើនយ៉ាងឆាប់រហ័ស ហើយស្ទើរតែគ្រប់គ្នា ជាពិសេសសិស្សានុសិស្សអាចស្វែងរកព័ត៌មាន និងចំណេះដឹងបានគ្រប់យ៉ាង គ្រប់ពេលវេលា និងគ្រប់ទីកន្លែងតាមរយៈអ៊ីនធឺណែត (internet) តាមប្រព័ន្ធបណ្តាញសង្គមដ៏សម្បូរបែបនានា។ នៅពេលដែលប្រព័ន្ធបច្ចេកវិទ្យាអាចផ្តល់ចំណេះដឹងដ៏សម្បូរបែបនេះ តើលោកគ្រូគួរតែបន្តតួនាទីជាប្រភពព័ត៌មានតែម្យ៉ាងដល់សិស្សានុសិស្សឬយ៉ាងណា? កាលពីអតីតកាលប្រភពព័ត៌មានមិនមានច្រើន និងមិនមានលក្ខណៈទូលំទូលាយនេះទេ ក្រៅពីគម្ពីនិងក្បួនច្បាប់នានា ចាស់ព្រឹទ្ធាចារ្យ ជាពិសេសគ្រូជាប្រភពព័ត៌មានសម្រាប់អ្នករៀនភាគច្រើន។ ការរៀនប្រព្រឹត្តទៅតាមគោលវិធីគ្រូមជ្ឈមណ្ឌល ដែលទាមទាឱ្យសិស្សស្តាប់ ចង់ចាំ ទន្ទេញនិងសូត្រដើម្បីផ្តល់ចម្លើយជាក់លាក់ណាមួយដែលអ្នកផ្តល់ការអប់រំរំពឹងទុក។ បច្ចុប្បន្នការរៀនតាមគ្រូមជ្ឈមណ្ឌលមិនអាចឆ្លើយតបទាំងស្រុងទៅនឹងតម្រូវការរបស់សង្គមសម័យទំនើបនេះបានទៀតទេ ព្រោះព័ត៌មាន និងទិន្នន័យ

គ្រប់ប្រភេទត្រូវបានចែករំលែកយ៉ាងឆាប់រហ័ស ពិភពលោកមានការវិវត្តលឿនជាងមុន ទីផ្សារការងារមានការប្រកួតប្រជែងខ្ពស់ ព្រមទាំងទាមទារជំនាញ និងសមត្ថភាពសម្បូរបែបក្នុងការបំពេញតម្រូវការការងារដែលកើតឡើងថ្មីៗ។ ដូច្នេះហើយ ការរៀនតែខ្លឹមសារគឺមិនគ្រប់គ្រាន់ទេ ពាក្យថាចេះសម្រាប់បច្ចុប្បន្នមិនសំដៅទៅលើការទន្ទេញឱ្យចាំឬថាតាមនោះទេ តែត្រូវទាមទារសមត្ថភាពស្វែងរកព័ត៌មានដែលពិត ហើយល្អឱ្យបានលឿន កំណត់ វិភាគ វាយតម្លៃ និងប្រើប្រាស់ព័ត៌មានប្រកបដោយប្រសិទ្ធភាព ត្រិះរិះពិចារណាដើម្បីដោះស្រាយបញ្ហាឱ្យទាន់សភាពការ និងច្នៃប្រឌិតឱ្យឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង។ បច្ចេកវិទ្យាបាននឹងកំពុងតែផ្លាស់ប្តូរវិធីប្រាស្រ័យទាក់ទង របៀបធ្វើការ និងតម្រូវការរបស់មនុស្ស មានន័យថាការរៀននិងបង្រៀនក៏ចាំបាច់ត្រូវផ្លាស់ប្តូរដែរ។ ដើម្បីឆ្លើយតបនឹងតម្រូវការថ្មីនេះគ្រូបង្រៀនត្រូវតែធ្វើការផ្លាស់ប្តូរវិធីសាស្ត្របង្រៀន ដើម្បីរៀបចំឱ្យសិស្សមាននូវគុណសម្បទាសតវត្សទី២១ ពោលគឺបង្រៀនសិស្សឱ្យមានវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា។ វិជ្ជាសម្បទានៅក្នុងសតវត្សទី២១ គឺសំដៅការចេះអានសរសេរ គិតលេខ ភាសាបរទេស និងប្រព័ន្ធបច្ចេកវិទ្យា។ បំណិនសម្បទាគឺសំដៅទៅលើ ការចេះត្រិះរិះពិចារណា វិភាគ ច្នៃប្រឌិត ដោះស្រាយបញ្ហា និងសម្រេចចិត្តប្រកបដោយភាពឆ្លាតវៃ។ រីឯចរិយាសម្បទាគឺសំដៅទៅលើ ការចង់ចេះចង់ដឹង ចេះផ្តួចផ្តើមថ្មី មានវិន័យ ទន់ភ្លន់ សុចរិត មានស្មារតីទទួលខុសត្រូវខ្ពស់ចេះប្រាស្រ័យទាក់ទង និងសហការក្នុងការធ្វើការក្នុងស្មារតីជាក្រុមជាមួយមនុស្សដែលមានភេទ ជំនឿវប្បធម៌ និងជាតិសាសន៍ផ្សេងៗគ្នា។ លោកគ្រូ អ្នកគ្រូគួរបណ្តុះបំណិនរៀនពេញមួយជីវិតដល់សិស្សានុសិស្សផងដែរ។ គ្រូបង្រៀនអាចបណ្តុះសម្បទាសតវត្សរ៍ទី២១ តាមរយៈការប្រើគោលវិធីសិស្សមជ្ឈមណ្ឌល និងផ្តោតសំខាន់តាមវិធីសាស្ត្របង្រៀនបែបរិះរក។ គ្រូបង្រៀនគួរផ្លាស់ប្តូរពីទម្លាប់ប្រាប់សិស្សស្តីពីព័ត៌មានឬខ្លឹមមេរៀនមកជាអ្នកបង្ហឹកឬតម្រង់ទិសឱ្យចេះឆ្ងល់ ហ៊ានសួរ និងស្វែករកចម្លើយតាមរយៈការអាន សម្ភាសពិសោធ សង្កេត និងការស្រាវជ្រាវទាំងក្នុង និងក្រៅថ្នាក់ដើម្បីប្រមូលព័ត៌មានយកមកវិភាគផ្ទៀងផ្ទាត់ចម្លើយនិងសហការជាមួយមិត្តរួមថ្នាក់ដើម្បីដោះស្រាយបញ្ហា ដើម្បីបង្កើតថ្មីរួចហើយផ្សព្វផ្សាយដំណោះស្រាយនិងលទ្ធផលការងារទៅមិត្តរួមថ្នាក់ឬមនុស្សទូទៅតាមវិធីផ្សេងៗ។

## ២.៧ កម្មវិធីសិក្សានៅកម្រិតបឋមសិក្សា

យោងតាមសៀវភៅក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅនិងអប់រំបច្ចេកទេស (២០១៥) បានកំណត់និងបែងចែកប្រភេទនៃមុខវិជ្ជាសិក្សានៅកម្រិតបឋមសិក្សាដែលមានមុខវិជ្ជា ភាសាខ្មែរ គណិតវិទ្យា វិទ្យាសាស្ត្រ សិក្សាសង្គម កុំព្យូទ័រ ភាសារទេស បំណិនជីវិតមូលដ្ឋាន អរប់រំសុខភាព អប់រំការនិងកីឡា និងអប់រំសិល្បៈ។ នៅក្នុងមុខវិជ្ជានីមួយៗត្រូវបានបែងចែកជាមុខវិជ្ជារងតាមប្រភេទផ្សេងៗគ្នា។ ភាសាខ្មែរ មានមុខវិជ្ជារង៤ គឺ ការអាន ការស្តាប់ ការនិយាយ និងការសរសេរ។ គណិតវិទ្យា មានមុខវិជ្ជារង ៧ គឺ នព្វន្ត រង្វាស់រង្វាល់ ធរណីមាត្រ ស្ថិតិនិងប្រូបាប ពិជគណិត គណិតវិភាគ និងត្រីកោណមាត្រ។ វិទ្យាសាស្ត្រ មានមុខវិជ្ជារង ៤ គឺ រូបវិទ្យា គីមីវិទ្យា ផែនដីបរិស្ថានវិទ្យា និងជីវវិទ្យា។ សិក្សាសង្គម មានមុខវិជ្ជារង៥ គឺ ប្រវត្តិវិទ្យា ភូមិវិទ្យា សីលធ៌មពលរដ្ឋវិទ្យា គេហកិច្ចវិទ្យា និងអប់រំសិល្បៈ។ ក្រៅពីនេះក៏មានបន្ថែមមុខវិជ្ជា បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍(ICT) មុខវិជ្ជាភាសាបរទេស មុខវិជ្ជាអប់រំកាយនិងកីឡា មុខវិជ្ជាអប់រំសុខភាព មុខវិជ្ជាអប់រំសិល្បៈ និងមុខវិជ្ជាអប់រំបំណិនជីវិតមូលដ្ឋាន។ ម៉ោងសិក្សានៅកម្រិតបឋមសិក្សាត្រូវបានបែងចែកតាមប្រភេទនៃកម្រិតថ្នាក់រៀននីមួយៗដូចខាងក្រោម៖

*តារាង២.១ កម្មវិធីសិក្សាកម្រិតបឋមសិក្សា*

| ល.រ | មុខវិជ្ជា | កម្រិតថ្នាក់ | | | | | |
|---|---|---|---|---|---|---|---|
| | | **1** | **2** | **3** | **4** | **5** | **6** |
| 1 | ភាសាខ្មែរ | 11 | 11 | 11 | 9 | 9 | 9 |
| 2 | គណិតវិទ្យា | 7 | 7 | 7 | 6 | 6 | 6 |
| 3 | វិទ្យាសាស្ត្រ | 3 | 3 | 3 | 3 | 3 | 3 |
| 4 | កុំព្យូទ័រ | 0 | 0 | 0 | 1 | 1 | 1 |
| 5 | សិក្សាសង្គម | 3 | 3 | 3 | 3 | 3 | 3 |
| 6 | អប់រំសិល្បៈ | 1 | 1 | 1 | 1 | 1 | 1 |
| 7 | អប់រំកាយនិងកីឡា | 2 | 2 | 2 | 2 | 2 | 2 |
| 8 | អប់រំសុខភាព | 1 | 1 | 1 | 1 | 1 | 1 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 9 | ភាសាបរទេស | 2 | 2 | 2 | 2 | 2 | 2 |
| 10 | បំណិនជីវិតមូលដ្ឋាន | 0 | 0 | 0 | 2 | 2 | 2 |
| **សរុបម៉ោងសិក្សាប្រចាំសប្ដាហ៍** | | 30 | 30 | 30 | 30 | 30 | 30 |

គ្រូបង្រៀនត្រូវបង្រៀន ៣៥ សប្ដាហ៍ក្នុងមួយឆ្នាំ ៣០ ម៉ោងក្នុង១សប្ដាហ៍ ក្នុង១សប្ដាហ៍បង្រៀន ៦ ថ្ងៃ ១ ថ្ងៃបង្រៀន៥ ម៉ោងសិក្សា និងមួយម៉ោងសិក្សាមានរយៈពេល៤០នាទី។

## ២.៨ ម៉ោងសិក្សាលម្អិតលើមុខវិជ្ជាភាសាខ្មែរ

យោងតាម សៀវភៅកម្មវិធីសិក្សាលម្អិតមុខវិជ្ជាភាសាខ្មែរកម្រិតបឋមសិក្សា(២០១៨) បានបែងចែកម៉ោងសិក្សាមុខវិជ្ជាភាសាខ្មែរ កម្រិតបឋមសិក្សាមានរយៈពេល ៣៥ សប្ដាហ៍ក្នុងមួយឆ្នាំ សិក្សារយៈពេល៦ ថ្ងៃក្នុងមួយសប្ដាហ៍ ក្នុងមួយម៉ោងសិក្សាមានរយៈពេល ៤០ នាទី។ ម៉ោងសិក្សាមុខវិជ្ជាភាសាខ្មែរនៅកម្រិតបឋមសិក្សាត្រូវបានបែងចែកដូចខាងក្រោម៖

*តារាង២.២ បំណែកចែកម៉ោងសិក្សាលម្អិតមុខវិជ្ជាភាសាខ្មែរ*

| ថ្នាក់ទី | ចំនួនសប្ដាហ៍ ក្នុង១ឆ្នាំសិក្សា | ចំនួនថ្ងៃ ក្នុង១សប្ដាហ៍ | ចំនួនម៉ោង ក្នុង១សប្ដាហ៍ | ចំនួននាទី ក្នុង ១ម៉ោងសិក្សា | ចំនួនម៉ោង ក្នុង ១ឆ្នាំសិក្សា |
|---|---|---|---|---|---|
| 1 | 35 | 6 | 11 | 40 | 385 |
| 2 | 35 | 6 | 11 | 40 | 385 |
| 3 | 35 | 6 | 11 | 40 | 385 |
| 4 | 35 | 6 | 9 | 40 | 315 |
| 5 | 35 | 6 | 9 | 40 | 315 |
| 6 | 35 | 6 | 9 | 40 | 315 |

របាយម៉ោងបង្រៀនមុខវិជ្ជាភាសាខ្មែរនៅកម្រិតបឋមសិក្សាត្រូវបែងចែកទៅតាមខ្លឹមសារនៃប្រភេទខុសៗគ្នា ៤០% នៃម៉ោងសិក្សាប្រចាំឆ្នាំប្រើសម្រាប់បង្រៀនសមាសភាគនិយាយ ស្ដាប់ វេយ្យាករណ៍ និងបំណិន ៣០% បង្រៀនលើសមាសភាគអំណាន និង៣០% បង្រៀនលើសមាសភាគសរសេរ។

## ២.៩ ស្តង់ដាបង្រៀនអំណាន

យោងតាមឯកសារស្តីពី ស្តង់ដាអំណានថ្នាក់ទី១(២០១៤)បានលើកឡើងថា ស្តង់ដាអំណាន មានគោលបំណងផ្តល់បំណិនសំខាន់ៗក្នុងការរៀន និងបង្រៀនសមត្ថភាពអំណានជាក់ស្តែងដែលសិស្ស ត្រូវទទួលបានក្នុងមេរៀននីមួយៗនៃសៀវភៅសិក្សាគោល។ ស្តង់ដាអំណានសម្រាប់សិស្សថ្នាក់ទី១ ដោយផ្តោតសំខាន់ទៅនឹងប្រធានបទតាមដំណាក់កាលដែលចែកចេញជា៩ ដំណាក់កាល។ ដំណាក់កាលទី១ ស្រៈនិស្ស័យ និងព្យញ្ជនៈ ដំណាក់កាលទី២ ព្យញ្ជនៈពួកអ ផ្សំនឹងស្រៈនិស្ស័យ ដំណាក់កាលទី៣ ព្យញ្ជនៈពួកអ៊ ផ្សំនឹងស្រៈនិស្ស័យ ដំណាក់កាលទី៤ ព្យញ្ជនៈប្រើមូសិកទន្ត និងត្រីសព្ទ ដំណាក់កាលទី៥ ព្យញ្ជនៈប្រកបគ្មានបន្តក់ និងមានបន្តក់ ដំណាក់កាលទី៦ ស្រៈពេញតួ ដំណាក់កាលទី៧ ព្យញ្ជនៈ និងជើង ដំណាក់កាលទី៨ ព្យញ្ជនៈផ្ញើជើង និងដំណាក់កាលទី៩ ព្យាង្គតម្រួត។

យោងតាមឯកសារស្តីពី ស្តង់ដាអំណានថ្នាក់ទី២(២០១៤) បានលើកឡើងថា សម្រាប់ថ្នាក់ទី២ ក៏បានកំណត់ស្តង់ដាអំណានដោយផ្តោតសំខាន់ទៅនឹងប្រធានបទតាមដំណាក់កាលដែលចែកចេញជា៨ ដំណាក់កាល។ ដំណាក់កាលទី១ រំឭកស្រៈនិស្ស័យ ព្យញ្ជនៈផ្សំស្រៈ ប្រកប និងស្រៈពេញតួ ដំណាក់កាលទី២ រំឭកព្យញ្ជនៈផ្ញើជើង ដំណាក់កាលទី៣ រំឭកព្យាង្គតម្រួត ដំណាក់កាលទី៤ អំណាន និងសំណេរ ដំណាក់កាលទី៥ អំណាន និងសំណេរ ដំណាក់កាលទី៦ អំណាន និងសំណេរ ដំណាក់កាលទី៧ និង ដំណាក់កាលទី៨ អំណាន និងសំណេរ ។

យោងតាមឯកសារស្តីពី ស្តង់ដាអំណានថ្នាក់ទី៣(២០១៦) បានលើកឡើងថា ការកំណត់ស្តង់ដាអំណានដោយផ្តោតសំខាន់ទៅនឹងប្រធានបទតាមដំណាក់កាលដែលចែកចេញជា៧ ដំណាក់កាល។ ដំណាក់កាលទី១ មានចំនួន៧ មេរៀនអំណានចាប់ពីមេរៀនទី១ ដល់មេរៀនទី៧ នៃសៀវភៅសិក្សាគោល ដំណាក់កាលទី២មានចំនួន៧មេរៀនអំណានចាប់ពីមេរៀនទី៨ ដល់មេរៀនទី១៤នៃសៀវភៅសិក្សាគោល ដំណាក់កាលទី៣ មានចំនួន ៩ មេរៀន ចាប់ពីមេរៀនទី១៥ ដល់មេរៀនទី២៣ នៃសៀវភៅសិក្សាគោល ដំណាក់កាលទី៤ មានចំនួន១១ មេរៀន ចាប់ពីមេរៀនទី២៤ ដល់មេរៀនទី៣៤ នៃសៀវភៅសិក្សាគោល ដំណាក់កាលទី៥ មានចំនួន៧ មេរៀន ចាប់ពីមេរៀនទី៣៥ ដល់មេរៀនទី៤១ នៃសៀវភៅសិក្សាគោល

ដំណាក់កាលទី៦ មានចំនួន១១មេរៀនចាប់ពីមេរៀនទី៤២ដល់មេរៀនទី៥២នៃសៀវភៅសិក្សាគោល និង ដំណាក់កាលទី៧ មានចំនួន១២មេរៀនចាប់ពីមេរៀនទី៥៣ដល់មេរៀនទី៦៤នៃសៀវភៅសិក្សាគោល។

យោងតាម សៀវភៅឯកសារជំនួយគ្រូឧទ្ទេសសម្រាប់បណ្តុះបណ្តាលគរុសិស្ស និងគ្រូ ស្តីពីស្តង់ដាអំណានថ្នាក់ទី១ ទី២ និងទី៣(២០១៦) បានលើកឡើងថា សមាសភាគសំខាន់ៗនៃស្តង់ដាអំណានថ្នាក់ទី១ ទី២ និងទី៣ មាន៦ ដំណាក់កាល(១) ការកំណត់សមត្ថភាពសិស្សបង្ហាញពីសមត្ថភាពអំណានរបស់សិស្សត្រូវសម្រេចឱ្យបានក្នុងពេលសិក្សាតាមដំណាក់កាលនីមួយៗ។(២) បំណិនអំណានពាក់ព័ន្ធបង្ហាញពីបំណិនមួយក្នុងចំណោមបំណិនអំណានទាំងប្រាំដែលសិស្សត្រូវចេះរួមមាន ការស្គាល់សូរ ការស្គាល់តួអក្សរ និងសូរ ការចេះវាក្យស័ព្ទ ការអានស្ទាត់ និងការអានដើម្បីយល់ន័យ។(៣) ខ្លឹមសារ បង្ហាញពីខ្លឹមសារដែលសិស្សត្រូវរៀនតាមដំណាក់កាលនីមួយៗ ដូចជា តួអក្សរ វណ្ណយុត្ត។ល។(៤) សកម្មភាពគម្រូ ផ្តល់កិច្ចការដាក់លាក់ឆ្លើយតបទៅនឹងសមត្ថភាពសិស្ស។ បើសិស្សបំពេញកិច្ចការមួយឬច្រើនបានជោគជ័យនោះ មានន័យថា សិស្សទទួលបាននូវសមត្ថភាពអាន។(៥) ការវាយតម្លៃ(ឧបករណ៍វាយតម្លៃ) បង្ហាញពីឧបករណ៍តេស្តដែលមានក្នុងឧបសម្ព័ន្ធដែលគ្រូប្រើប្រាស់ ដើម្បីវាយតម្លៃសិស្ស។ ដោយផ្អែកលើបំណិនអំណានទាំងប្រាំ( តេស្តសំណេរ និងផ្ទាល់មាត់)។(៦) ល្បែងសិក្សា បង្ហាញអំពីល្បែងដែលគ្រូអាចប្រើប្រាស់ ដើម្បីលើកម្ពស់សមត្ថភាពសិស្សក្នុងការអាន។

## ២.១០ គន្លងអាជីពគ្រូបង្រៀន

យោងតាមសៀវភៅក្របខ័ណ្ឌគន្លងអាជីពគ្រូបង្រៀន(២០១៨) បានលើកឡើងថាដើម្បីលើកស្ទួយសិទ្ធិប្រជាពលរដ្ឋក្នុងការទទួលបានការអប់រំប្រកបដោយគុណភាពនៅគ្រប់កម្រិត ក្រសួងអប់រំ យុវជន និងកីឡាត្រូវចាត់វិធានការគ្រប់បែបយ៉ាងជាជំហានៗ ដើម្បីឱ្យការអប់រំបានទៅដល់ប្រជាពលរដ្ឋគ្រប់រូប។ វិស័យអប់រំជាមូលដ្ឋានគ្រឹះក្នុងការអភិវឌ្ឍជាតិ។ គ្រូបង្រៀនត្រូវបានចាត់ទុកជាសសរស្តម្ភក្នុងវិស័យអប់រំ។ ប៉ុន្តែនៅក្នុងក្របខ័ណ្ឌមន្ត្រីសាធារណៈទាំងក្នុងប្រទេសអភិវឌ្ឍន៍និងប្រទេសកំពុងអភិវឌ្ឍន៍ ជាទូទៅគ្រូបង្រៀនមិនសូវមានឱកាសអភិវឌ្ឍវិជ្ជាជីវៈ និងគ្មានតំណែងបន្តខ្ពស់ជាងនេះទេ ពោលគឺមានងារជាគ្រូបង្រៀនពេញមួយជីវិត។ គន្លងអាជីពគ្រូបង្រៀនត្រូវបានបង្កើតឡើងក្នុងគោលដៅពង្រឹងគុណភាពអប់រំ ពិសេសគ្រូ

បង្រៀនដើម្បីឆ្លើយតបនឹងការប្រែប្រួលសង្គម សេដ្ឋកិច្ចជាតិ អន្តរជាតិ និងដោះស្រាយក្នុងវិស័យអប់រំ។ គ្រូបង្រៀនជាមូលដ្ឋានគ្រឹះក្នុងការលើកកម្ពស់គុណភាពអប់រំ។ គុណសម្បទារបស់គ្រូបង្រៀនដើម្បីជានាប្រសិទ្ធភាពការងារ ដែលមានចែងក្នុងស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន រួមបញ្ចូលទាំងចំណេះដឹងវិជ្ជាជីវៈ ការប្រតិបត្តិវិជ្ជាជីវៈ ការសិក្សាវិជ្ជាជីវៈ និងសីលធម៌វិជ្ជាជីវៈ។ ក្របខ័ណ្ឌគន្លងអាជីពគ្រូបង្រៀនមានចក្ខុវិស័យកសាងគ្រូបង្រៀន ឱ្យមានចំណេះដឹង ជំនាញ សីលធម៌ និងមានសមត្ថភាពលើវិជ្ជាជីវៈដោយមានការទទួលស្គាល់ពីសង្គម។

ក្របខ័ណ្ឌគន្លងអាជីពគ្រូបង្រៀន ជាប្រព័ន្ធលើកទឹកចិត្តដល់គ្រូបង្រៀនក្នុងការអនុវត្តអាជីពជាគ្រូបង្រៀនដែលធានាបាននូវប្រសិទ្ធភាព។ គន្លងអាជីពគ្រូបង្រៀនត្រូវបានរៀបចំសម្រាប់គ្រូបង្រៀនដែលមានឧបនិស្ស័យបង្រៀនសិស្សក្នុងថ្នាក់រៀន។ គន្លងអាជីពគ្រូបង្រៀនត្រូវបានបែងចែកជា៣កម្រិតគឺ គ្រូបង្រៀនឈានមុខ គ្រូបង្រៀនគំរូ និងគ្រូបង្រៀនឆ្នើម។ លក្ខខណ្ឌក្នុងការកំណត់កម្រិតនៃសមត្ថភាពគ្រូបង្រៀនតាមកម្រិតនីមួយៗត្រូវបានបែងចែកយ៉ាងច្បាស់ដូចខាងក្រោម៖

១) គ្រូបង្រៀនឈានមុខ៖ មានគុណភាពការងារធ្វើឱ្យប្រសើរឡើងនូវការអនុវត្តកម្មវិធីសិក្សា ការបង្រៀន ការវាយតម្លៃ និងគុណផលសិក្សារបស់សិស្សនៅកម្រិតសាលារៀន។

២) គ្រូបង្រៀនគំរូ៖មានគុណភាពការងារធ្វើឱ្យប្រសើរឡើងនូវការអនុវត្តកម្មវិធីសិក្សា ការបង្រៀន ការវាយតម្លៃ និងគុណផលសិក្សារបស់សិស្សនៅកម្រិតស្រុកឬខេត្ត។

៣) គ្រូបង្រៀនឆ្នើម៖ មានគុណភាពការងារធ្វើឱ្យប្រសើរឡើងដល់គោលនយោបាយ និងអន្តរាគមន៍ពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីសិក្សា ការបង្រៀន ការវាយតម្លៃ និងគុណផលសិក្សារបស់សិស្ស និងគុណផលសាលារៀននៅកម្រិតជាតិ។

## ២.១១ គន្លឹះសំខាន់ៗ ក្នុងការបណ្តុះទម្លាប់អាន

យោងតាមសៀវភៅសកម្មភាពអំណានក្នុងម៉ោងបណ្ណាល័យ(២០១៧) បានលើឡើងថាបណ្ណាល័យគឺជាកន្លែងដ៏មានសារៈសំខាន់មួយសម្រាប់ឱ្យសិស្សរីករាយក្នុងការអានសៀវភៅ ក៏ដូចជាអភិវឌ្ឍទម្លាប់អានរបស់ពួកគេ។ អង្គការរួមធ្វើដំបានកំណត់និយមន័យនៃទម្លាប់អានថា ជាការអានដែលធ្វើឡើងដោយ

ស្ម័គ្រចិត្ត និងញឹកញាប់ ហើយកុមារអាចអភិវឌ្ឍទម្លាប់អានបានល្អតាមរយៈការដឹកនាំសកម្មភាពអំណានទាំង៤ នៅក្នុងម៉ោងបណ្ណាល័យ ដែលមានអំណានឮ អំណានចូលរួម អំណានដៃគូ និងអំណានបុគ្គល។ សិស្សដែលមានទម្លាប់អាន ពួកគេអាចអាននៅគ្រប់ទីកន្លែងទាំងក្នុង និងក្រៅសាលារៀន។ ការដឹកនាំសិស្សធ្វើសកម្មភាពអំណានក្នុងម៉ោងបណ្ណាល័យ គឺបានជួយដល់សិស្សក្នុងការអភិវឌ្ឍទម្លាប់អាន។

យោងតាម សៀវភៅឯកសារជំនួយស្តីពីការគ្រប់គ្រងបណ្ណាល័យ (២០១៩) បានលើកឡើងថា បណ្ណាល័យ គឺបណ្តុះនូវទម្លាប់អានដល់សិស្សានុសិស្ស។ ទម្លាប់អានគឺកើតឡើងនៅពេលសិស្សអានដោយស្ម័គ្រចិត្ត អានដោយញឹកញាប់ និងមានភាពរីករាយជាមួយនឹងការអាន។ សិស្សនឹងយល់ថា ការអានជាសកម្មភាពគួរឱ្យរំភើប មានភាពរីករាយ ព្រមទាំងយល់នូវអ្វីដែលបានអាន។ បន្ទាប់ពីសិស្សបានបញ្ចប់ការសិក្សានៅកម្រិតបឋមសិក្សា សិស្សានុសិស្សនឹងក្លាយជាអ្នកអានដោយម្ចាស់ការ ហើយមានចំណង់ចំណូលចិត្តក្នុងការអានតាំងនៅសាលា និងនៅផ្ទះ។ បណ្ណាល័យដែលដំណើរការប្រកបដោយប្រសិទ្ធភាព គឺមានកុមារចូលបណ្ណាល័យក្នុងកំលុងពេលចេញលេង និងម៉ោងបណ្ណាល័យ។ កុមារអាចចូលរួមក្នុងសកម្មភាពអំណានក្នុងបរិយាកាសទទួលរាក់ទាក់ ជួយគាំទ្រ មានសុវត្ថិភាពផ្លូវអារម្មណ៍ និងអាចខ្ចីសៀវភៅយកទៅអាននៅផ្ទះ។ ក្នុងន័យនេះគឺត្រូវតែរៀបចំបណ្ណាល័យឱ្យក្លាយជាបណ្ណាល័យកុមារមេត្រី ដែលធានាបាននូវដំណើរការប្រកបដោយប្រសិទ្ធភាពរវាងអន្តរកម្មរបស់បណ្ណារក្សនិងគ្រូ ទៅលើកុមារដើម្បីទទួលបានអារម្មណ៍សុវត្ថិភាពនៅក្នុងការអាន។

យោងតាមសៀវភៅស្តីពី ស្តង់ដាបណ្ណាល័យបឋមសិក្សា(២០១១) បានលើកឡើងថាបណ្ណាល័យគឺជាកន្លែងដែលជួយលើកកម្ពស់ការអានដល់សាធារណជនទូទៅ ក្នុងការបណ្តុះទម្លាប់អាន និងការសិក្សាស្រាវជ្រាវដល់កុមារ រួមចំណែកគាំទ្រគោលនយោបាយស្តីពីសាលាកុមារមេត្រី និងរួមចំណែកក្នុងការពង្រឹងប្រសិទ្ធភាពបង្រៀន និងរៀន។ ការរៀបចំឱ្យមានបណ្ណាល័យនៅកម្រិតបឋមសិក្សា គឺជាចលនាមួយក្នុងការលើកកម្ពស់ដល់ការអានរបស់សិស្សចាប់តាំងពីកម្រិតថ្នាក់ដំបូង ដើម្បីឱ្យពួកទទួលបំណិនក្នុងការអានមួយដ៏សមស្រមតាមរយៈម៉ោងអំណានសេរី និងម៉ោងសកម្មភាពនៅក្នុងបណ្ណាល័យ។ សកម្មភាពទាំងនេះក៏បានបង្ហាញផងដែរអំពីការជំរុញដល់ដំណើរការនៃប្រព្រឹត្តទៅលើការរៀនអំណានរបស់សិស្ស។

# ជំពូកទី៣
# វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវស្តីពី "ការវាយតម្លៃទៅលើការបង្រៀនរបស់គ្រូស្តីអំណាននៅកម្រិតបឋមសិក្សាក្នុងខេត្តព្រៃវែង" មានគោលបំណងសិក្សាពីបញ្ហាប្រឈមនៃការបង្រៀនអំណានមុខវិជ្ជាភាសាខ្មែរ និងភាពខុសគ្នារវាងការបង្រៀនអំណាននិងមុខវិជ្ជាផ្សេងនៅក្នុងកម្រិតបឋមសិក្សា។ ការបង្កើតកម្រងសំណួរស្រាវជ្រាវនេះឡើង ដោយផ្អែកតាមឯកសារសៀវភៅតេស្តវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស សៀវភៅណែនាំសម្រាប់គ្រូបង្រៀនថ្នាក់ទី១ សៀវភៅកម្មវិធីសិក្សាលម្អិតមុខវិជ្ជាភាសាខ្មែរកម្រិតបឋមសិក្សា សៀវភៅក្របខ័ណ្ឌកម្មវិធីសិក្សាចំណេះទូទៅនិងអប់រំបច្ចេកទេស សៀវភៅស្តង់ដាអំណានថ្នាក់ទី១ ថ្នាក់ទី២ និងថ្នាក់ទី៣ និងឯកសារស្តីពីគន្លងអាជីពគ្រូបង្រៀន។ វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវគឺអនុវត្តតាមបែបបរិមាណវិស័យ។

## ៣.១ គម្រោងវិភាគ

អ្នកសិក្សាស្រាវជ្រាវ បានប្រើប្រាស់កម្រងសំណួរ ២ប្រភេទ តាមបែបបរិមាណវិស័យដោយបន្សីគ្នាជាមួយសំណួរស្រាវជ្រាវទាំងពីរ នៃប្រធានបទដែលលើកយកមកសិក្សា។ ស្របតាមផែនការនៃការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងកម្មវិធីសិក្សា ព្រមទាំងនិក្ខេបបទមានរយៈពេលកំណត់ច្បាស់លាស់ អ្នកសិក្សាស្រាវជ្រាវអាចបញ្ចប់ការសរសេរនិក្ខេបបទនិងឡើងការពារកិច្ចស្រាវជ្រាវនៅថ្ងៃទី២៤ខែតុលា ឆ្នាំ២០២០ តាមផែនការគ្រោងទុក។ ការចុះប្រមូលទិន្នន័យគឺធ្វើនៅសាលាបឋមសិក្សា៩ក្នុងខេត្តព្រៃវែង និងក្រុមគោលដៅបំពេញទិន្នន័យកម្រងសំណួរមាន២ប្រភេទគឺគណៈគ្រប់គ្រងសាលារៀននិងគ្រូបង្រៀន។

## ៣.២ ការប្រមូលទិន្នន័យ

ក្នុងអំឡុងពេលបិទសាលារៀនដោយសារការកើតមានជំងឺកូវីដ-១៩ គ្រូបង្រៀនតាមសាលារដ្ឋ បានចាប់ផ្តើមបង្រៀន និងដឹកនាំសិស្សឱ្យរៀនតាមអនឡាញ។ លិខិតឧទ្ទេសនាមពីក្រសួងអប់រំ យុវជន និងកីឡា លេខ ១៩៧ វជអ.ផក ចុះថ្ងៃពុធ ១០រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ពុទ្ធសករាជ ២៥៦៤ ត្រូវនឹងថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០ ស្តីពីការចាត់តាំងនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ

ជំនាន់ទី៧ នៃវិទ្យាស្ថានជាតិអប់រំ ឱ្យចុះប្រមូលទិន្នន័យតាមប្រព័ន្ធអនឡាញ (ONLINE Google Form) ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ។

ក្រោយពីបានឆ្លងយោបល់ក្នុងក្រុបខ័ណ្ឌបច្ចេកទេស ជាមួយគ្រូដឹកនាំបង្គោល និងគ្រូដឹកនាំរងរួចមក អ្នកសិក្សាស្រាវជ្រាវបានរៀបចំកម្រងសំណួរ ដើម្បីចុះប្រមូលទិន្នន័យ។ ក្នុងពេលចុះប្រមូលទិន្នន័យ អ្នកសិក្សាស្រាវជ្រាវ មានភាពសហការល្អអាជ្ញាធរដែនដី គណៈគ្រប់គ្រងសាលារៀន ដើម្បីចែកកម្រងសំណួរទៅតាមការជ្រើសរើសចំនួនសំណាកដែលបានគ្រោងទុក។

អ្នកសិក្សាស្រាវជ្រាវ បានចុះទៅជួបនាយកសាលានីមួយៗដើម្បីជូនលិខិតឧទ្ទេសនាម និងសុំការអនុញ្ញាត ជួបក្រុមគោលដៅដើម្បីផ្តល់កម្រងសំណួរ ដល់គណៈគ្រប់គ្រង និងគ្រូបង្រៀន ដោយមានកំណត់ពេលវេលាជាក់លាក់។ ការចុះប្រមូលទិន្នន័យ គឺមានភាពបត់បែនទៅតាមទីតាំងភូមិសាស្ត្ររបស់សាលារៀន និងផ្តល់អាទិភាពដល់អ្នកផ្តល់ទិន្នន័យ តាមរយៈប្រព័ន្ធទំនាក់ទំនងសង្គមនានា៖ Google form, តេលេក្រាម, ទូរស័ព្ទ និង Facebook ជាដើម។

ការបំពេញទិន្នន័យក្នុងកម្រងសំណួរមានរយៈពេលមួយសប្តាហ៍ អ្នកសិក្សាស្រាវជ្រាវបានប្រមូលកម្រងសំណួរពីអ្នកឆ្លើយតបទៅតាមពេលកំណត់ជាក់លាក់។ ក្នុងអន្តរកាលនៃការរក្សាគម្លាតសង្គម ការចុះប្រមូលទិន្នន័យបានជួបបញ្ហាមួយចំនួនផងដែរ ទាំងផ្នែកបច្ចេកទេសបណ្តាញទំនាក់ទំនងសង្គមនិងកិច្ចសហការពីអ្នកឆ្លើយតប។ ក្នុងការចុះប្រមូលទិន្នន័យបានប្រើប្រាស់ពេលវេលាសរុបចំនួន៣០ថ្ងៃ គិតចាប់ពីចាប់ផ្តើមរហូតដល់ថ្ងៃដែលបានទទួលកម្រងសំណួរទាំងអស់ពីគណៈគ្រប់គ្រងសាលារៀននិងគ្រូបង្រៀននៅកម្រិតបឋមសិក្សាដែលជាសំណាក។

## ៣.៣ ឧបករណ៍ស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទស្តីពី "ការវាយតម្លៃទៅលើការបង្រៀនរបស់គ្រូស្តីអំណាននៅកម្រិតបឋមសិក្សាក្នុងខេត្តព្រៃវែង" បានរៀបចំកម្រងសំណួរដែលមានសូចនាករនីមួយៗ ដោយយោងលើក្របខ័ណ្ឌកម្មវិធីសិក្សាចំណោះទូទៅ កម្មវិធីសិក្សាលម្អិតសម្រាប់កម្រិតបឋមសិក្សា គោលនយោបាយស្តីពីគ្រូបង្រៀន ក្របខ័ណ្ឌគន្លងអាជីពគ្រូបង្រៀន ទ្រឹស្តីពាក់ព័ន្ធជាមួយអំណាន និងការប្រឹក្សាជាមួយគ្រូដឹកនាំ

ដើម្បីប្រើប្រាស់សូចនាករនៅក្នុងកម្រងសំណួរ ប្រកបដោយសង្គតិភាព។ អ្នកសិក្សាស្រាវជ្រាវប្រើប្រាស់វិធីសាស្រ្តតាមបែបបរិមាណវិស័យ ក្នុងការចុះប្រមូលទិន្នន័យ ដោយមានកម្រងសំណួរ ២ប្រភេទផ្សេងគ្នា សម្រាប់គណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀន។

### ៣.៣.១ កម្រិតចង្អុលបង្ហាញ

កម្រិតចង្អុលបង្ហាញ គឺប្រើប្រាស់ក្នុងទម្រង់កម្រងសំណួរ ដើម្បីចុះប្រមូលទិន្នន័យពីភាគីពាក់ព័ន្ធ ទៅតាមការឆ្លើយតប ក្នុងកម្រិតតួលេខជាក់លាក់។ កម្រិតចង្អុលបង្ហាញ អាចបំពេញតាមរយៈអនឡាញ និង/ឬ គូសដោយផ្ទាល់នៅលើកម្រងសំណួរលើប្រធានបទសិក្សាស្រាវជ្រាវ។ ក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទខាងលើ គឺមានកម្រិតចង្អុលបង្ហាញចំនួន៥កម្រិត។ តួលេខចង្អុលបង្ហាញតាមបែប Likert Scale គឺនិយមចូលចិត្ត ប្រើច្រើនលើនិក្ខេបបទស្រាវជ្រាវក្នុងវិស័យអប់រំ។ តួលេខចង្អុលបង្ហាញគឺប្រើដើម្បីវាស់វែងសូចនាករ វាយតម្លៃទៅលើកម្រិតនៃការអនុវត្ត និងដំណើរការបំពេញការងាររបស់គណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀន។

ក្នុងការសិក្សាស្រាវជ្រាវនេះ កម្រិតចង្អុលបង្ហាញនៃកម្រងសំណួរនីមួយៗ មានចំនួន៥កម្រិត ពីពិន្ទុទាបបំផុត(១) ទៅពិន្ទុខ្ពស់បំផុត (៥)។ ពិន្ទុនៃកម្រិតចង្អុលបង្ហាញគឺ៖

១ គឺ មិនយល់ស្របទាល់តែសោះ

២ គឺ មិនយល់ស្រប

៣ គឺ ពុំមានយោបល់

៤ គឺ យល់ស្រប

៥ គឺ យល់ស្របខ្លាំង

ការបកស្រាយទៅលើការគណនាពិន្ទុ ពីការប្រមូលទិន្នន័យ ដើម្បីវិភាគលើ ពិន្ទុមធ្យមភាគនៃសូចនាករនីមួយៗ គឺមានរូបមន្តដូចខាងក្រោម (Best, 1981)៖

$$\frac{\text{ពិន្ទុខ្ពស់បំផុត-ពិន្ទុទាបបំផុត}}{\text{ចំនួនកម្រិតចង្អុលបង្ហាញ}} = \frac{5-1}{5} = \frac{4}{5} = 0.80$$

| | | |
|---|---|---|
| 1.00 — 1.80 | មានន័យថា | ខ្សោយខ្លាំង |
| 1.81 — 2.60 | មានន័យថា | ខ្សោយ |
| 2.61 — 3.40 | មានន័យថា | មធ្យម |
| 3.41 — 4.20 | មានន័យថា | ល្អ |
| 4.21 — 5.00 | មានន័យថា | ល្អណាស់ |

### ៣.៣.២ កម្រងសំណួរ

គោលបំណងនៃកម្រងសំណួរនេះ គឺដើម្បីសិក្សាស្វែងយល់ ការវាយតម្លៃទៅលើការបង្រៀនរបស់គ្រូស្តីអំណាននៅកម្រិតបឋមសិក្សាក្នុងខេត្តព្រៃវែង និងរកដំណោះស្រាយ លើការសិក្សាអំណាននៅកម្រិតបឋមសិក្សាឱ្យទទួលបានលទ្ធផលកាន់តែល្អប្រសើរ។ ទិន្នន័យប្រមូលបានពីកម្រងសំណួរនេះ មានគោលបំណងយកទៅប្រើប្រាស់ដើម្បីវិភាគកែលម្អ និងលើកកម្ពស់ ការងារបង្រៀនអំណាននៅកម្រិតបឋមសិក្សាឱ្យកាន់តែល្អប្រសើរ។ ទិន្នន័យដែលប្រមូលបាន គឺប្រើសម្រាប់តែសិក្សាស្រាវជ្រាវនេះ តែប៉ុណ្ណោះ។

#### *៣.៣.២.១ កម្រងសំណួរសម្រាប់គណៈគ្រប់គ្រងសាលារៀនបឋមសិក្សា*

កម្រងសំណួរសម្រាប់គណៈគ្រប់គ្រង ដែលត្រូវប្រើប្រាស់សម្រាប់នាយក/នាយិកា និងនាយករង/នាយិការង ដែលចែកចេញជា២ផ្នែកគឺ៖

**ផ្នែកទី១៖ព័ត៌មានទូទៅ**

ដែលមាន៦សំណួរ ទាក់ទងទៅនឹងតួនាទី កន្លែងបម្រើការងារ ភេទ អាយុ កម្រិតវប្បធម៌ និងបទពិសោធការងារ។

**ផ្នែកទី២៖ បញ្ហាប្រឈមនៃការបង្រៀនអំណាន លើមុខវិជ្ជាភាសាខ្មែរនៅកម្រិតបឋមសិក្សាក្នុងខេត្តព្រៃវែង**

មានសមាសភាគចំនួន៣ គឺកិច្ចគាំទ្រការងារពង្រឹងអំណាន (១០សំណួរ) ដំណើរការនៃការបង្រៀនអំណានមុខវិជ្ជាភាសាខ្មែរ (៨សំណួរ) ឥរិយាបថសិក្សាអំណានរបស់សិស្ស (៦សំណួរ) អំណានមុខវិជ្ជាភាសាខ្មែរ និងមុខវិជ្ជាផ្សេងទៀត (៥សំណួរ) ជាឧបករណ៍សម្រាប់វាស់ពីកម្រិតនៃឥរិយាបថរបស់ថ្នាក់ដឹកនាំនិងគ្រប់គ្រងសាលារៀន ដែលអាចឆ្លើយតបទៅនឹង ការវាយតម្លៃទៅលើការបង្រៀនរបស់គ្រូស្ដីពីអំណាននៅកម្រិតបឋមសិក្សាក្នុងខេត្តព្រៃវែង។ អ្នកសិក្សាស្រាវជ្រាវបានស្នើសុំមតិយោបល់បន្ថែម ពីការឆ្លើយតបរបស់គណៈគ្រប់គ្រងនៅផ្នែកទី២ ដើម្បីឱ្យការចុះប្រមូលទិន្នន័យកាន់តែមានភាពជឿជាក់ខ្ពស់ និងគ្រប់ជ្រុងជ្រោយ។

### *៣.៣.២.២ កម្រងសំណួរសម្រាប់គ្រូបង្រៀន*

កម្រងសំណួរគ្រូ គឺប្រើប្រាស់សម្រាប់ការប្រមូលទិន្នន័យពីគ្រូបង្រៀនដែលកំពុងបង្រៀននៅកម្រិតបឋមសិក្សាដែលចែកចេញជា៣ផ្នែកគឺៈ

**ផ្នែកទី១ៈ ព័ត៌មានទូទៅ**

ដែលមាន៧សំណួរ ទាក់ទងទៅនឹងស្ថានភាពដែលជាគ្រូបង្រៀន កំពុងបង្រៀននៅកម្រិតបឋមសិក្សា ជាគ្រូបង្រៀនដែលកំពុងបង្រៀន កន្លែងបម្រើការងារ ភេទ អាយុ កម្រិតវប្បធម៌ បទពិសោធការងារមុខវិជ្ជាឯកទេស/តួនាទី និងបង្រៀនថ្នាក់ទីប៉ុន្មាន។

**ផ្នែកទី២ៈ អំពីបញ្ហាប្រឈមរបស់គ្រូក្នុងការបង្រៀនអំណាន លើមុខវិជ្ជាភាសាខ្មែរនៅកម្រិតបឋមសិក្សា**

មានសមាសភាគចំនួន៤ គឺការអនុវត្តកម្មវិធីសិក្សា (៨សំណួរ) វិធីសាស្ត្របង្រៀន (១២សំណួរ) ការរៀបចំ និងប្រើប្រាស់សម្ភារឧបទេសបង្រៀនអំណាន (៧សំណួរ) ការសិក្សាអំណានមុខវិជ្ជាភាសាខ្មែរ (៩សំណួរ) ជាឧបករណ៍សម្រាប់វាស់ពីការវាយតម្លៃទៅលើការបង្រៀនរបស់គ្រូស្ដីអំណាននៅកម្រិតបឋមសិក្សាក្នុងខេត្តព្រៃវែង។ អ្នកសិក្សាស្រាវជ្រាវបានស្នើសុំមតិយោបល់បន្ថែមពីការឆ្លើយតបរបស់គ្រូបង្រៀននៅផ្នែកទី២ ដើម្បីឱ្យការចុះប្រមូលទិន្នន័យកាន់តែមានភាពជឿជាក់ខ្ពស់ និងគ្រប់ជ្រុងជ្រោយ។

**ផ្នែកទី៣ៈ អំពីភាពខុសគ្នាជាមួយការបង្រៀនអំណានមុខវិជ្ជាភាសាខ្មែរ និងមុខវិជ្ជាផ្សេងទៀត**

មានសំណួរ (៥សំណួរ) ជាឧបករណ៍សម្រាប់ឆ្លុះបញ្ចាំងអំពីភាពខុសគ្នាជាមួយការបង្រៀន

អំណានមុខវិជ្ជាភាសាខ្មែរនិងមុខវិជ្ជាផ្សេងទៀតនៅកម្រិតបឋមសិក្សា។ អ្នកសិក្សាស្រាវជ្រាវបានស្នើសុំមតិយោបល់បន្ថែមពីការឆ្លើយតបរបស់គ្រូបង្រៀន ដើម្បីឱ្យការចុះប្រមូលទិន្នន័យកាន់តែមានភាពជឿជាក់ខ្ពស់ និងគ្រប់ជ្រុងជ្រោយ។

## ៣.៤ ការជ្រើសរើសភាគសំណាក

ការប្រមូលទិន្នន័យ តាមរយៈកម្រងសំណួរក្នុងចំនួន៩ សាលាបឋមសិក្សាក្នុងខេត្តព្រៃវែង ដែលមានចំនួនសំណាកសរុប៨១នាក់ លោកគ្រូ-អ្នកគ្រូចំនួន៦៣នាក់ និងគណៈគ្រប់គ្រងសាលារៀនចំនួន១៨នាក់។ ការវិភាគទិន្នន័យ សិក្សាលើចំនួនភាគរយ តាមអថេរនីមួយៗ និងចំនួនមធ្យមភាគនៃសូចនាករតាមផ្នែក និងកម្រិតចង្អុលបង្ហាញចំនួន៥កម្រិត ដោយគណនាតាមរូបមន្តកំណត់ជាក់លាក់។

ស្ថានភាពនៅពេលចុះប្រមូលទិន្នន័យគឺ ឋិតក្នុងបរិបទនៃការរក្សាគម្លាតសង្គម ដោយសារជំងឺកូវីដ-១៩។ សាលារៀនកម្រិតបឋមសិក្សាមួយចំនួននៅក្នុងខេត្តព្រៃវែង មានស្ថានភាពទីតាំងភូមិសាស្ត្រខុសគ្នាទៅតាមស្រុកនីមួយៗ ដោយសាលាខ្លះឋិតក្នុងក្រុងមានភាពរីកចម្រើន សាលាខ្លះមានកម្រិតមធ្យម ហើយក៏មានសាលាខ្លះទៀតស្ថិតនៅក្នុងតំបន់ជួបការលំបាក។

ចំនួនសំណាកក្នុងការប្រមូលទិន្នន័យ តាមរយៈកម្រងសំណួរ បានជ្រើសរើសក្រុង/ស្រុកចំនួន៣ក្នុងខេត្តព្រៃវែង គឺ៖ ក្រុងព្រៃវែង ស្រុកបាភ្នំ និងស្រុកមេសាង។ ការចុះប្រមូលទិន្នន័យ តាមរយៈកម្រងសំណួរនៅសាលាបឋមសិក្សាចំនួន៩ មានសំណាកសរុបចំនួន ៨១នាក់ ដែលបែងចែកជា គណៈគ្រប់គ្រងសាលារៀនចំនួន១៨នាក់ និងគ្រូបង្រៀនកម្រិតបឋមចំនួន៦៣នាក់។

*តារាង៣.១៖ ចំនួនភាគសំណាកដែលបានទទួលទិន្នន័យពីកម្រងសំណួរ*

| ល.រ | ឈ្មោះស្រុក | ចំនួនសំណាក គណៈគ្រប់គ្រង | ចំនួនសំណាក គ្រូបង្រៀន |
|---|---|---|---|
| ១ | ក្រុងព្រៃវែង | 6 | 21 |
| ២ | ស្រុកបាភ្នំ | 6 | 21 |
| ៣ | ស្រុកមេសាង | 6 | 21 |

| | | |
|---|---|---|
| សរុប | **18** | **63** |

## ៣.៥ ការវិភាគទិន្នន័យ

ការវិភាគទិន្នន័យ សិក្សាលើចំនួនភាគរយ តាមអថេរនីមួយៗ និងចំនួនមធ្យមភាគនៃសូចនាករតាមផ្នែក និងកម្រិតចង្អុលបង្ហាញចំនួន ៥កម្រិត ដោយគណនាតាមរូបមន្តកំណត់ជាក់លាក់។ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់នូវកម្រងសំណួរ ដែលមានលក្ខណៈជាពហុជ្រើសរើស ទៅតាមកម្រិតចង្អុលបង្ហាញនីមួយៗក្នុងទម្រង់បិទ និងការផ្តល់មតិយោបល់សម្រាប់ស្វែងរកទិន្នន័យជាធាតុចូលបន្ថែម។ អ្នកសិក្សាស្រាវជ្រាវ បានប្រើប្រាស់កម្មវិធីវិភាគទិន្នន័យ Microsoft Excel ដើម្បីសិក្សាពីភាគរយ ពិន្ទុមធ្យមភាគ និងគម្លាតស្តង់ដារ ដើម្បីបកស្រាយទិន្នន័យតាមសូចនាករនីមួយៗ។ ការវិភាគលើមតិយោបល់បន្ថែមគឺអ្នកសិក្សាបានចាប់ក្រុមពាក្យទៅតាមទស្សនៈយល់ឃើញនីមួយៗ ពីការបំពេញកម្រងសំណួរទៅធ្វើការឆ្លុះបញ្ចាំងទៅនិងមធ្យមភាគដែលទទួលបានព្រមទាំងស្រង់ធាតុចូលមួយចំនួនពីអ្នកឆ្លើយតប ដាក់ក្នុងសំណូមពរ។

# ជំពូកទី៤
# លទ្ធផល និងការពិភាក្សា

លទ្ធផលនៃការសិក្សាស្រាវជ្រាវពីការប្រមូលទិន្នន័យ ត្រូវបានយកមកធ្វើការវិភាគបកស្រាយ និងពិភាក្សា ឆ្លើយតបទៅលើសំណួរស្រាវជ្រាវ តាមរយៈការបំពេញកម្រងសំណួរ ពីគណៈគ្រប់គ្រងសាលា និងគ្រូបង្រៀនកំពុងបង្រៀននៅកម្រិតបឋមសិក្សាក្នុងខេត្តព្រៃវែង។ បញ្ហាប្រឈមរបស់គ្រូក្នុងការបង្រៀនអំណាននៅកម្រិតបឋមសិក្សា និងភាពខុសគ្នាក្នុងការបង្រៀនអំណានមុខវិជ្ជាភាសាខ្មែរ និងមុខវិជ្ជាផ្សេងទៀត ដែលលោកគ្រូ-អ្នកគ្រូក្នុងខេត្តព្រៃវែងបានជួបនាពេលកន្លងមកហើយក៏ត្រូវបានលើកយកចំណុចទាំងនោះមកបកស្រាយ និងពិភាក្សា។

## ៤.១.ការវិភាគទិន្នន័យលើកម្រងសំណួរទី១ពីគ្រូបង្រៀន និងគណៈគ្រប់គ្រង

### ៤.១.១.ព័ត៌មានទូទៅរបស់គ្រូ

តាមទិន្នន័យ (ឧបសម្ព័ន្ធ "ក") បង្ហាញថាគ្រូបង្រៀនដែលចូលរួមក្នុងការសិក្សាស្រាវជ្រាវ មានភេទស្រីចំនួន ៦៧% និងគ្រូបង្រៀនភេទប្រុសមានចំនួន ៣៣%។ គ្រូបង្រៀនមានអាយុនៅចន្លោះ ៣១ ដល់៤០ មានចំនួន ៤១% អាយុចន្លោះ២០ ដល់៣០ មានចំនួន ៣២% មានអាយុចន្លោះ ៤១ ដល់៥០ មានចំនួន ១៧% និងមានអាយុលើសពី៥០ឆ្នាំ មានចំនួន ១០%។ គ្រូបង្រៀនបានបញ្ចប់សញ្ញាបត្របរិញ្ញាបត្រមានចំនួន ៥២% បញ្ចប់ថ្នាក់ទី១២ មានចំនួន ៤៦% បញ្ចប់បរិញ្ញាបត្រជាន់ខ្ពស់ ២% និងគ្មានគ្រូបង្រៀនបានបញ្ចប់ថ្នាក់បណ្ឌិតសោះឡើយ។ គ្រូបង្រៀនមានបទពិសោធន៍បង្រៀន ចន្លោះពី១១ដល់២០ឆ្នាំ មានចំនួន ៣៨% ចន្លោះពី ១ ដល់១០ មានចំនួន ៣៧% ចន្លោះពី២១ ដល់៣០ មានចំនួន ១០% និងលើសពី៣០ ឆ្នាំ មានចំនួន១៥%។ ចំនួនគ្រូបង្រៀនដែលបង្រៀននៅថ្នាក់ទី១ ថ្នាក់ទី២ ថ្នាក់ទី៣ មានចំនួន ២១% ស្មើគ្នា គ្រូបង្រៀនដែលបង្រៀននៅថ្នាក់ទី៥ មានចំនួន ១៤% គ្រូបង្រៀនដែលបង្រៀននៅថ្នាក់ទី៤ មានចំនួន ១២% និងគ្រូបង្រៀនដែលបង្រៀននៅថ្នាក់ទី៦ មានចំនួន ១១%។

### ៤.១.២ ព័ត៌មានទូទៅរបស់គណៈគ្រប់គ្រង

តាមទិន្នន័យ(ឧបសម្ព័ន្ធ "ខ")បង្ហាញថា គណៈគ្រប់គ្រងសាលារៀន ៧២% ភេទប្រុស និង ២៨% ជាគណៈគ្រប់គ្រងភេទស្រី។ គណៈគ្រប់គ្រងមានអាយុលើសពី ៤០ឆ្នាំ មានចំនួន ៣៣% មានអាយុចន្លោះពី ៣៦ ដល់ ៤០ មានចំនួន ៣៣% មានអាយុចន្លោះពី ៣១ដល់ ៣៥ មានចំនួន ៦% និងមិនមានគណៈគ្រប់ដែលមានអាយុចន្លោះពី២៥ ដល់៣០ឡើយ។ គណៈគ្រប់គ្រងបញ្ចប់បរិញ្ញាបត្រ មានចំនួន ៥៥% បញ្ចប់ថ្នាក់ទី១២ មានចំនួន ៣៩% បញ្ចប់បរិញ្ញាបត្រជាន់ខ្ពស់មានចំនួន ៦% និងមិនមានគណៈគ្រប់បានបញ្ចប់ថ្នាក់បណ្ឌិតទាល់តែសោះ។ គណៈគ្រប់គ្រងមានបទពិសោធន៍បង្រៀនលើសពី១៥ឆ្នាំ មានចំនួន ៨២% ក្រៅពីនេះគណៈគ្រប់គ្រងមានបទពិសោធន៍បង្រៀនចន្លោះពី ១ ដល់ ៥ឆ្នាំ មានចំនួន ៦% ចន្លោះពី ៦ ដល់ ១០ឆ្នាំមានចំនួន ៦% និងមានចន្លោះពី ១១ ដល់ ១៥ឆ្នាំមានចំនួន ៦%។

### ៤.១.៣. ទិន្នន័យឆ្លើយរបស់គ្រូ លើការបង្រៀនអំណានមុខវិជ្ជាភាសាខ្មែរ

*តារាង៤.១៖ ទិន្នន័យពីគ្រូលើការអនុវត្តកម្មវិធីសិក្សា*

| ល.រ | បរិយាយ | មធ្យមភាគ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | កិច្ចតែងការបង្រៀនអំណានត្រូវបានត្រួតពិនិត្យជាប្រចាំពីគណៈគ្រប់គ្រងសាលារៀន | 4.03 | 0.76 | ល្អ |
| ២ | បានរៀបចំកិច្ចតែងការបង្រៀនអំណានជាប្រចាំ | 3.98 | 0.61 | ល្អ |
| ៣ | មានទស្សនៈវិស័យលើកកម្ពស់គុណភាពបង្រៀនអំណាន | 4.19 | 0.69 | ល្អ |
| ៤ | បានស្រាវជ្រាវបន្ថែមលើការបង្រៀនអំណានភាសាខ្មែរ | 4.17 | 0.64 | ល្អ |
| ៥ | បានរៀបចំបំណែងចែកកម្មវិធីសិក្សា ច្បាស់លាស់ | 4.33 | 0.65 | ល្អណាស់ |
| ៦ | បានប្រើប្រាស់សៀវភៅពុម្ពសិក្សា | 4.43 | 0.67 | ល្អណាស់ |
| ៧ | មានទំនួលខុសត្រូវក្នុងការគោរពពេលវេលា | 4.29 | 0.63 | ល្អណាស់ |
| ៨ | ជារួម បានបង្រៀនអំណានស្របតាមកម្មវិធីសិក្សា | 4.32 | 0.69 | ល្អណាស់ |
| | **សរុប** | **4.22** | **0.67** | **ល្អណាស់** |

តារាង៤.១បង្ហាញថា មធ្យមភាគសរុបដែលបង្ហាញពីការអនុវត្តកម្មវិធីសិក្សានៃការបង្រៀនអំណានមុខវិជ្ជាភាសាខ្មែររបស់គ្រូនៅខេត្តព្រៃវែង គឺទទួលបានការយល់ស្របក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ= 4.22 )។ សូចនាករ "បានប្រើប្រាស់សៀវភៅពុម្ពសិក្សា" ទទួលបានការយល់ស្របខ្ពស់ជាងគេ ក្នុងដំណើរការអនុវត្តកម្មវិធីសិក្សា ដែលលោកគ្រូ-អ្នកគ្រូបានអនុវត្តក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ= 4.43)។ សូចនាករ "គ្រូបង្រៀន បានរៀបចំកិច្ចតែងការបង្រៀនអំណានជាប្រចាំ" ទទួលបានការយល់ស្របទាបជាងគេក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= 3.98)។

*តារាង៤.២៖ ទិន្នន័យពីគ្រូលើការប្រើវិធីសាស្ត្របង្រៀនអំណាន*

| ល.រ | បរិយាយ | មធ្យមភាគ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | កិច្ចតែងការបង្រៀនអំណានត្រូវបានត្រួតពិនិត្យជាប្រចាំពីគណៈគ្រប់គ្រងសាលារៀន | 4.30 | 0.53 | ល្អណាស់ |
| ២ | ទាញអារម្មណ៍សិស្សជាប្រចាំក្នុងពេលបង្រៀនអំណាន | 4.24 | 0.43 | ល្អណាស់ |
| ៣ | ផ្តល់ការណែនាំដល់សិស្ស លើចំណេះដឹងស្តីពីអំណាន | 4.32 | 0.50 | ល្អណាស់ |
| ៤ | ផ្លាស់ប្តូរវិធីសាស្ត្រ ដោយបានលេងល្បែងសិក្សាពីអំណាន | 4.13 | 0.46 | ល្អ |
| ៥ | បង្ហាញពី ការបញ្ចេញសំឡេង តាមអក្ខរក្រម | 4.27 | 0.48 | ល្អណាស់ |
| ៦ | ពិនិត្យ និងផ្ទៀងផ្ទាត់លើសំណេរសិស្ស | 4.32 | 0.50 | ល្អណាស់ |
| ៧ | បានបង្រៀនតាមបំណែងចែកកម្មវិធីសិក្សាមេរៀនភាសាខ្មែរ | 4.40 | 0.52 | ល្អណាស់ |
| ៨ | បង្រៀនអំណានតាមកាលវិភាគ និងម៉ោងកំណត់ | 4.33 | 0.65 | ល្អណាស់ |
| ៩ | បានណែនាំសិស្ស ចូលអានក្នុងបណ្ណាល័យជាប្រចាំ | 4.33 | 0.57 | ល្អណាស់ |
| ១០ | បានពិនិត្យសិស្សក្នុងពេលអានជាក្រុម ឬជាដៃគូ ឬជាបុគ្គល | 4.37 | 0.52 | ល្អណាស់ |
| ១១ | បានស្តាប់សិស្សអាន ព្រមទាំងបានជួយអានពាក្យពិបាក | 4.40 | 0.49 | ល្អណាស់ |
| ១២ | បានបង្រៀនចប់មុខវិជ្ជាភាសាខ្មែរ តាមកម្មវិធីសិក្សាកំណត់ | 4.05 | 0.81 | ល្អ |
| | **សរុប** | **4.29** | **0.54** | **ល្អណាស់** |

តារាង៤.២បង្ហាញថា មធ្យមភាគសរុបដែលបង្ហាញពីការប្រើប្រាស់វិធីសាស្ត្រនៃការបង្រៀនអំណានមុខវិជ្ជាភាសាខ្មែររបស់គ្រូនៅខេត្តព្រៃវែង គឺទទួលបានការយល់ស្របក្នុងកម្រិត "ល្អណាស់"(មធ្យមភាគពិន្ទុ= 4.29)។ សូចនាករ "បានបង្រៀនតាមបំណែងចែកកម្មវិធីសិក្សាមេរៀនភាសាខ្មែរ" ទទួលបានការយល់ស្របខ្ពស់ជាងគេក្នុងដំណើរការនៃការប្រើប្រាស់វិធីសាស្ត្របង្រៀនអំណានដែលលោកគ្រូ-អ្នកគ្រូបានអនុវត្តក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ= 4.40)។ សូចនាករ "បានបង្រៀនចប់មុខវិជ្ជាភាសាខ្មែរតាមកម្មវិធីសិក្សាកំណត់"ទទួលបានការយល់ស្របទាបជាងគេក្នុងកម្រិត"ល្អ"(មធ្យមភាគពិន្ទុ= 4.05)។

*តារាង៤.៣៖ ទិន្នន័យពីគ្រូលើការរៀបចំ និងប្រើប្រាស់សម្ភារឧបទេសសម្រាប់បង្រៀនអំណាន*

| ល.រ | បរិយាយ | មធ្យមភាគ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | បានប្រើប្រាស់សម្ភារឧបទេស ក្នុងពេលបង្រៀនអំណានជាប្រចាំ | 3.87 | 0.61 | ល្អ |
| ២ | សម្ភារឧបទេសស បានជួយឱ្យសិស្សងាយស្រួលក្នុងការយល់ | 4.32 | 0.47 | ល្អណាស់ |
| ៣ | ចេះប្រើប្រាស់ សម្ភារឧបទេសក្នុងការបង្រៀនអំណាន | 4.21 | 0.48 | ល្អណាស់ |
| ៤ | សិស្សងាយយល់ពីតួអក្សរ និងពាក្យក្រោយពីប្រើសម្ភារឧបទេស | 4.13 | 0.58 | ល្អ |
| ៥ | បានច្នៃប្រឌិតសម្ភារឧបទេសទាំងនោះឱ្យមានភាពទាក់ទាញ | 3.95 | 0.68 | ល្អ |
| ៦ | សម្ភារៈដែលបានរៀបចំប្រកបដោយគុណភាព | 3.87 | 0.75 | ល្អ |
| ៧ | បណ្ណាល័យមានសៀវភៅសិក្សា គ្រប់គ្រាន់ | 4.11 | 1.02 | ល្អ |
| | **សរុប** | **4.07** | **0.66** | **ល្អ** |

តារាង៤.៣បង្ហាញថា មធ្យមភាគសរុបដែលបង្ហាញពីការរៀបចំ និងប្រើប្រាស់សម្ភារឧបទេសការបង្រៀនអំណានមុខវិជ្ជាភាសាខ្មែររបស់គ្រូនៅខេត្តព្រៃវែង គឺទទួលបានការយល់ស្របក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ= 4.07)។ សូចនាករ "សម្ភារឧបទេសបានជួយឱ្យសិស្សងាយស្រួលក្នុងការយល់" ទទួលបានការយល់ស្របខ្ពស់ជាងគេក្នុងដំណើរការនៃការរៀបចំនិងប្រើប្រាស់សម្ភារឧបទេស

បង្រៀនអំណាន ដែលលោកគ្រូ-អ្នកគ្រូបានអនុវត្តក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ= 4.32)។ សូចនាករពីរ "បានប្រើប្រាស់សម្ភារឧបទេសក្នុងពេលបង្រៀនអំណានជាប្រចាំ"និង"សម្ភារៈដែលបានរៀបចំប្រកប ដោយគុណភាព" ទទួលបានការយល់ស្របទាបជាងគេក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= 3.87)។

***តារាង៤.៤៖ ទិន្នន័យពីគ្រូលើការសិក្សាអំណានមុខវិជ្ជាភាសាខ្មែរ***

| ល.រ | បរិយាយ | មធ្យមភាគ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | សិស្សអានដោយរីករាយ និងឮៗ ជាក្រុម ឬជាដៃគូ ឬជាបុគ្គល | 4.44 | 0.53 | ល្អណាស់ |
| ២ | សិស្សអានច្បាស់ៗ តាមលំដាប់នៃអក្ខរាវិរុទ្ធ | 4.21 | 0.68 | ល្អណាស់ |
| ៣ | សិស្ស បានសួរគ្រូពីការអានពាក្យពិបាក | 4.24 | 0.61 | ល្អណាស់ |
| ៤ | មានកម្មវិធីសិស្សជួយសិស្ស សំដៅជួយសិស្សជួបការលំបាកក្នុងការអាន | 4.11 | 0.48 | ល្អ |
| ៥ | បានចូលរួមក្នុងការប្រកួតប្រជែងអំណាន | 4.29 | 0.58 | ល្អណាស់ |
| ៦ | សិស្សចូលចិត្ត លើការសិក្សាអំណានភាសាខ្មែរ | 4.14 | 0.56 | ល្អ |
| ៧ | សិស្សមានបម្រុងប្រយ័ត្ន ក្នុងពេលអានមេរៀន | 4.17 | 0.55 | ល្អ |
| ៨ | សិស្សម្នាក់ៗ ទទួលបានលទ្ធផលសិក្សាល្អ លើអំណានភាសាខ្មែរ | 4.13 | 0.58 | ល្អ |
| ៩ | សិស្សបានធ្វើកិច្ចផ្ទះ លើអំណានភាសាខ្មែរតាមបណ្តាំធ្វើគ្រូ | 4.21 | 0.54 | ល្អណាស់ |
| | **សរុប** | **4.22** | **0.57** | **ល្អណាស់** |

តារាង៤.៤បង្ហាញថា មធ្យមភាគសរុបដែលបង្ហាញពីការការសិក្សាអំណានមុខវិជ្ជាភាសាខ្មែរ របស់សិស្សនៅខេត្តព្រៃវែង គឺទទួលបានការយល់ស្របក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ= 4.22)។ សូចនាករ "សិស្សអានដោយរីករាយ និងឮៗ ជាក្រុម ឬជាដៃគូ ឬជាបុគ្គល" ទទួលបានការយល់ស្របខ្ពស់ជាងគេក្នុងដំណើរការនៃការសិក្សាអំណានមុខវិជ្ជាភាសាខ្មែររបស់សិស្សក្នុងកម្រិត "ល្អណាស់"

(មធ្យមភាគពិន្ទុ= 4.44)។ សូចនាករ "មានកម្មវិធីសិស្សជួយសិស្ស សំដៅជួយសិស្សជួបការលំបាកក្នុងការអាន" ទទួលបានការយល់ស្របទាបជាងគេក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= 4.11)។

*តារាង៤.៥៖ ទិន្នន័យសរុបពីគ្រូទៅលើបញ្ហាប្រឈមក្នុងការបង្រៀនអំណានមុខវិជ្ជាភាសាខ្មែរ*

| ល.រ | បរិយាយ | មធ្យមភាគ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | ការអនុវត្តកម្មវិធីសិក្សា | 4.22 | 0.67 | ល្អណាស់ |
| ២ | វិធីសាស្ត្របង្រៀន | 4.29 | 0.54 | ល្អណាស់ |
| ៣ | ការរៀបចំ និងប្រើប្រាស់សម្ភារឧបទេសសម្រាប់បង្រៀនអំណាន | 4.07 | 0.66 | ល្អ |
| ៤ | ការសិក្សាអំណានមុខវិជ្ជាភាសាខ្មែរ | 4.22 | 0.57 | ល្អណាស់ |
| | **សរុប** | **4.20** | **0.61** | **ល្អ** |

តារាង៤.៥បង្ហាញថា មធ្យមភាគសរុបដែលបង្ហាញពីការសិក្សាអំណានមុខវិជ្ជាភាសាខ្មែរ នៅក្នុងខេត្តព្រៃវែងគឺទទួលបានការយល់ស្របក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= 4.20 )។ សូចនាករ "វិធីសាស្ត្របង្រៀន" ទទួលបានការយល់ស្របខ្ពស់ជាងគេ ក្នុងដំណើរការសិក្សាអំណានមុខវិជ្ជាភាសាខ្មែររបស់សិស្សដែលលោកគ្រូ-អ្នកគ្រូបានអនុវត្តក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ= 4.29) និងសូចនាករ "ការរៀបចំ និងប្រើប្រាស់សម្ភារឧបទេសសម្រាប់បង្រៀនអំណាន" ទទួលបានការយល់ស្របទាបជាងគេក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= 4.07 )។

## ៤.២. ទិន្នន័យឆ្លើយតបពី គណៈគ្រប់គ្រងសាលារៀន លើការអនុវត្តកម្មវិធីសិក្សា និងដំណើរការក្នុងការបង្រៀនអំណាន លើមុខវិជ្ជាភាសាខ្មែរ

នៅក្នុងតារាងទិន្នន័យនេះ បង្ហាញពីមធ្យមភាគសរុបនៃបញ្ហាប្រឈមរបស់គណៈគ្រប់គ្រងក្នុងការជួយគាំទ្រទៅលើការបង្រៀនអំណានមុខវិជ្ជាភាសាខ្មែរនៅកម្រិតបឋមសិក្សាក្នុងខេត្តព្រៃវែង។

*តារាង៤.៦៖ ទិន្នន័យឆ្លើយតបពីគណៈគ្រប់គ្រងលើកិច្ចគាំទ្រលើការងារពង្រឹងអំណាន*

| ល.រ | បរិយាយ | មធ្យមភាគ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | ផ្តល់សម្ភារល្បែងសិក្សា ដើម្បីពង្រឹងអំណាន | 4.06 | 0.64 | ល្អ |
| ២ | បង្កើតឱ្យមានកម្មវិធីកុមារជួយកុមារ ជម្រុញការរៀនសូត្រពីមិត្តភក្តិ | 3.94 | 0.87 | ល្អ |
| ៣ | បង្កបរិយាកាសក្នុងសាលារៀន ដើម្បីលើកកម្ពស់អំណាន | 4.33 | 0.49 | ល្អ |
| ៤ | បានអនុវត្តតាមគោលនយោបាយ លើកកម្ពស់អំណាន | 4.33 | 0.49 | ល្អ |
| ៥ | ការរៀបចំបណ្ណាល័យ ឱ្យក្លាយជាទីមេត្រីសម្រាប់ការអាន | 4.11 | 0.90 | ល្អ |
| ៦ | បានផ្តល់មតិយោបល់ កែលម្អក្នុងការធ្វើថ្នាក់និទស្សន៍មុខវិជ្ជាភាសាខ្មែរ | 3.94 | 0.73 | ល្អ |
| ៧ | បានពិនិត្យតាមដាន លើដំណើរការបង្រៀនរបស់គ្រូ ជាប្រចាំ | 4.28 | 0.75 | ល្អ |
| ៨ | បានផ្តល់វគ្គបំប៉នសមត្ថភាព ដល់គ្រូបង្រៀនអំណាន | 3.89 | 1.02 | ល្អ |
| ៩ | ប្រជុំជាមួយមាតាបិតាសិស្ស ដើម្បីឱ្យជួយបង្រៀនកូនៗនៅផ្ទះ | 4.22 | 1.06 | ល្អ |
| ១០ | សហគមន៍បានចូលរួម ជាមួយសាលារៀន ស្តីពីអំណានរបស់សិស្ស | 4.00 | 0.59 | ល្អ |
| | **សរុប** | **4.11** | **0.75** | **ល្អ** |

តារាង៤.៦បង្ហាញថា មធ្យមភាគសរុបដែលបង្ហាញពីកិច្ចគាំទ្រលើការងារពង្រឹងអំណានរបស់គណៈគ្រប់គ្រងសាលារៀន គឺទទួលបានការយល់ស្របក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= 4.11 )។ សូចនាករ "បង្កបរិយាកាសក្នុងសាលារៀន ដើម្បីលើកកម្ពស់អំណាន" និង "បានអនុវត្តតាមគោលនយោបាយ លើកកម្ពស់អំណាន" ទទួលបានការយល់ស្របខ្ពស់ជាងគេ ក្នុងដំណើរការសិក្សារបស់សិស្ស ដែលលោកគ្រូ-អ្នកគ្រូបានអនុវត្តក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ= 4.33) និងសូចនាករ "បានផ្តល់វគ្គបំប៉នសមត្ថភាពដល់គ្រូបង្រៀនអំណាន" ទទួលបានការយល់ស្របទាបជាងគេក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= 3.89)។

*តារាង៤.៧៖ ទិន្នន័យឆ្លើយតបពីគណៈគ្រប់គ្រងលើដំណើរការនៃការបង្រៀនអំណានមុខវិជ្ជាភាសាខ្មែរ*

| ល.រ | បរិយាយ | មធ្យមភាគ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | កិច្ចតែងការបង្រៀនអំណានត្រូវបានត្រួតពិនិត្យជាប្រចាំពីគណៈគ្រប់គ្រងសាលារៀន | 3.94 | 0.21 | ល្អ |
| ២ | គ្រូបង្រៀន បានរៀបចំកិច្ចតែងការបង្រៀនអំណានជាប្រចាំ | 3.83 | 0.27 | ល្អ |
| ៣ | គ្រូបង្រៀន មានទស្សនៈវិស័យលើកកម្ពស់គុណភាពបង្រៀនអំណាន | 4.06 | 0.30 | ល្អ |
| ៤ | គ្រូបង្រៀន បានស្រាវជ្រាវបន្ថែមលើការបង្រៀនអំណានភាសាខ្មែរ | 3.83 | 0.31 | ល្អ |
| ៥ | គ្រូបង្រៀន បានរៀបចំបំណែងចែកកម្មវិធីសិក្សាច្បាស់លាស់ | 4.44 | 0.33 | ល្អណាស់ |
| ៦ | គ្រូបង្រៀន មានសមត្ថភាពសបស្រេបតាមកម្រិតវិជ្ជាជីវៈ | 4.11 | 0.32 | ល្អ |
| ៧ | គ្រូបង្រៀន មានទំនួលខុសត្រូវក្នុងការគោរពពេលវេលា | 4.39 | 0.32 | ល្អណាស់ |
| ៨ | ជារួម គ្រូបានបង្រៀនអំណានស្របតាមកម្មវិធីសិក្សា | 4.22 | 0.32 | ល្អណាស់ |
| | **សរុប** | **4.10** | **0.29** | **ល្អ** |

តារាង៤.៧បង្ហាញថា មធ្យមភាគសរុបដែលបង្ហាញពីដំណើរការនៃការបង្រៀនអំណានមុខវិជ្ជាភាសាខ្មែររបស់គ្រូនៅខេត្តព្រៃវែង គឺទទួលបានការយល់ស្របក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= 4.10 )។ សូចនាករ "គ្រូបង្រៀន បានរៀបចំបំណែងចែកកម្មវិធីសិក្សា ច្បាស់លាស់" ទទួលបានការយល់ស្របខ្ពស់ជាងគេ ក្នុងដំណើរការសិក្សារបស់សិស្ស ដែលលោកគ្រូ-អ្នកគ្រូបានអនុវត្តក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ= 4.44)។ សូចនាករ "គ្រូបង្រៀន បានរៀបចំកិច្ចតែងការបង្រៀនអំណានជាប្រចាំ" និង "គ្រូបង្រៀន បានស្រាវជ្រាវបន្ថែមលើការបង្រៀនអំណានភាសាខ្មែរ" ទទួលបានការយល់ស្របទាបជាងគេក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= 3.83)។

*តារាង៤.៨៖ ទិន្នន័យឆ្លើយតបពីគណៈគ្រប់គ្រងលើឥរិយាបថសិក្សាអំណានរបស់សិស្ស*

| ល.រ | បរិយាយ | មធ្យមភាគ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | លទ្ធផលសិក្សារបស់សិស្ស មានតម្លាភាព និងផ្ទៀងផ្ទាត់ច្បាស់លាស់ | 3.94 | 0.54 | ល្អ |
| ២ | ពេលម៉ោងសិក្សាអំណាន សមស្របជាមួយមុខវិជ្ជាភាសាខ្មែរ | 4.33 | 0.49 | ល្អណាស់ |
| ៣ | សិស្ស បានចូលរួមក្នុង កម្មវិធីកុមារជួយកុមារ | 3.89 | 0.83 | ល្អ |
| ៤ | មានការរៀនអានបន្ថែម នៅក្រៅម៉ោងសិក្សា | 3.61 | 1.04 | ល្អ |
| ៥ | សិស្ស ស្រឡាញ់ និងចូលចិត្តអំណានក្នុងបណ្ណាល័យ | 4.06 | 0.94 | ល្អ |
| ៦ | សិស្សចូលចិត្ត លើការសិក្សាអំណានភាសាខ្មែរ | 4.06 | 0.64 | ល្អ |
| | **សរុប** | **3.98** | **0.75** | **ល្អ** |

តារាង៤.៨បង្ហាញថា មធ្យមភាគសរុបដែលបង្ហាញពីឥរិយាបថនៃការសិក្សាអំណានរបស់សិស្ស តាមរយៈការសង្កេតពីគណៈគ្រប់គ្រងសាលា គឺទទួលបានការយល់ស្របក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= 3.98 )។ សូចនាករ "ពេលម៉ោងសិក្សាអំណាន សមស្របជាមួយមុខវិជ្ជាភាសាខ្មែរ" ទទួលបានការយល់ស្របខ្ពស់ជាងគេ ក្នុងដំណើរការសិក្សារបស់សិស្ស ដែលលោកគ្រូ-អ្នកគ្រូបានអនុវត្តក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ= 4.33) និងសូចនាករ "មានការរៀនអានបន្ថែម នៅក្រៅម៉ោងសិក្សា" ទទួលបានការយល់ស្របទាបជាងគេក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= 3.61 )។

***តារាង៤.៩៖ ទិន្នន័យឆ្លើយតបរបស់គណៈគ្រប់គ្រងសាលា លើកិច្ចគាំទ្រក្នុងការបង្រៀនអំណានមុខវិជ្ជាភាសាខ្មែរ***

| ល.រ | បរិយាយ | មធ្យមភាគ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | កិច្ចគាំទ្រលើការងារពង្រឹងអំណាន | 4.11 | 0.75 | ល្អ |
| ២ | ដំណើរការនៃការបង្រៀនអំណានមុខវិជ្ជាភាសាខ្មែរ | 4.10 | 0.29 | ល្អ |
| ៣ | ឥរិយាបថសិក្សាអំណានរបស់សិស្ស | 3.98 | 0.75 | ល្អ |

| | | | |
|---|---|---|---|
| សរុប | **4.06** | **0.59** | **ល្អ** |

តារាង៤.៩បង្ហាញថា មធ្យមភាគសរុបដែលបង្ហាញពីការសិក្សាអំណានមុខវិជ្ជាភាសាខ្មែរ នៅក្នុងខេត្តព្រៃវែងគឺទទួលបានការយល់ស្របពីគណៈគ្រប់គ្រងសាលាក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= 4.06)។ សូចនាករ "កិច្ចគាំទ្រលើការងារពង្រឹងអំណាន" ទទួលបានការយល់ស្របខ្ពស់ជាងគេ ក្នុងដំណើរការសិក្សាអំណានមុខវិជ្ជាភាសាខ្មែររបស់សិស្ស ដែលលោកគ្រូ-អ្នកគ្រូបានអនុវត្តក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= 4.11) និងសូចនាករ "ឥរិយាបថសិក្សាអំណានរបស់សិស្ស" ទទួលបានការយល់ស្របទាបជាងគេក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= 3.98 )។

## ៤.៣. ការពិភាក្សាលើបញ្ហាប្រឈមរបស់គ្រូបង្រៀនអំណានមុខវិជ្ជាភាសាខ្មែរ

កិច្ចការងារបង្រៀន គឺទាមទារវិជ្ជាជីវៈការងារច្បាស់លាស់ដោយគ្របដណ្តប់ទាំងការងាររដ្ឋបាលសិក្សា និងវិធីសាស្ត្របង្រៀនក្នុងដំណើរការថ្នាក់រៀន។ មុខវិជ្ជាភាសាខ្មែរគឺជាមុខវិជ្ជាមួយ ក្នុងចំណោមមុខវិជ្ជាផ្សេងទៀត នៃកម្រិតបឋមសិក្សា។ ដោយដំណើរការបង្រៀន ត្រូវប្រព្រឹត្តិទៅតាមកាលវិភាគ ក្នុងមួយឆ្នាំសិក្សាចែកជា ៣៥ សប្តាហ៍នោះបញ្ហាប្រឈមនៃការអនុវត្តរបស់គ្រូបង្រៀន នៅកម្រិតបឋមសិក្សាគឺអាចមានបញ្ហាប្រឈមជាច្រើនដែលតម្រូវឱ្យមានការដោះស្រាយដើម្បីធានាដល់ប្រសិទ្ធភាពនៃការបង្រៀន និងជំរុញភាពប្រសើរឡើងនៃលទ្ធផលសិក្សារបស់សិស្សានុសិស្ស ជាពិសេសគឺការរៀនអានមុខវិជ្ជាភាសាខ្មែរ។

***តារាង៤.១០៖ ទិន្នន័យលើការពិភាក្សាលើបញ្ហាប្រឈមការបង្រៀនអំណានមុខវិជ្ជាភាសាខ្មែរ***

| ល.រ | បរិយាយ | មធ្យមភាគ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | ទិន្នន័យសរុបពីគ្រូ លើការបង្រៀនអំណានមុខវិជ្ជាភាសាខ្មែរ | 4.20 | 0.61 | ល្អ |
| ២ | ទិន្នន័យសរុបពីគណៈគ្រប់គ្រងសាលរៀន លើការបង្រៀនអំណានមុខវិជ្ជាភាសាខ្មែរ | 4.06 | 0.59 | ល្អ |
| | សរុប | **4.13** | **0.60** | **ល្អ** |

តាមតារាង៤.១០បង្ហាញថា ទិន្នន័យសរុបលើការអនុវត្តដំណើរការបង្រៀនអំណានមុខវិជ្ជាភាសាខ្មែរនៅកម្រិតបឋមសិក្សា ក្នុងខេត្តព្រៃវែងស្ថិតក្នុងកម្រិត "ល្អ"(មធ្យមភាគ=4.13)។ តាមរយៈទិន្នន័យដែលឆ្លុះបញ្ចាំងលើដំណើរការអនុវត្តការបង្រៀនអំណានមុខវិជ្ជាភាសាខ្មែរ ស្តែងឱ្យឃើញថា គ្រូបង្រៀនមានការអនុវត្តបានល្អក្នុងដំណើរការបង្រៀនអំណានមុខវិជ្ជាភាសាខ្មែរ ដោយបានអនុវត្តការបង្រៀនចប់តាមកម្មវិធីសិក្សាដែលក្រសួងអប់រំ យុវជន និងកីឡាបានកំណត់ គ្រូបង្រៀបបានរៀបចំកិច្ចតែងការបង្រៀនអំណានជាប្រចាំ និងមានវិធីសាស្ត្រសម្បូរបែបក្នុងការបង្រៀនអំណានឆ្លើយតបទៅនឹងស្ថានភាពនៃការសិក្សារបស់សិស្សក្នុងកម្រិតបឋមសិក្សា ចំណែកសិស្សានុសិស្សក៏មានស្មារតីខ្ពស់ក្នុងការចូលរួមចំណែកលើសកម្មភាពរៀនអំណាន ពួកគេមានទឹកចិត្តសប្បាយរីករាយនៅក្នុងការរៀនអាន ដោយបញ្ចេញសំឡេងអានលឺៗ អានច្បាស់ៗ តាមលំដាប់នៃអក្ខរាវិរុទ្ធ ជាក្រុម ឬជាដៃគូ ឬជាបុគ្គល។ សិស្សានុសិស្សមានបម្រុងប្រយ័ត្នក្នុងពេលរៀនអំណាន ហ៊ានសួរគ្រូ ឬមិត្តភក្តិអំពីពាក្យពិបាកឬពាក្យអានមិនរួច ហើយពួកគេក៏មានសេចក្ដីក្លាហានក្នុងចូលរួមក្នុងការប្រកួតប្រជែងអំណាន និងចូលចិត្តលើការសិក្សាអំណានភាសាខ្មែរ។ ការបង្រៀនអំណានមុខវិជ្ជាភាសាខ្មែរក៏នូវមានបញ្ហាប្រឈមទៅលើ ការរៀបចំ និងប្រើប្រាស់សម្ភារៈឧបទេសបង្រៀនអំណាន ដែលគ្រូបង្រៀនមិនប្រើប្រាស់សម្ភារៈឧបទេសបង្រៀនជាប្រចាំ មិនបានកែច្នៃសម្ភារៈឱ្យមានភាពទាក់ទាញអារម្មណ៍សិស្សឱ្យចាប់អារម្មណ៍ឱ្យយកចិត្តទុកក្នុងការរៀនអំណាន និងមិនបានរៀបចំសម្ភារឧបទេសឱ្យមានគុណភាពឆ្លើយតបទៅនឹងខ្លឹមសាររៀន ព្រមទាំងងាយស្រួលប្រើប្រាស់ក្នុងពេលបង្រៀនអំណាន។

ការបង្រៀនអំណានដែលមានការយកចិត្តទុកដាក់អនុវត្តឱ្យចប់តាមកម្មវិធីសិក្សាដែលបានកំណត់គឺជាការអនុវត្តតាមវិជ្ជាជីវៈនៃដំណើរការបង្រៀនសិស្ស និងការពិនិត្យតាមដានលើក្របខ័ណ្ឌនៃកាអនុវត្តកម្មវិធីសិក្សាប្រកបដោយគុណភាព។ ការអនុវត្តកម្មវិធីសិក្សាអំណាននៅកម្រិតបឋមសិក្សាបានល្អគឺមានភាពចាំបាច់ណាស់សម្រាប់សិស្សានុសិស្សនៅក្នុងការសិក្សាមុខវិជ្ជាភាសាខ្មែរ ព្រោះកម្មវិធីសិក្សាគឺជាផែនទីសម្រាប់ចង្អុលបង្ហាញដល់គ្រូបង្រៀន ក្នុងការកំណត់បានពីមូលហេតុនៃការមិនចេះអានរបស់សិស្ស ហើយក៏បានធ្វើឱ្យការសិក្សារបស់សិស្ស ជួបនូវឧបសគ្គក្នុងការមើល តួអក្សររួចហើយ រិតតែពុំអាចប្រកប

ព្យញ្ជនៈនិងស្រៈបាន។ យោងតាមសៀវភៅកម្មវិធីសិក្សាលម្អិតមុខវិជ្ជាភាសាខ្មែរកម្រិតបឋមសិក្សា (២០១៨) បានលើកឡើងថា "កម្មវិធីសិក្សាមុខវិជ្ជាភាសាខ្មែរ សំដៅបណ្តុះបណ្តាលបុគ្គលិកលក្ខណៈពេញលេញរបស់អ្នកសិក្សាលើផ្នែករាងកាយ បញ្ញា សីលធម៌ តម្លៃ និងអប់រំបំណិនមូលដ្ឋានសម្រាប់ការអប់រំនៅកម្រិតបន្ត ដើម្បីឱ្យក្លាយខ្លួនជា បុគ្គលដែលមានប្រយោជន៍សម្រាប់ខ្លួនឯង គ្រួសារ សហគមន៍ ប្រទេសជាតិ និងពិភពលោក"។ យោងតាមសៀវភៅណែនាំសម្រាប់គ្រូបង្រៀនថ្នាក់ទី១(២០២០) បានលើកលើងថា "មូលដ្ឋាននៃអំណានមុខវិជ្ជាភាសាខ្មែរ គឺការស្គាល់សូរព្យញ្ជនៈ ស្រៈច្បាស់លាស់ រួមផ្សំទាំងសមត្ថភាពក្នុងការកំណត់សូរ ញែកសូរ និងផ្សំសូរ ប្រកបអក្សរ ព្យាង្គ ពាក្យ។ ការកត់សម្គាល់សូរទៅនឹងការស្គាល់តួអក្សរ គឺជាការភ្ជាប់ពីសូរអក្សរ ទៅនឹងរូបរាងនៃសូរអក្សរដែលជួយដល់ដំណើរការអានរបស់សិស្ស"។ គ្រូបង្រៀននៅកម្រិតបឋមសិក្សា បានអនុវត្តកិច្ចការបង្រៀនអំណានតាមកម្មវិធីសិក្សា បានល្អធ្វើឱ្យសិស្សានុសិស្សមានចំណេះដឹង និងសមត្ថភាពពេញក្នុងការសិក្សារៀនសូត្រ យោងតាមឯកសារសន្និបាតបូកសរុបលទ្ធផលការងារ អប់រំ យុវជន និងកីឡា(២០១៩)បានលើកឡើងថា "ការបង្រៀន និងរៀននៅតាមសាលាប្រកបដោយគុណភាព និងប្រសិទ្ធភាពគឺបានលើកម្ពស់ដល់ការអនុវត្តកម្មវិធីសិក្សា"។ ការបង្រៀនអំណានក៏បានបង្ហាញ ពីភាពល្អរបស់គ្រូបង្រៀនដែលមានកិច្ចតែងការបង្រៀនអំណានសម្រាប់ជាទិសដៅចង្អុល បង្ហាញនូវជំហាននៃការបង្រៀន និងប្រើប្រាស់វិធីសាស្ត្របង្រៀនអំណានឱ្យកាន់តែសម្បូរបែបឆ្លើយតបទៅនឹងស្ថានភាពនៃការសិក្សាអំណានរបស់សិស្ស ដើម្បីជួយបង្កើនប្រសិទ្ធភាពនៃការរៀនអំណានរបស់សិស្សានុសិស្ស យោងតាមសៀវភៅកម្មវិធីសិក្សាលម្អិតមុខវិជ្ជាភាសាខ្មែរកម្រិតបឋមសិក្សា(២០១៨) បានលើកឡើងថា "វិធីសាស្ត្របង្រៀនភាសាខ្មែរ ធ្វើយ៉ាងណាឱ្យសិស្សយល់ពីរបៀបរៀនដោយខ្លួនឯង ពោលគឺមិនឱ្យរៀនបានត្រឹមតែត្រាប់តាមគ្រូនោះទេ។ គ្រូគប្បីប្រើវិធីបង្រៀនសម្បូរបែបស្របតាមកាលៈទេសៈ និងស្ថានភាព ជាពិសេសវិធីបង្រៀនថ្មីៗ"។ ស្មារតីនៅក្នុងការសិក្សាអំណានមុខវិជ្ជាភាសាខ្មែរអាចកើតមានទៅបាន ដោយសារគ្រូបង្រៀនបានផ្តល់ការលើកទឹកចិត្តសិស្សក្នុងការសិក្សាអំណានមុខវិជ្ជាភាសាខ្មែរដល់សិស្ស ដែលបានការកសាងមូលដ្ឋានគ្រឹះសម្រាប់សិស្សឱ្យមានការយកចិត្តទុកដាក់លើការសិក្សាអំណានមុខភាសាខ្មែរ ដោយស្ម័គ្រចិត្ត ដោយរីករាយ ដោយក្តីស្រលាញ់

ដែលបង្កដំណើរនៃបរិយាកាសសិក្សាល្អ មិនមានសម្ពាធ ព្រមទាំងមានការជួយគាំទ្រលើអំណានគ្រប់ពេល ពីគ្រូបង្រៀន និងទទួលបានចំណេះដឹងផ្នែកអំណានច្បាស់លាស់ ″ការអានគឺជាសកម្មភាពគួរឱ្យរំភើប មានភាពរីករាយ ព្រមទាំងទទួលបាននូវព័ត៌មាន និងយល់ពីអ្វីដែលគេបានអាន″, សៀវភៅឯកសារជំនួយ ស្ដីពីការគ្រប់គ្រងបណ្ណាល័យ របស់អង្គការរួមធ្វើដ(២០១៨)។

ដំណើរការដឹកនាំគ្រប់គ្រងសាលាមានប្រសិទ្ធភាព បានធានាដល់ដំណើរការរៀន និងបង្រៀន អំណានកាន់តែមានគុណភាព និងប្រសិទ្ធភាព។ យោងតាមឯកសារក្របខ័ណ្ឌគន្លងអាជីពគ្រូបង្រៀន (២០១៨) បានលើកឡើងថា ″អ្នកគ្រប់គ្រងសាលារៀនល្អ ឱ្យមានចំណេះដឹង ជំនាញ សីលធ៌ម និងមាន សមត្ថភាពវិជ្ជាជីវៈដោយមានការទទួលស្គាល់ពីសង្គម ដែលធ្វើឱ្យសម្រេចបាននូវគុណផលរបស់គ្រូបង្រៀន ជាមួយនឹងគុណផលសិក្សារបស់សិស្ស និងគុណផលរបស់សាលារៀន″។

តាមរយៈទិន្នន័យដែលបានឆ្លើយតបដោយគ្រូបង្រៀន និងគណៈគ្រប់គ្រងនៅកម្រិតបឋមសិក្សា ក្នុងខេត្តព្រៃវែងក៏បង្ហាញឱ្យឃើញថានៅការបង្រៀនអំណានមុខវិជ្ជាភាសាខ្មែរក៏នៅមានបញ្ហាប្រឈមទៅ លើការច្នៃប្រឌិតសម្ភារៈឧបទេសបង្រៀនអំណានមិនទាន់មានការទាក់ទាញចិត្តសិស្ស និងសម្ភារៈ ឧបទេសបង្រៀនអំណានដែលគ្រូបង្រៀនបានប្រើប្រាស់ក្នុងពេលបង្រៀនអំណានមិនមានគុណភាពដែល ធ្វើឱ្យរាំងស្ទះដល់ដំណើរការបង្រៀន និងរៀនអំណានមិនបានពេញលេញ និងធានាបាននូវប្រសិទ្ធភាពនៅ ក្នុងការបង្រៀន។ សម្ភារៈឧបទេសបង្រៀនអំណានមានភាពចាំបាច់ណាស់ដែលធានាបាននូវលទ្ធផលនៃ ការសិក្សា ព្រោះសម្ភារៈឧបទេស បានជួយសម្រួលដល់ការបញ្ជ្រាបចំណេះដឹងពីគ្រូទៅសិស្សបានយ៉ាង ឆាប់រហ័ស និងជួយដល់ដំណើរការប្រព្រឹត្តទៅនៃការអនុវត្តវិធីសាស្ត្របង្រៀនរបស់គ្រូឱ្យកាន់តែមាន ប្រសិទ្ធភាពសព្វជ្រុងជ្រោយ។ ការបង្រៀនមុខវិជ្ជាភាសាខ្មែរ ពិតជាចាំបាច់ដែលទាមទារឱ្យគ្រូបង្រៀនមាន មាវត្ថុតាងជាក់ស្ដែង មកបង្ហាញ និងពន្យល់ដល់សិស្សក្នុងពេលបង្រៀនដើម្បីឱ្យសិស្សទទួលបានចំណេះ ដឹងពិតប្រាកដ។ យោងតាមសៀវភៅកម្មវិធីសិក្សាលម្អិតមុខវិជ្ជាភាសាខ្មែរកម្រិតបឋមសិក្សា(២០១៨) បានលើកឡើងថា ″សម្ភារៈឧបទេសជាមធ្យោបាយ និងជាលក្ខណចំបាច់សម្រាប់ប្រើប្រាស់ក្នុងដំណើរការ រៀន និងបង្រៀនប្រកបដោយប្រសិទ្ធភាព។ ដូច្នេះសម្ភារៈឧបទេស គឺជាធនធានទាំងឡាយដែលគ្រូ និង

សិស្សយកមកប្រើប្រាស់ក្នុងដំណើរការរៀន និងបង្រៀនដើម្បីឱ្យខ្លឹមសារមេរៀនកាន់តែជាក់លាក់ ច្បាស់លាស់ ងាយយល់ ងាយចាប់បាន ហើយអាចសម្រេចវត្ថុបំណងមេរៀនបានល្អប្រសើរ"។ បន្ថែមលើសពីនេះទៀតនោះសម្ភារៈសិក្សាដែលបានរៀបចំដើម្បីបង្រៀនអំណានក៏ត្រូវតែ "ងាយរក ងាយផលិត និងប្រើប្រាស់ប្រកបដោយគុណភាពនិងប្រសិទ្ធភាព" ទើបជានាបានដល់កិច្ចការប្រើប្រាស់សម្ភារៈសិក្សាក្នុងពេលបង្រៀនផងដែរ។ សម្ភារៈសិក្សាដែលមានគុណភាព និងការតែងលំអសម្ភារៈឱ្យមានការទាកទាញក៏បានលើកទឹកចិត្តឱ្យគ្រូមានភាពពេញចិត្តកាន់តែប្រសើរឡើងក្នុងការបង្រៀនអំណានមុខវិជ្ជាភាសាខ្មែរ ផ្តល់ភាពរីករាយក្នុងល្បែងសិក្សាលើអំណាន ព្រមទាំងសិស្សានុសិស្សចង់សិក្សានិងខិតខំរៀនមុខវិជ្ជាអំណាន ដើម្បីបានជាទុន បន្តការរៀនសូត្រទៅភូមិសិក្សាបន្ទាប់ ឆ្លើយតបទៅនឹងក្របខ័ណ្ឌកម្មវិធីសិក្សាអប់រំពលរដ្ឋពេញលេញរបស់ក្រសួងអប់រំ យុវជន និងកីឡា ផងដែរ។

សម្ភារៈឧបទេសបង្រៀនអំណានមុខវិជ្ជាភាសាខ្មែរមានសារៈសំខាន់ណាស់ ក្នុងការផ្តល់មូលដ្ឋានគ្រឹះអំណានដល់សិស្ស។ ការបង្រៀនអំណានដែលមិនបានប្រើប្រាស់សម្ភារៈឧបទេសបង្រៀន នាំឱ្យដំណើរការបង្រៀនមិនប្រសិទ្ធភាព លទ្ធផលការបង្រៀនមិនបានឆ្លើយតបនិងវត្ថុបំណងរបស់មេរៀន។ ដើម្បីឱ្យការបង្រៀនអំណានមុខវិជ្ជាភាសាខ្មែរមានប្រសិទ្ធភាព គ្រូបង្រៀនគប្បីរៀបចំសម្ភារៈឧបទេសបង្រៀនឱ្យមានភាពទាក់ទាញប្រកបដោយគុណភាពព្រមទាំងយកទៅប្រើប្រាស់ឱ្យឆ្លើយតបទៅនឹងខ្លឹមសារមេរៀន។ គ្រូបង្រៀនដែលមានសម្ភារៈឧបទេសបង្រៀនអំណានជាប្រចាំ ជួយសិស្សឱ្យទទួលបានជំនាញអំណាន និងអានដោយយល់ន័យ ព្រមទាំងមានភាពច្បាស់លាស់ក្នុងការបង្រៀនភាសាខ្មែរ រួមទាំងបំណិនក្នុង ការស្គាល់សូរ ព្យញ្ជនៈ ស្រៈ ការប្រកបព្យាង្គឬពាក្យ អានល្បះ និងអត្ថបទ និងការយល់ន័យអត្ថបទ ដែលជាមូលដ្ឋានគ្រឹះនៃការសិក្សាភាសាខ្មែរនៅកម្រិតបឋមសិក្សា។

## ៤.៤. ទិន្នន័យឆ្លើយតបរបស់គ្រូទៅលើភាពខុសគ្នារវាងការបង្រៀនអំណានមុខវិជ្ជាភាសាខ្មែរ និងមុខវិជ្ជាផ្សេង

*តារាង៤.១១៖ . ទិន្នន័យពីគ្រូអំពីភាពខុសគ្នារវាងការបង្រៀនអំណាន និងមុខវិជ្ជាផ្សេង*

| ល.រ | បរិយាយ | មធ្យមភាគ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | មានការរៀបចំ ទិវាអំណានជាតិ | 4.25 | 0.57 | ខុសគ្នា |
| ២ | គ្រូបង្រៀន មានស្មារតីសហការចូលរួមលើកកម្ពស់ភាសាខ្មែរ | 4.32 | 0.47 | ខុសគ្នា |
| ៣ | វិធីសាស្ត្របង្រៀនអំណានមាននិយាមច្បាស់លាស់ | 4.24 | 0.50 | ខុសគ្នា |
| ៤ | មានការបែងចែកម៉ោងអំណាន នៅបណ្ណាល័យ | 4.32 | 0.56 | ខុសគ្នា |
| ៥ | អំណានភាសាខ្មែរ មានចំនួនម៉ោងសិក្សាច្រើនលើក្របខ័ណ្ឌកម្មវិធីសិក្សា | 3.87 | 0.99 | ដូចគ្នា |
| | **សរុប** | **4.20** | **0.62** | **ខុស** |

តារាង៤.១១បង្ហាញថា មធ្យមភាគសរុបដែលបង្ហាញពីភាពខុសគ្នារវាងការបង្រៀនអំណាន និងមុខវិជ្ជាដទៃទៀត របស់គ្រូនៅក្នុងខេត្តព្រៃវែង គឺទទួលបានការយល់ស្របក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= 4.20 )។ សូចនាករ "គ្រូបង្រៀន មានស្មារតីសហការចូលរួមលើកកម្ពស់ភាសាខ្មែរ" និង "មានការបែងចែកម៉ោងអំណាន នៅបណ្ណាល័យ" ទទួលបានការយល់ស្របខ្ពស់ជាងគេ ក្នុងដំណើរការសិក្សារបស់សិស្ស ដែលលោកគ្រូ-អ្នកគ្រូបានអនុវត្តក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ= 4.32) និងសូចនាករ "អំណានភាសាខ្មែរ មានចំនួនម៉ោងសិក្សាច្រើនលើក្របខ័ណ្ឌកម្មវិធីសិក្សា" ទទួលបានការយល់ស្របទាបជាងគេក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= 3.87)។

***តារាង៤.១២៖ ទិន្នន័យពីគណៈគ្រប់គ្រងអំពីភាពខុសគ្នារវាងការបង្រៀនអំណាន និងមុខវិជ្ជាផ្សេង***

| ល.រ | បរិយាយ | មធ្យមភាគ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | មានការរៀបចំ ទិវាអំណានជាតិ | 4.22 | 0.43 | ខុសគ្នា |
| ២ | គ្រូបង្រៀន មានស្មារតីសហការចូលរួមលើកកម្ពស់ភាសាខ្មែរ | 4.22 | 0.73 | ខុសគ្នា |

| | | | | |
|---|---|---|---|---|
| ៣ | វិធីសាស្ត្របង្រៀនអំណានមាននិយាមច្បាស់លាស់ | 4.17 | 0.71 | ខុសគ្នា |
| ៤ | មានការបែងចែកម៉ោងអំណាន នៅបណ្ណាល័យ | 4.22 | 0.94 | ខុសគ្នា |
| ៥ | អំណានភាសាខ្មែរ មានចំនួនម៉ោងសិក្សាច្រើនលើ ក្របខ័ណ្ឌកម្មវិធីសិក្សា | 4.00 | 0.91 | ដូចគ្នា |
| | **សរុប** | **4.17** | **0.74** | **ល្អ** |

តារាង៤.១២បង្ហាញថា មធ្យមភាគសរុបដែលបង្ហាញពីភាពខុសគ្នារវាងការបង្រៀនអំណាន និង មុខវិជ្ជាដទៃទៀត របស់គណៈគ្រប់គ្រងសាលានៅក្នុងខេត្តព្រៃវែង គឺទទួលបានការយល់ស្របក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= 4.17)។ សូចនាករ "មានការរៀបចំ ទិវាអំណានជាតិ", "គ្រូបង្រៀន មានស្មារតីសហការចូលរួមលើកកម្ពស់ភាសាខ្មែរ" និង "មានការបែងចែកម៉ោងអំណាននៅបណ្ណាល័យ" ទទួលបានការយល់ស្របខ្ពស់ជាងគេក្នុងដំណើរការសិក្សារបស់សិស្សដែលលោកគ្រូ-អ្នកគ្រូបានអនុវត្តក្នុងកម្រិត "ល្អណាស់"(មធ្យមភាគពិន្ទុ= 4.22)ដូចគ្នា។ សូចនាករ"អំណានភាសាខ្មែរមានចំនួនម៉ោងសិក្សាច្រើនលើក្របខ័ណ្ឌកម្មវិធីសិក្សា" ទទួលបានការយល់ស្របទាបជាងគេក្នុងកម្រិត "ល្អ"(មធ្យមភាគពិន្ទុ= 4.00)។

## ៤.៥. ការពិភាក្សាលើភាពខុសគ្នារវាងការបង្រៀនអំណានមុខវិជ្ជាភាសាខ្មែរ និងមុខវិជ្ជាផ្សេង

ការអប់រំបានបណ្ដុះស្មារតីដល់ពលរដ្ឋគ្រប់រូប នៅក្នុងភពផែនដីនេះ។ ការអប់រំអាចនឹងកើតឡើងទៅបាននោះទាមទារការបង្រៀន និងដំណើរការរៀនដោយឆ្លុះបញ្ចាំងទៅលើក្របខ័ណ្ឌនៃការបញ្ជ្រាបចំណេះដឹង ជំនាញ និងឥរិយាបថ។ ការបង្រៀនទាមទារការរៀបចំទុកជាមុននូវ កិច្ចតែងការបង្រៀន និងសម្ភារៈបង្រៀនផ្សេងៗ ដើម្បីជួយឱ្យដំណើរការបង្រៀនទទួលបានលទ្ធផលសិក្សាខ្ពស់តាមរយៈលទ្ធផលសិក្សារបស់សិស្ស។ នៅក្នុងកម្រិតបឋមសិក្សាមានមុខវិជ្ជាសំខាន់ៗបួនដូចជា ភាសាខ្មែរ គណិតវិទ្យា វិទ្យាសាស្ត្រ និងសិក្សាសង្គម។ ក្នុងន័យនេះការបង្រៀនមុខវិជ្ជាភាសាខ្មែរ និងមុខវិជ្ជាសិក្សាសង្គមមានការខុសប្លែកគ្នាពីមុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រជាដើម។ ក្នុងការទទួលបន្ទុកលើដំណើរការប្រព្រឹត្តទៅ

នៃការអនុវត្តកម្មវិធីសិក្សាថ្នាក់បឋមសិក្សា គ្រូទាមទារឱ្យមានការបែងចែកឱ្យច្បាស់រវាងការបង្រៀនមុខវិជ្ជាភាសាខ្មែរដែលផ្ដោតទៅលើអំណាន និងមុខវិជ្ជាគណិតវិទ្យាដែលផ្ដោតលើការគណនាលេខ។

***តារាង៤.១៣៖ . ទិន្នន័យលើការពិភាក្សាអំពីភាពខុសគ្នារវាងការបង្រៀនអំណាន និងមុខវិជ្ជាដទៃ***

| ល.រ | បរិយាយ | មធ្យមភាគ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | ទិន្នន័យសរុបពីគ្រូ លើចំណុចខុសគ្នា រវាងការបង្រៀនអំណានវិជ្ជាភាសាខ្មែរនិងមុខវិជ្ជាផ្សេង | 4.20 | 0.62 | ខុសគ្នា |
| ២ | ទិន្នន័យសរុបពីគណៈគ្រប់ លើចំណុចខុសគ្នា រវាងការបង្រៀនអំណានវិជ្ជាភាសាខ្មែរនិងមុខវិជ្ជាផ្សេង | 4.17 | 0.74 | ខុសគ្នា |
| | **សរុប** | **4.18** | **0.68** | **ល្អ** |

តាមតារាង៤.១៣ បង្ហាញពីទិន្នន័យការបង្រៀនអំណានមុខវិជ្ជាភាសាខ្មែរមានភាពដូចគ្នាជាមួយមុខវិជ្ជាផ្សេង ទៅលើក្របខ័ណ្ឌកម្មវិធីសិក្សានៅកម្រិតបឋមសិក្សាដែលមុខវិជ្ជាភាសាខ្មែរ និងមុខវិជ្ជាផ្សេងមានម៉ោងសិក្សាចំនួន ៣៥ សប្ដាហ៍ក្នុង១ឆ្នាំសិក្សា ១ សប្ដាហ៍ ៣០ ម៉ោង ១ ថ្ងៃ ៥ ម៉ោងសិក្សា និង១ម៉ោងសិក្សាមានរយៈពេល ៤០នាទីដូចគ្នា យោងតាមសៀវភៅក្របខណ្ឌកម្មវិធីសិក្សាអប់រំចំណេះទូទៅនិងអប់រំបច្ចេកទេស (២០១៥)។ តាមទិន្នន័យឆ្លើយពីគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលា បានបង្ហាញផងដែរថាការបង្រៀនអំណានមុខវិជ្ជាភាសាខ្មែរពិតជាមានភាពខុសប្លែកគ្នាជាមួយមុខវិជ្ជាដទៃនៅក្នុងកម្រិតបឋមសិក្សា ដែលការបង្រៀនអំណានមាន ប្រារព្ធទិវាជាតិអំណានរៀងរាល់ឆ្នាំដើម្បីលើកកម្ពស់ដល់ការអាន គ្រូបង្រៀនមានស្មារតីសហការចូលរួមលើកកម្ពស់ដល់ការភាសាខ្មែររបស់សិស្សានុសិស្ស ការបង្រៀនអំណានមានវិធីសាស្ត្របង្រៀនច្បាស់លាស់តាមនិយាមនៃក្បួនប្រកប ព្យាង្គ ពាក្យ ស្រៈ ព្យញ្ជនៈច្បាស់លាស់ និងមានបែងចែកម៉ោងអំណានទៅរៀនក្នុងបណ្ណាល័យបន្ថែមទៀត។ ចំពោះមុខវិជ្ជាដទៃយកមកបង្រៀននៅកម្រិតបឋមសិក្សាដូចគ្នា មិនមានសកម្មភាពទាំងនោះដូចអំណានមុខវិជ្ជាភាសាខ្មែរឡើយ។ ទាំងនេះស្តែងឱ្យឃើញថា មុខវិជ្ជាអំណានត្រូវបានផ្តល់យកចិត្តទុកដាក់យ៉ាងខ្លាំងនៅក្នុងដំណើរការសិក្សារៀនសូត្ររបស់សិស្សនៅកម្រិតបឋមសិក្សា ដើម្បីជំរុញគ្រប់ចលនាអំណានតាមរយៈ ការប្រារព្ធទិវាអំណានថ្នាក់ជាតិ

ដើម្បីលើកកម្ពស់ដល់ការសិក្សាអំណានរបស់សិស្សឱ្យកាន់តែប្រសិទ្ធភាព មានការយកចិត្តទុកដាក់ពិសេសដើម្បីជំរុញចលនាគ្រប់ផ្នែកទាំងអស់នៅក្នុងសង្គមឱ្យជួយគាំទ្រអំណានភាសាខ្មែរ និងឆ្លើយតបទៅនឹងការសិក្សាពេញមួយជីវិត យោងតាមអនុក្រឹតស្តីពីការប្រារព្ធជាតិអំណាន(២០១៥)។ គ្រូបង្រៀនមានស្មារតីសហការចូលរួមលើកកម្ពស់ការសិក្សាមុខវិជ្ជាភាសាខ្មែរដែលជាផ្នែកមួយដ៏សំខាន់នៅក្នុងការគាំទ្រដល់ប្រសិទ្ធភាពនៃការសិក្សាអំណានរបស់សិស្សឱ្យកាន់តែចាប់អារម្មណ៍ក្នុងការសិក្សាអំណានមុខវិជ្ជាភាសាខ្មែរ ដែលជាមុខវិជ្ជាមូលដ្ឋានគ្រឹះនៅក្នុងការចាប់ផ្តើមនៃការបង្រៀនមេរៀននៅកម្រិតបឋមសិក្សា យោងតាមសៀវភៅក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅនិងអប់រំបច្ចេកទេស(២០១៥)។ និយាមនៅការបង្រៀនអំណានមុខវិជ្ជាភាសាខ្មែរក៏មានភាពចាំបាច់ ដែលតម្រូវឱ្យឱ្យគ្រូបង្រៀនមានការយកចិត្តទុកដាក់ទៅលើក្របខណ្ឌនៃការប្រើប្រាស់វិធីសាស្ត្របង្រៀនអំណានមុខវិជ្ជាភាសាខ្មែរ និងទាមទារឱ្យគ្រូបង្រៀនមានភាពច្បាស់លាស់ទៅលើ ការស្គាល់សូរ ព្យញ្ជនៈ ស្រៈ ការអានព្យញ្ជនៈ ស្រៈ ស្គាល់វេវចនសព្ទ សទិសសព្ទជាដើម យោងតាមសៀវភៅណែនាំគ្រូ សម្រាប់បង្រៀនថ្នាក់ទី១(២០២០)។ ក្នុងដំណើរការសិក្សាអំណានមុខវិជ្ជាភាសាខ្មែរឱ្យកាន់តែមានភាពទាក់ទាញផងនោះគ្រូបង្រៀននិងគណៈគ្រប់គ្រងសាលាក៏មានការបែងម៉ោងអំណាននៅក្នុងបណ្ណាល័យ ដើម្បីផ្លាស់ប្តូរបរិយាកាសនៃការសិក្សាអំណាន និងជួយលើកកម្ពស់ដល់ការសិក្សាអំណានឱ្យកាន់តែមានប្រសិទ្ធភាព យោងតាមសៀវភៅស្តង់ដាបណ្ណាល័យបឋមសិក្សា(២០១១)។

ក្នុងន័យរួម កម្មវិធីសិក្សាមុខវិជ្ជាភាសាខ្មែរ មានភាពដូចគ្នាជាមួយមុខវិជ្ជាផ្សេងទៀត ទៅលើចំនួនសប្តាហ៍ក្នុងរយៈពេលមួយឆ្នាំសិក្សាដែលមានចំនួន ៣៥សប្តាហ៍។ ការបែងចែកកម្មវិធីសិក្សាលម្អិត កាលវិភាគ និងវិធីសាស្ត្របង្រៀន ត្រូវបានអនុវត្តតាមនិយាម និងក្របខ័ណ្ឌដូចគ្នាជាមួយមុខវិជ្ជាផ្សេងទៀតផងដែរ។ ការបង្រៀនអំណានមុខវិជ្ជាភាសាខ្មែរមានភាពខុសគ្នាជាមួយមុខវិជ្ជាផ្សេងលើ ក្របខណ្ឌបច្ចេកទេសតាមរយៈការបញ្ជ្រៀបចំណេះដឹងដល់សិស្សចាប់ពីការស្គាល់សូរអក្សរ ទំនាក់ទំនងសូរនិងតួអក្សរ ការផ្សំតួអក្សរដើម្បីអានព្យាង្គឬពាក្យ ការផ្គុំពាក្យដើម្បីអានល្បះខ្លីៗ និងឈានទៅដល់ការអានអត្ថបទជាដើម។ គ្រូបង្រៀនត្រូវមានវិធីសាស្ត្រផ្សេងៗ ក្នុងការផ្តល់ជំនាញនៃការអានរបស់សិស្ស ដោយផ្តោតលើសូរ និងអក្ខរ

ក្រុម ព្រមទាំងមានបំរុងប្រយ័ត្នលើឥរិយាបថនៃការចូលរួមក្នុងការសិក្សាអំណានភាសាខ្មែររបស់សិស្សានុសិស្សក្នុងថ្នាក់រៀន និងកិច្ចការផ្ទះផងដែរ។ លើសពីនេះទៅទៀតនោះ ការបង្រៀនអំណានមុខវិជ្ជាភាសាខ្មែរ មានប្រារព្ធកម្មវិធីទិវាជាតិអំណានដែលបានកំណត់យកថ្ងៃទី១១ ខែមីនា ជារៀងរាល់ឆ្នាំដើម្បីរៀបចំដំណើរការនៃការអាននៅគ្រប់ទីកន្លែង គ្រប់ស្ថាប័ននៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងបណ្តុះទម្លាប់អាន ជំរុញវប្បធម៌អាន លើកកម្ពស់សមត្ថភាពអាននិងការតែងនិពន្ធរួមចំណែកការងារនិងពង្រឹងវប្បធម៌ខ្មែរ។ វិធីសាស្រ្តបង្រៀនអំណានមុខវិជ្ជាភាសាខ្មែរមាននិយាមច្បាស់លាស់ ជាងមុខវិជ្ជាផ្សេងដែលក្បួនខ្នាតនៃការបង្រៀន ការស្គាល់សូរ ព្យញ្ជនៈ ស្រៈ ការអានព្យញ្ជនៈ ស្រៈ ការអានព្យាង្គ ពាក្យវេយ្យាករណ៍ ស្គាល់វេវចនសព្ទ និងសទិសសព្ទជាដើម។ ដោយឡែកការបង្រៀនអំណានមុខវិជ្ជាភាសាខ្មែរមានម៉ោងបណ្ណាល័យសម្រាប់ផ្លាស់ប្តូរបរិយាកាសសិក្សាពីក្នុងថ្នាក់ទៅសិក្សាបន្ថែមនៅក្នុងបណ្ណាល័យដែលផ្តល់ភាពរីករាយដល់សិស្សានុសិស្សក្នុងរៀនសូត្រ ក៏ដូចជាបង្កឱកាសការសិក្សាក្នុងសាលារៀនដែលជាថ្នាល បណ្តុះចំណេះដឹង និងមូលធនមនុស្សទៅពេលអនាគត ស្របតាមកម្មវិធីសិក្សាអប់រំពេលរដ្ឋពេលលេញ ក៏ដូចជាការចូលរួមជំរុញកម្លាំងពលកម្មតាមរយៈវិស័យអប់រំ សំដៅលើកម្ពស់ខឿនសេដ្ឋកិច្ចជាតិក្នុងទិសដៅឆ្នាំ២០៣០ និងឆ្នាំ២០៥០ ផងដែរ។

# ជំពូកទី៥
# សេចក្ដីសន្និដ្ឋាន និងសំណូមពរ

## ៥.១.សេចក្ដីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទ ការវាយតម្លៃទៅលើការបង្រៀនរបស់គ្រូ ស្ដីពីអំណាននៅកម្រិតបឋមសិក្សាក្នុងខេត្តព្រៃវែង ក្នុងគោលបំណងសិក្សាទៅលើបញ្ហាប្រឈមរបស់គ្រូក្នុងការបង្រៀនអំណានមុខវិជ្ជាភាសាខ្មែរនៅសាលាកម្រិតបឋមសិក្សាក្នុងខេត្តព្រៃវែង និងចំណុចខុសគ្នារវាងការបង្រៀនអំណានមុខវិជ្ជាភាសាខ្មែរ និងមុខវិជ្ជាផ្សេងៗ តាមរយៈការសិក្សាស្រាវជ្រាវពីគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀន នៅក្នុងខេត្តព្រៃវែង បានរកឃើញថាការបង្រៀនអំណានមុខវិជ្ជាភាសាខ្មែរស្ថិតក្នុងកម្រិតល្អ ដែលទទួលបានមធ្យមភាគ ៤.១៣ ឆ្លុះបញ្ចាំងថាគ្រូបង្រៀនបានអនុវត្តស្របតាមកម្មវិធីសិក្សា គ្រូមានទស្សនៈវិស័យក្នុងការលើកកម្ពស់គុណភាពបង្រៀនអំណាន ដោយស្រាវជ្រាវបន្ថែមលើការបង្រៀនអំណាន រៀបចំកិច្ចតែងការបង្រៀនអំណាន ធ្វើបំណែងចែកកម្មវិធីសិក្សាអំណាន ជំរុញសិស្សក្នុងការប្រើប្រាស់សៀវភៅសិក្សាគោលក្នុងសកម្មភាពអាន មានទំនួលខុសត្រូវក្នុងការគោរពពេលវេលា និងបង្រៀនអំណានស្របតាមកម្មវិធីសិក្សា។ លើសពីនេះគ្រូបង្រៀននៅក្នុងខេត្តព្រៃវែង ក៏មានភាពបត់បែននៅក្នុងការប្រើប្រាស់វិធីសាស្ត្របង្រៀនអំណានស្របតាមស្ថានភាព និងកម្រិតសិក្សាបស់សិស្សតាមកម្រិតថ្នាក់នីមួយៗដើម្បីធានាដល់លទ្ធផលសិក្សារបស់សិស្សទទួលបានលទ្ធផលល្អ។ មិនតែប៉ុណ្ណោះគ្រូបង្រៀនក៏មានស្មារតីលើកកម្ពស់ដល់ដំណើរការសិក្សាអំណានលើមុខវិជ្ជាភាសាខ្មែររបស់សិស្សានុសិស្ស ដោយមានបង្កើតសកម្មភាពផ្សេងៗនៅក្នុងថ្នាក់ និងក្រៅថ្នាក់ដូចជា បង្កើតបរិយាកាសឱ្យសិស្សហ៊ានសួរគ្រូនៅពេលពួកគេអានពាក្យពិបាកមិនរួច សកម្មភាពសិស្សជួយសិស្ស សកម្មភាពអំណានផ្សេងៗ និងការប្រកួតប្រជែងអំណាន។ ក្នុងចំណុចវិជ្ជមានរបស់គ្រូបង្រៀន អំណានមុខវិជ្ជាភាសាខ្មែរដែលបានបំពេញក្នុងកម្រិតល្អហើយនោះ ក៏នៅមានចំណុចដែលតម្រូវឱ្យមានការលើកកម្ពស់ គឺការរៀបចំ និងប្រើប្រាស់សម្ភារឧបទេសបង្រៀនអំណាន។ គ្រូបង្រៀនអំណានមុខវិជ្ជាភាសាខ្មែរដែលមិនបាន ប្រើប្រាស់សម្ភារឧបទេសបង្រៀនសម្រាប់បង្រៀនអំណានជាប្រចាំ ធ្វើឱ្យប៉ះពាល់ដល់គុណភាពសិក្សាអំណានមុខវិជ្ជាភាសាខ្មែរនៅ

កម្រិតបឋមសិក្សា ដែលសិស្សានុសិស្សទាមទារឱ្យគ្រូចាំបាច់ប្រើប្រាស់សម្ភារៈបង្រៀនដើម្បីទទួលបានចំណេះដឹង និងជំនាញលើការសិក្សាអំណាន ពិសេសការអានព្យញ្ជនៈ ស្រៈ និងការប្រកប។ សម្ភារៈទៀតសោតគប្បី មានភាពទាក់ទាញចិត្តសិស្សឱ្យមានការចាប់អារម្មណ៍ ព្រមទាំងបង្កើតបរិយាកាសសប្បាយរីករាយក្នុងការសិក្សារៀនសូត្រ និងមានបច្ចេកទេសក្នុងការប្រើប្រាស់សម្ភារៈបង្រៀនពីរូបីទៅពាក់កណ្ដាលរូបី ពីពាក់កណ្ដាលរូមបីទៅអរូបី ដើម្បីធានាឱ្យការបង្រៀនមេរៀនមានប្រសិទ្ធភាព និងប្រសិទ្ធផល។ នៅក្នុងដំណើរការបង្រៀនអំណានមុខវិជ្ជាភាសាខ្មែរនៅកម្រិតបឋមសិក្សា ក៏មានភាពខុសប្លែកគ្នាជាមួយមុខវិជ្ជាគណិតវិទ្យា វិទ្យាសាស្ត្រ និងសិក្សាសង្គម ដូចជាការបង្រៀនអំណានមុខវិជ្ជាភាសាខ្មែរមានការបែងចែកកម្មវិធីបង្រៀនទាំងក្នុងថ្នាក់រៀន និងម៉ោងបណ្ណាល័យ ដោយមានវិធីសាស្ត្របង្រៀនអំណានតាមនិយាមច្បាស់លាស់ ដែលជួយជំរុញឱ្យសិស្សមានឱកាសក្នុងការអភិវឌ្ឍជំនាញអានរបស់ខ្លួនបានល្អក្នុងដំណើរការសិក្សាអំណាន ព្រមទាំងផ្ដល់បានលទ្ធផលសិក្សាបានល្អ។ មិនតែប៉ុណ្ណោះអំណានមុខវិជ្ជាភាសាខ្មែរក៏មានស្មារតីសហការពីគ្រូបង្រៀនក្នុងការលើកកម្ពស់ការអានភាសាខ្មែរ ដោយបណ្ដុះក្ដីស្រលាញ់ការយកចិត្តទុកដាក់ក្នុងការជួយលើកកម្ពស់ដល់វប្បធម៌អានភាសាខ្មែរនៅក្នុងព្រឹត្តិការអំណាននៅតាមសាលារៀន ឬ ព្រឹត្តិការអំណានជាតិជាដើម។

សរុបសេចក្ដីមក ការបង្រៀនអំណានមុខវិជ្ជាភាសាខ្មែររបស់គ្រូបង្រៀននៅក្នុងខេត្តព្រៃវែងមានកម្រិតល្អ លើការអនុវត្តលើក្របខ័ណ្ឌកម្មវិធីសិក្សាអំណានស្របតាមការកំណត់របស់ក្រសួង គ្រូបង្រៀនមានវិធីសាស្ត្របង្រៀនអំណានសម្បូរបែបស្របតាមស្ថានភាពសិក្សារបស់សិស្ស ពិសេសគ្រូបង្រៀនមានភាពបត់បែនលើការប្រើប្រាស់វិធីសាស្ត្របង្រៀនតាមកាលៈទេសៈ ដើម្បីធានាបាននូវប្រសិទ្ធភាពនៃការបង្រៀនពិតប្រាកដ លើសពីនេះសិស្សានុសិស្សនៅកម្រិតបឋមសិក្សាមានស្មារតីក្នុងសិក្សាអំណានមុខវិជ្ជាភាសាខ្មែរដោយយកចិត្តទុកដាក់ក្នុងរៀនសូត្រទាំងនៅក្នុងថ្នាក់ បណ្ណាល័យ និងចូលរួមព្រឹត្តិការណ៍ប្រគួតប្រជែងអំណានផងដែរ។ ការបង្រៀនអំណានមុខវិជ្ជាភាសាខ្មែរ នៅក្នុងខេត្តព្រៃវែងក៏នៅមានបញ្ហាប្រឈមទៅលើការរៀបចំ និងប្រើប្រាស់សម្ភារឧបទេសបង្រៀនអំណាន ដែលគួរតែត្រូវពង្រឹងបន្ថែមតាមរយៈការផ្ដល់សម្ភារឧបទេសដល់សាលារៀនដើម្បីប្រើប្រាស់ក្នុងការបង្រៀនអំណាន ផ្ដល់វគ្គបំប៉នដល់គ្រូបង្រៀន

ក្នុងកម្រិតបឋមសិក្សាឱ្យចេះពីរបៀបរៀបចំសម្ភារឧបទេសបង្រៀនអំណាន និងមានការជំរុញ និងលើកទឹកចិត្តដល់គ្រូបង្រៀនពីគ្រប់ភាគីពាក់ព័ន្ធក្នុងការធានានូវការផលិតសម្ភារៈបង្រៀនអំណានជាប្រចាំ ដើម្បីធ្វើឱ្យដំណើរការបង្រៀនដើម្បីផ្តល់ឱ្យនូវសក្តានុពលនៃភាសាខ្មែរ ក៏ដូចជាការឆ្លុះបញ្ចាំងនៃអត្តកម្មរបស់ជាតិផងដែរ។

## ៥.២.សំណូមពរ

តាមរយៈការសិក្សាស្រាវជ្រាវលើប្រធានបទ ការវាយតម្លៃទៅលើការបង្រៀនរបស់គ្រូ ស្តីពីអំណាននៅកម្រិតបឋមសិក្សាក្នុងខេត្តព្រៃវែង បានរកឃើញនូវចំណុចល្អ និងបញ្ហាប្រឈមដែលគ្រូបង្រៀនជួបប្រទះនៅក្នុងដំណើរការបង្រៀនអំណានមុខវិជ្ជាភាសាខ្មែរដែលទាមទារឱ្យមានកិច្ចសហការ ការជំរុញលើកកម្ពស់ និងពង្រឹងបន្ថែមដើម្បីឱ្យការបង្រៀនអំណានលើមុខវិជ្ជាភាសាខ្មែរនៅកម្រិតបឋមសិក្សាក្នុងខេត្តព្រៃវែងរឹតតែមានប្រសិទ្ធភាព។ អ្នកសិក្សាស្រាវជ្រាវ សូមលើកនូវសំណូមពរដូចខាងក្រោម៖

### ៥.២.១ ក្រសួងអប់រំ យុវជន និងកីឡា

- ពង្រឹងការដាក់ចេញនូវគោលនយោបាយស្តីពីអំណាន ដែលធានាបានថាគ្រប់គ្រូបង្រៀននៅតាមសាលាក្នុងកម្រិតបឋមសិក្សាបានយល់ច្បាស់អំពីគោលនយោបាយដែលក្រសួងបានដាក់ចេញ។
- ពង្រឹងការដាក់ចេញនូវក្របខ័ណ្ឌកម្មវិធីសិក្សាស្តីពីអំណាននៅកម្រិតបឋមសិក្សាឱ្យកាន់តែមានភាពច្បាស់លាស់។
- ផ្តល់វគ្គបំប៉នស្តីពីការផលិតសម្ភារឧបទេសបង្រៀនអំណាន តាមរយៈជំរុញកិច្ចសហការដៃគូរអភិវឌ្ឍន៍ និងសាលារៀន។

### ៥.២.២ មន្ទីរអប់រំ យុវជន និងកីឡាខេត្ត

- ជំរុញការអនុវត្តការបង្រៀនអំណានមុខវិជ្ជាភាសាខ្មែរនៅកម្រិតបឋមសិក្សា ឱ្យកាន់តែមានប្រសិទ្ធភាពតាមរយៈការចុះពិនិត្យតាមដានជាប្រចាំ។
- បន្តផ្តល់កិច្ចគាំទ្រដល់គណៈគ្រប់គ្រងសាលា និងគ្រូបង្រៀនក្នុងការផលិតសម្ភារឧបទេសបង្រៀនអំណាន ទាំងកញ្ចប់ថវិកា និងបច្ចេកទេស។

### ៥.២.៣ គណៈគ្រប់គ្រងសាលារៀន

- ពង្រឹងកិច្ចការដឹកនាំបង្ហាត់គ្រូបង្រៀនមុខវិជ្ជាភាសាខ្មែរ ច្នៃសម្ភារឧបទេសបង្រៀនអំណានតាមកម្រិតថ្នាក់ ដើម្បីជានាបានសម្ភារៈឧបទ្ទេសឆ្លើយតបមេរៀនអំណាន។

### ៥.២.៤ គ្រូបង្រៀនមុខវិជ្ជាភាសាខ្មែរ

- បង្កបរិយាកាសសិក្សារៀនសូត្រ អំណានមុខវិជ្ជាភាសាខ្មែរ លើសកម្មភាពថ្នាក់រៀនឆ្លុះបញ្ចាំងតាមរយៈសម្ភារៈឧបទ្ទេសនៃមេរៀននីមួយៗ។

### ៥.២.៥. សម្រាប់ការសិក្សាស្រាវជ្រាវបន្ត

តាមរយៈ ប្រធានបទការវាយតម្លៃទៅលើការបង្រៀនរបស់គ្រូ ស្ដីពីអំណាននៅកម្រិតបឋមសិក្សាក្នុងខេត្តព្រៃវែង មានវិសាលភាពទៅលើតែការបង្រៀនអំណានមុខវិជ្ជាភាសាខ្មែរ ហើយគ្របដណ្ដប់ទៅតែលើការបង្រៀនរបស់គ្រូខេត្តព្រៃវែង១ ប៉ុណ្ណោះ។ ការសិក្សាស្រាវជ្រាវបន្ត គួរធ្វើការសិក្សាអំពីប្រធានបទដែលទាក់ទងទៅនឹង៖

- សិក្សាប្រៀបធៀបលើប្រសិទ្ធភាពនៃការបង្រៀនមុខវិជ្ជាភាសាខ្មែរ និងការបង្រៀនមុខវិជ្ជាគណិតវិទ្យានៅកម្រិតបឋមសិក្សា ក្នុងខេត្តព្រៃវែង
- ស្ថានភាពនៃការអនុវត្តកម្មវិធីសិក្សាអប់រំពលរដ្ឋពេញលេញរបស់គ្រូបង្រៀន នៅសាលាបឋមសិក្សា ក្នុងខេត្តព្រៃវែង
- ការអនុវត្តគោលនយោបាយស្ដីពីអំណាន របស់សាលាបឋមសិក្សា ក្នុងខេត្តព្រៃវែង

# ឯកសារយោង


ក្រសួងអប់រំ យុវជន និងកីឡា (២០១៩) "ការរៀន និងបង្រៀនក្នុងបរិបទថ្មី"។ *វីដេអូផ្សព្វផ្សាយក្នុងបណ្តាញសង្គមយូធូប (YouTube)*។ បានទទួលពីថ្ងៃទី២០ តុលា ២០២០ ពីវេបសាយតំណភ្ជាប់ https://youtu.be/SDptC4hjWYk

ក្រសួងអប់រំ យុវជន និងកីឡា (២០១៩) *ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៩-២០២៣៖* ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡា។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៨) *ក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន៖* ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡា។

ក្រសួង អប់រំ យុវជន និងកីឡា (២០១៨) *នាយកដ្ឋានធានាគុណភាពអប់រំ៖ ក្របខ័ណ្ឌវាយតម្លៃលទ្ធផលសិក្សារបស់សិស្សកម្រិតមត្តេយ្យសិក្សា និងអប់រំចំណេះទូទៅ* ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡា។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៨) *កម្មវិធីសិក្សាលម្អិតមុខវិជ្ជាភាសាខ្មែរ៖ កម្រិតបឋមសិក្សា* ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡា។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៦) *នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រិតការ៖ ឯកសារជំនួយគ្រូឧទ្ទេសសម្រាប់បណ្តុះបណ្តាលគរុសិស្សនិងគ្រូស្តីពីស្តង់ដាអំណានថ្នាក់ទី១ ទី២ និងទី៣* ពេញ ក្រសួងអប់រំ យុវជន និងកីឡា។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៦) *ស្តង់ដាអំណានថ្នាក់ទី៣៖* ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡា។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៥)*នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា៖ក្របខណ្ឌកម្មវិធីសិក្សាអប់រំចំណេះទូទៅនិងបច្ចេកទេស* ភ្នំពេញក្រសួងអប់រំ យុវជន និងកីឡា។

ក្រសួងអប់រំ យុវជន និងកីឡា(២០១៥)*នាយកដ្ឋានធានាគុណភាពអប់រំ៖ តេស្តវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស* ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡា។

ក្រសួងអប់រំ យុវជន និងកីឡា(២០១៤)*ស្តង់ដាអំណាន ថ្នាក់ទី១៖* ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡា។

ក្រសួងអប់រំ យុវជន និងកីឡា(២០១៤) *ស្តង់ដាអំណាន ថ្នាក់ទី២៖* ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡា។

ក្រសួងអប់រំ យុវជន និងកីឡា(២០១១)*ស្តង់ដាបណ្ណាល័យបឋមសិក្សា៖* ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡា។

ខេម អេច អរ (២០២០) "អត្ថប្រយោជន៍ ១០យ៉ាងនៃការអានសៀវភៅ"។ *ព្រឹត្តិបត្រព័ត៌មាន ខេម អេច អរ (CamHR)*។ បានទទួលពីថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២០ ពីវេបសាយតំណភ្ជាប់ https://www.camhr.com/pages/articles/article.jsp?id=10003005

បណ្ឌិតសភាចារ្យ ណាត ប៊ុនរឿន (២០២០) *សន្ទរថាស្តីពីអត្ថប្រយោជន៍នៃអំណាន*។

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន (២០១៨) *សន្ទរកថាស្តីពីកំណែទម្រង់វិស័យអប់រំ សំដៅលើកកម្ពស់គុណភាពអប់រំ និងអភិវឌ្ឍធនធានមនុស្ស ស្របទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ២០១៥-២០៣០*។

ប៉ែន បូណា (២០១៣) "កង្វះមូលដ្ឋានគ្រឹះធ្វើឲ្យគុណភាពធនធានមនុស្សខ្សោយ"។ *វិទ្យុបារាំងអន្តរជាតិ Radio France International (RFI) Monde (២៦នាទី)*។ បានទទួលពីថ្ងៃទី១៥ ខែតុលា ឆ្នាំ ២០២០ ពីវេបសាយតំណភ្ជាប់ https://www.rfi.fr/km/analyse-Cambodge-manque-de-ressource-humaine

រាជរដ្ឋាភិបាលកម្ពុជា (២០១៥) *អនុក្រឹតស្តីពីទិវាជាតិអំណាន៖* ភ្នំពេញ រាជរដ្ឋាភិបាលកម្ពុជា។

សម្តេចព្រះសង្ឃរាជ ជួន ណាត (១៩៦៧) *វចនានុក្រមភាសាខ្មែរ* ៖ភ្នំពេញ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ លើកទី៥។

ឡាំ លីម (២០១៩)*អំណានជាអំណាច៖* ភ្នំពេញ។

អង្គការរូមធូរីដ (២០១៨) *ឯកសារជំនួយស្តីពីការគ្រប់គ្រងបណ្ណាល័យ* ៖ ភ្នំពេញ អង្គការរូមធូរីដ។

អង្គការរួមធូរីជ (២០១៧) *សកម្មភាពអំណានក្នុងម៉ោងបណ្ណាល័យ* ៖ ភ្នំពេញ អង្គការរួមធូរីជ។

អង្គការខុនសឺន(២០០៣) *ឯកសារណែនាំសម្រាប់សិក្ខាកាមៈ វគ្គបណ្តុះបណ្តាលស្តីពី ការត្រួតពិនិត្យ និងវាយតម្លៃ៖* ភ្នំពេញ អង្គការខុនសឺន។

Mcmahon, M., & Patton, W. (2002). Using qualitative assessment in career counselling. *International Journal for Educational and Vocational Guidance*, *2*(1), 51-66.

Mehrens, W.A., & Lehmann, I.J. (1969). Standardized tests in education.

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ "ក"

## កម្រងសំណួរស្រាវជ្រាវសម្រាប់លោកគ្រូ-អ្នកគ្រូ បង្រៀនអំណាន មុខវិជ្ជាភាសាខ្មែរនៅកម្រិតបឋមសិក្សាក្នុងខេត្តព្រៃវែង

ខ្ញុំបាទឈ្មោះ ចែម នី ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ នៅវិទ្យាស្ថានជាតិអប់រំ កំពុងសរសេរនិក្ខេបបទស្ដីពី "ប្រធានបទ ការវាយតម្លៃទៅលើការបង្រៀនរបស់គ្រូ ស្ដីពីអំណាន លើមុខវិជ្ជាភាសាខ្មែរនៅកម្រិតបឋមសិក្សាក្នុងខេត្តព្រៃវែង" ដើម្បីបញ្ចប់ការសិក្សា។

គោលបំណងនៃការប្រមូលទិន្នន័យនេះ គឺដើម្បីសិក្សាស្វែងយល់ពីការអនុវត្តកម្មវិធីសិក្សា និងដំណើរការបង្រៀនមុខវិជ្ជាភាសាខ្មែរ ដោយផ្ដោតលើកត្តាប្រឈម នៃការបង្រៀនអំណាន និងភាពខុសប្លែកគ្នា ជាមួយមុខវិជ្ជាផ្សេងទៀត ក្នុងក្របខ័ណ្ឌកម្មវិធីសិក្សាកម្រិតបឋមសិក្សា។ ទិន្នន័យទទួលបានពីលោក-លោកស្រី ជាគណៈគ្រប់គ្រង គឺដើម្បីយកទៅប្រើប្រាស់ក្នុងការសិក្សាស្រាវជ្រាវ ភាពជាក់លាក់នៃការវិភាគឆ្លើយតបទៅប្រធានបទខាងលើ។

ទិន្នន័យដែលប្រមូលបាននេះ គឺប្រើសម្រាប់តែសិក្សាស្រាវជ្រាវនេះតែប៉ុណ្ណោះ។ ក្នុងន័យនេះ សូមលោក-លោកស្រី មេត្តាជួយផ្ដល់ព័ត៌មានពិតជាក់ស្ដែង ដើម្បីឱ្យខ្ញុំបាទអាចមានទិន្នន័យ និងហេតុផលគ្រប់គ្រាន់តាមបែបវិទ្យាសាស្ត្រ ដើម្បីទាញអំណះអំណាងយកមកសិក្សា បកស្រាយទៅលើ ការសរសេរនិក្ខេបបទក្នុងការសិក្សាស្រាវជ្រាវ។

ខ្ញុំបាទ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការចូលរួម របស់លោកគ្រូ-អ្នកគ្រូ។

**ផ្នែកទី១៖ព័ត៌មានទូទៅ**

ការណែនាំ៖ សូមលោកគ្រូ អ្នកគ្រូ គូសសញ្ញា(✓)ក្នុងប្រអប់នីមួយៗខាងក្រោមទៅតាមស្ថានភាពជាក់ស្ដែងដូចខាងក្រោម។

១. ជាគ្រូបង្រៀនកម្រិតបឋមសិក្សា ដែលកំពុងបង្រៀន ☐ បាទ/ចាស ☐ ទេ

២. បម្រើការងានៅ៖............................................ឃុំ/សង្កាត់៖...........................................

ក្រុង/ស្រុក/ខណ្ឌ៖.......................................រាជធានី/ខេត្ត៖..................................................

៣. ភេទ ☐ ប្រុស ☐ ស្រី

៤. អាយុ ☐ ២០-៣០ ឆ្នាំ ☐ ៣១-៤០ឆ្នាំ☐ ៤១-៥០ឆ្នាំ ☐ លើពី៥០ឆ្នាំ

៥.កម្រិតវប្បធម៌ ☐ ចប់ថ្នាក់ទី១២ ☐ សញ្ញាបត្រទុតិយភូមិ ☐បរិញ្ញាបត្រ☐ បរិញ្ញាបត្រជាន់ខ្ពស់

៦.បទពិសោធន៍បង្រៀន៖ ☐ ១ ដល់ ១០ ឆ្នាំ ☐១១ទៅ២០ ឆ្នាំ ☐ ២១ទៅ៣០ឆ្នាំ☐លើសពី៣០ឆ្នាំ

៧. មុខវិជ្ជាឯកទេស/តួនាទី៖..................................................បង្រៀនថ្នាក់ទី៖..........................

## ផ្នែកទី២៖ អំពីបញ្ហាប្រឈមរបស់គ្រូក្នុងការបង្រៀនអំណាន លើមុខវិជ្ជាភាសាខ្មែរ នៅកម្រិតបឋមសិក្សា

ការណែនាំ៖ នៅក្នុងបទពិសោធន៍នៃការបង្រៀនអំណាន របស់លោកគ្រូ អ្នកគ្រូកន្លងមក តើគ្រូបង្រៀនអំណាន លើមុខវិជ្ជាភាសាខ្មែរនៅកម្រិតបឋមសិក្សា មានបញ្ហាប្រឈមអ្វីខ្លះ? សូមអានចំណុចនីមួយ ឱ្យបានច្បាស់លាស់ បន្ទាប់មកគូសសញ្ញា (✓) ទៅតាមកម្រិតនៃការពេញចិត្តរបស់លោកគ្រូ អ្នកគ្រូ ៖

កម្រិតចង្អុលបង្ហាញ៖

១. មិនយល់ស្របទាល់តែសោះ

២. មិនយល់ស្រប

៣. មិនមានយលបល់

៤. យល់ស្រប

៥. យល់ស្របខ្លាំង

| ល.រ | បរិយាយ | កម្រិតចង្អុលបង្ហាញ | | | | |
|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ |
| ក. ការអនុវត្តកម្មវិធីសិក្សា | | | | | | |
| ១ | កិច្ចតែងការបង្រៀនអំណានត្រូវបានត្រួតពិនិត្យជាប្រចាំពីគណៈគ្រប់គ្រងសាលារៀន | | | | | |
| ២ | បានរៀបចំកិច្ចតែងការបង្រៀនអំណានជាប្រចាំ | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ៣ | មានទស្សនៈវិស័យលើកកម្ពស់គុណភាពបង្រៀនអំណាន | | | | | |
| ៤ | បានស្រាវជ្រាវបន្ថែមលើការបង្រៀនអំណានភាសាខ្មែរ | | | | | |
| ៥ | បានរៀបចំបំណែងចែកកម្មវិធីសិក្សា ច្បាស់លាស់ | | | | | |
| ៦ | បានប្រើប្រាស់សៀវភៅពុម្ពសិក្សា | | | | | |
| ៧ | មានទំនួលខុសត្រូវក្នុងការគោរពពេលវេលា | | | | | |
| ៨ | ជារួម បានបង្រៀនអំណានស្របតាមកម្មវិធីសិក្សា | | | | | |
| **ខ. វិធីសាស្ត្របង្រៀន** | | | | | | |
| ១ | បង្ហាញវត្ថុបំណងមេរៀនអំណានច្បាស់លាស់ | | | | | |
| ២ | ទាញអារម្មណ៍សិស្សជាប្រចាំក្នុងពេលបង្រៀនអំណាន | | | | | |
| ៣ | ផ្តល់ការការណែនាំដល់សិស្ស លើចំណេះដឹងស្តីពីអំណាន | | | | | |
| ៤ | ផ្លាស់ប្តូរវិធីសាស្ត្រ ដោយបានលេងល្បែងសិក្សាពីអំណាន | | | | | |
| ៥ | បង្ហាញពី ការបញ្ចេញសំឡេង តាមអក្ខរក្រម | | | | | |
| ៦ | ពិនិត្យ និងផ្ទៀងផ្ទាត់លើសំណេរសិស្ស | | | | | |
| ៧ | បានបង្រៀនតាមបំណែងចែកកម្មវិធីសិក្សាមេរៀនភាសាខ្មែរ | | | | | |
| ៨ | បង្រៀនអំណានតាមកាលវិភាគ និងម៉ោងកំណត់ | | | | | |
| ៩ | បានណែនាំសិស្ស ចូលអានក្នុងបណ្ណាល័យជាប្រចាំ | | | | | |
| ១០ | បានពិនិត្យសិស្សក្នុងពេលអានជាក្រុម ឬជាដៃគូ ឬជាបុគ្គល | | | | | |
| ១១ | បានស្តាប់សិស្សអាន ព្រមទាំងបានជួយអានពាក្យពិបាក | | | | | |
| ១២ | បានបង្រៀនចប់មុខវិជ្ជាភាសាខ្មែរ តាមកម្មវិធីសិក្សាកំណត់ | | | | | |
| **គ. ការរៀបចំ និងប្រើប្រាស់សម្ភារឧបទេសសម្រាប់បង្រៀនអំណាន** | | | | | | |
| ១ | បានប្រើប្រាស់សម្ភារឧបទេស ក្នុងពេលបង្រៀនអំណានជាប្រចាំ | | | | | |
| ២ | សម្ភារឧបទេស បានជួយឱ្យសិស្សងាយស្រួលក្នុងការយល់ | | | | | |
| ៣ | ចេះប្រើប្រាស់ សម្ភារឧបទេសក្នុងការបង្រៀនអំណាន | | | | | |
| ៤ | សិស្សងាយយល់ពីតួអក្សរ និងពាក្យក្រោយពីប្រើសម្ភារឧបទេស | | | | | |
| ៥ | បានច្នៃប្រឌិតសម្ភារៈទាំងនោះឱ្យមានភាពទាក់ទាញ | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ៦ | សម្ភារៈដែលបានរៀបចំប្រកបដោយគុណភាព | | | | | |
| ៧ | បណ្ណាល័យមានសៀវភៅសិក្សា គ្រប់គ្រាន់ | | | | | |
| **ឃ. ការសិក្សាអំណានមុខវិជ្ជាភាសាខ្មែរ** | | | | | | |
| ១ | សិស្សអានដោយរីករាយ និងលឺៗ ជាក្រុម ឬជាដៃគូ ឬជាបុគ្គល | | | | | |
| ២ | សិស្សអានច្បាស់ៗ តាមលំដាប់នៃអក្ខរាវិរុទ្ធ | | | | | |
| ៣ | សិស្ស បានសួរគ្រូពីការអានពាក្យពិបាក | | | | | |
| ៤ | មានកម្មវិធីសិស្សជួយសិស្ស សំដៅជួយសិស្សជួបការលំបាកក្នុងការអាន | | | | | |
| ៥ | បានចូលរួមក្នុងការប្រកួតប្រជែងអំណាន | | | | | |
| ៦ | សិស្សចូលចិត្ត លើការសិក្សាអំណានភាសាខ្មែរ | | | | | |
| ៧ | សិស្សមានបម្រុងប្រយ័ត្ន ក្នុងពេលអានមេរៀន | | | | | |
| ៨ | សិស្សម្នាក់ៗ ទទួលបានលទ្ធផលសិក្សាល្អ លើអំណានភាសាខ្មែរ | | | | | |
| ៩ | សិស្សបានធ្វើកិច្ចផ្ទះ លើអំណានភាសាខ្មែរតាមបណ្ដាំធ្វើគ្រូ | | | | | |

**មតិយោបល់បន្ថែម៖**

ក. ការអនុវត្តកម្មវិធីសិក្សា

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

ខ. វិធីសាស្ត្របង្រៀន

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

គ.ការរៀបចំនិងប្រើប្រាស់សម្ភារឧបទេសសម្រាប់បង្រៀនអំណាន

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

ឃ.ការសិក្សាអំណានមុខវិជ្ជាភាសាខ្មែរ

.....................................................................................................................................

.....................................................................................................................................

## ផ្នែកទី៣៖ អំពីភាពខុសគ្នាជាមួយការបង្រៀនអំណានមុខវិជ្ជាភាសាខ្មែរ និងមុខវិជ្ជាផ្សេងនៅកម្រិតបឋមសិក្សា

ការណែនាំ៖ នៅក្នុងបទពិសោធន៍នៃការបង្រៀនអំណាន របស់លោកគ្រូ អ្នកគ្រូកន្លងមក តើការបង្រៀនអំណានលើមុខវិជ្ជាភាសាខ្មែរ នៅកម្រិតបឋមសិក្សា ខុសគ្នាជាមួយការបង្រៀនមុខវិជ្ជាផ្សេងទៀតយ៉ាងដូចម្តេច?សូមអានចំណុចនីមួយៗ ឱ្យបានច្បាស់លាស់ បន្ទាប់មកគូសសញ្ញា (✓) ទៅតាមកម្រិតនៃការយល់ស្របរបស់លោកគ្រូ អ្នកគ្រូ៖

កម្រិតចង្អុលបង្ហាញ៖

១. មិនយល់ស្របទាល់តែសោះ

២. មិនយល់ស្រប

៣. មិនមានយលបល់

៤. យល់ស្រប

៥. យល់ស្របខ្លាំង

| ល.រ | បរិយាយ | កម្រិតចង្អុលបង្ហាញ | | | | |
|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ |
| ១ | មានការរៀបចំ ទិវាអំណានជាតិ | | | | | |
| ២ | គ្រូបង្រៀន មានស្មារតីសហការចូលរួមលើកកម្ពស់ភាសាខ្មែរ | | | | | |
| ៣ | វិធីសាស្ត្របង្រៀនអំណានមាននិយាមច្បាស់លាស់ | | | | | |
| ៤ | មានការបែងចែកម៉ោងអំណាន នៅបណ្ណាល័យ | | | | | |
| ៥ | អំណានភាសាខ្មែរ មានចំនួនម៉ោងសិក្សាច្រើនលើក្របខ័ណ្ឌកម្មវិធីសិក្សា | | | | | |

**មតិយោបល់បន្ថែម៖**

.............................................................................................................................................

.............................................................................................................................................

## តារាងទិន្នន័យព័ត៌មានទូទៅគ្រូបង្រៀន

| ល.រ | បរិយាយ | | សរុបរួម | |
|---|---|---|---|---|
| | | | ចំនួន | ភាគរយ |
| ១ | ភេទ | ប្រុស | ២១ | ៣៣% |
| | | ស្រី | ៤២ | ៦៧% |
| | | **សរុប** | **៦៣** | **១០០%** |
| ២ | អាយុ | ២០ - ៣០ ឆ្នាំ | ២០ | ៣២% |
| | | ៣១ - ៤០ ឆ្នាំ | ២៦ | ៤១% |
| | | ៤១ - ៥០ ឆ្នាំ | ១១ | ១៧% |
| | | លើសពី៥០ ឆ្នាំ | ០៦ | ១០% |
| | | **សរុប** | **៦៣** | **១០០%** |
| ៣ | កម្រិតវប្បធ៌ម | បណ្ឌិត | ០០ | ០.០% |
| | | បរិញ្ញាបត្រជាន់ខ្ពស់ | ០១ | ២% |
| | | បរិញ្ញាបត្រ | ៣៣ | ៥២% |
| | | ចប់ថ្នាក់ទី១២ | ២៩ | ៤៦% |
| | | **សរុប** | **៦៣** | **១០០%** |
| ៤ | បទពិសោធន៍បង្រៀន | ១ ដល់ ១០ ឆ្នាំ | ២៣ | ៣៧% |
| | | ១១ ដល់ ២០ ឆ្នាំ | ២៤ | ៣៨% |
| | | ២១ ដល់ ៣០ ឆ្នាំ | ០៦ | ១០% |
| | | លើសពី៣០ឆ្នាំ | ១០ | ១៥% |
| | | **សរុប** | **៦៣** | **១០០%** |
| ៥ | បង្រៀនថ្នាក់ទី | ថ្នាក់ទី១ | ១៣ | ២១% |
| | | ថ្នាក់ទី២ | ១៣ | ២១% |
| | | ថ្នាក់ទី៣ | ១៣ | ២១% |

| | | | | |
|---|---|---|---|---|
| | | ថ្នាក់ទី៤ | ០៨ | ១២% |
| | | ថ្នាក់ទី៥ | ០៩ | ១៤% |
| | | ថ្នាល់ទី៦ | ០៧ | ១១% |
| | | **សរុប** | **៦៣** | **១០០%** |

# ឧបសម្ព័ន្ធ "ខ"

# គម្រោងសំណួរក្នុងការប្រមូលទិន្នន័យសម្រាប់គណៈគ្រប់គ្រង សាលារៀនបឋមសិក្សាក្នុងខេត្តព្រៃវែង

ខ្ញុំបាទឈ្មោះ ចែម នី ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ នៅវិទ្យាស្ថានជាតិអប់រំ កំពុងសរសេរនិក្ខេបបទស្តីពី "ប្រធានបទ ការវាយតម្លៃទៅលើការបង្រៀនរបស់គ្រូ ស្តីពីអំណាន លើមុខវិជ្ជាភាសាខ្មែរនៅកម្រិតបឋមសិក្សាក្នុងខេត្តព្រៃវែង" ដើម្បីបញ្ចប់ការសិក្សា។

គោលបំណងនៃការប្រមូលទិន្នន័យនេះ គឺដើម្បីសិក្សាស្វែងយល់ពីការអនុវត្តកម្មវិធីសិក្សា និងដំណើរការបង្រៀនមុខវិជ្ជាភាសាខ្មែរ ដោយផ្តោតលើកត្តាប្រឈម នៃការបង្រៀនអំណាន និងភាពខុសប្លែកគ្នា ជាមួយមុខវិជ្ជាផ្សេងទៀត ក្នុងក្របខ័ណ្ឌកម្មវិធីសិក្សាកម្រិតបឋមសិក្សា។ ទិន្នន័យទទួលបានពីលោក-លោកស្រី ជាគណៈគ្រប់គ្រង គឺដើម្បីយកទៅប្រើប្រាស់ក្នុងការសិក្សាស្រាវជ្រាវ ភាពជាក់លាក់នៃការវិភាគឆ្លើយតបទៅប្រធានបទខាងលើ។

ទិន្នន័យដែលប្រមូលបាននេះ គឺប្រើសម្រាប់តែសិក្សាស្រាវជ្រាវនេះតែប៉ុណ្ណោះ។ ក្នុងន័យនេះ សូមលោក-លោកស្រី មេត្តាជួយផ្តល់ព័ត៌មានពិតជាក់ស្តែង ដើម្បីឱ្យខ្ញុំបាទអាចមានទិន្នន័យ និងហេតុផលគ្រប់គ្រាន់តាមបែបវិទ្យាសាស្ត្រ ដើម្បីទាញអំណះអំណាងយកមកសិក្សា បកស្រាយទៅលើ ការសរសេរនិក្ខេបបទក្នុងការសិក្សាស្រាវជ្រាវ។

ខ្ញុំបាទ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការចូលរួម របស់លោកគ្រូ-អ្នកគ្រូ។

## ផ្នែកទី១៖ព័ត៌មានទូទៅ

ការណែនាំ៖ សូមលោកគ្រូ អ្នកគ្រូ គូសសញ្ញា(✓)ក្នុងប្រអប់នីមួយៗខាងក្រោមទៅតាមស្ថានភាពជាក់ស្តែងដូចខាងក្រោម។

១. តួនាទី៖....................................................មុខវិជ្ជាឯកទេស៖................................................

២. បម្រើការងានៅ៖..........................................................ឃុំ/សង្កាត់៖..................................

ក្រុង/ស្រុក/ខណ្ឌ៖..................................................ខេត្ត៖....................................................

៣. ភេទ ☐ ប្រុស ☐ ស្រី

៤. អាយុ ☐ ២៥-៣០ ឆ្នាំ ☐ ៣១-៣៥ឆ្នាំ☐ ៣៦-៤០ឆ្នាំ ☐ លើពី៤០ឆ្នាំ

៥.កម្រិតវប្បធម៌ ☐ ចប់ថ្នាក់ទី១២ ☐ បរិញ្ញាបត្រ ☐បរិញ្ញាបត្រជាន់ខ្ពស់ ☐ ផ្សេងៗ

៦.បទពិសោធន៍បង្រៀន៖☐១ ដល់ ៥ ឆ្នាំ ☐៦ ទៅ១០ ឆ្នាំ☐ ១១ទៅ១៥ ឆ្នាំ ☐លើសពី១៥ឆ្នាំ

**ផ្នែកទី២៖ បញ្ហាប្រឈមនៃការបង្រៀនអំណាន លើមុខវិជ្ជាភាសាខ្មែរនៅកម្រិតបឋមសិក្សា ក្នុងខេត្តព្រៃវែង**

ការណែនាំ៖ សំណួរខាងក្រោម គឺចង់ឆ្លុះបញ្ចាំងពីការងារគ្រប់គ្រង ក្នុងការអនុវត្តកម្មវិធីសិក្សា និងដំណើរការបង្រៀនមុខវិជ្ជាភាសាខ្មែរ ដោយផ្តោតលើកត្តាប្រឈម នៃការបង្រៀនអំណាន និងភាពខុសប្លែកគ្នាជាមួយមុខវិជ្ជាផ្សេងទៀត ក្នុងក្របខ័ណ្ឌកម្មវិធីសិក្សាកម្រិតបឋមសិក្សា។ សូមអានចំណុចនីមួយ ឱ្យបានច្បាស់លាស់ បន្ទាប់មកគូសសញ្ញា (✓) ទៅតាមកម្រិតនៃការពេញចិត្តរបស់លោក-លោកស្រី៖

កម្រិតចង្អុលបង្ហាញ៖

១. មិនយល់ស្របទាល់តែសោះ

២. មិនយល់ស្រប

៣. ពុំមានយោបល់

៤. យល់ស្រប

៥. យល់ស្របខ្លាំង

| ល.រ | បរិយាយ | កម្រិតចង្អុលបង្ហាញ | | | | |
|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ |
| កិច្ចគាំទ្រលើការងារពង្រឹងអំណាន | | | | | | |
| ១ | ផ្តល់សម្ភារល្បែងសិក្សា ដើម្បីពង្រឹងអំណានតាមរយៈ | | | | | |
| ២ | បង្កើតឱ្យមានកម្មវិធីកុមារជួយកុមារ ជំរុញការរៀនសូត្រពីមិត្តភក្តិ | | | | | |
| ៣ | បង្កបរិយាកាសក្នុងសាលារៀន ដើម្បីលើកកម្ពស់អំណាន | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ៤ | បានអនុវត្តតាមគោលនយោបាយ លើកកម្ពស់អំណាន | | | | | |
| ៥ | ការរៀបចំបណ្ណាល័យ អោយក្លាយជាទីមេត្រីសម្រាប់ការអាន | | | | | |
| ៦ | បានផ្ដល់មតិយោបល់ កែលម្អក្នុងការធ្វើថ្នាក់និទស្សន៍មុខវិជ្ជាភាសាខ្មែរ | | | | | |
| ៧ | បានពិនិត្យតាមដាន លើដំណើរការបង្រៀនរបស់គ្រូ ជាប្រចាំ | | | | | |
| ៨ | បានផ្ដល់វគ្គបំប៉នសមត្ថភាព ដល់គ្រូបង្រៀនអំណាន | | | | | |
| ៩ | ប្រជុំជាមួយមាតាបិតាសិស្ស ដើម្បីឱ្យជួយបង្រៀនកូនៗនៅផ្ទះ | | | | | |
| ១០ | សហគមន៍បានចូលរួម ជាមួយសាលារៀន ស្ដីពីអំណានរបស់សិស្ស | | | | | |
| ដំណើរការនៃការបង្រៀនអំណានមុខវិជ្ជាភាសាខ្មែរ | | | | | | |
| ១ | កិច្ចតែងការបង្រៀនអំណានត្រូវបានត្រួតពិនិត្យជាប្រចាំពីគណៈគ្រប់គ្រង | | | | | |
| ២ | គ្រូបង្រៀន បានរៀបចំកិច្ចតែងការបង្រៀនអំណានជាប្រចាំ | | | | | |
| ៣ | គ្រូបង្រៀន មានទស្សនៈវិស័យលើកកម្ពស់គុណភាពបង្រៀនអំណាន | | | | | |
| ៤ | គ្រូបង្រៀន បានស្រាវជ្រាវបន្ថែមលើការបង្រៀនអំណានភាសាខ្មែរ | | | | | |
| ៥ | គ្រូបង្រៀន បានរៀបចំបំណែងចែកកម្មវិធីសិក្សា ច្បាស់លាស់ | | | | | |
| ៦ | គ្រូបង្រៀន មានសមត្ថភាពសបស្រុបតាមកម្រិតវិជ្ជាជីវៈ | | | | | |
| ៧ | គ្រូបង្រៀន មានទំនួលខុសត្រូវក្នុងការគោរពពេលវេលា | | | | | |
| ៨ | ជារួម គ្រូបានបង្រៀនអំណានស្របតាមកម្មវិធីសិក្សា | | | | | |
| ឥរិយាបថសិក្សាអំណានរបស់សិស្ស | | | | | | |
| ១ | លទ្ធផលសិក្សារបស់សិស្ស មានតម្លាភាព និងផ្ទៀងផ្ទាត់ច្បាស់លាស់ | | | | | |
| ២ | ពេលម៉ោងសិក្សាអំណាន សមស្របជាមួយមុខវិជ្ជាភាសាខ្មែរ | | | | | |
| ៣ | សិស្ស បានចូលរួមក្នុង កម្មវិធីកុមារជួយកុមារ | | | | | |
| ៤ | មានការរៀនអានបន្ថែម នៅក្រៅម៉ោងសិក្សា | | | | | |
| ៥ | សិស្ស ស្រឡាញ់ និងចូលចិត្តអំណានក្នុងបណ្ណាល័យ | | | | | |
| ៦ | សិស្សចូលចិត្ត លើការសិក្សាអំណានភាសាខ្មែរ | | | | | |
| អំណានមុខវិជ្ជាភាសាខ្មែរ និងមុខវិជ្ជាផ្សេងទៀត | | | | | | |
| ១ | មានការរៀបចំ ទិវាអំណានជាតិ | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ២ | គ្រូបង្រៀន មានស្មារតីសហការចូលរួមលើកកម្ពស់ភាសាខ្មែរ | | | | | |
| ៣ | វិធីសាស្ត្របង្រៀនអំណានមាននិយាមច្បាស់លាស់ | | | | | |
| ៤ | មានការបែងចែកម៉ោងអំណាន នៅបណ្ណាល័យ | | | | | |
| ៥ | អំណានភាសាខ្មែរ មានចំនួនម៉ោងសិក្សាច្រើនលើក្របខ័ណ្ឌកម្មវិធីសិក្សា | | | | | |

**មតិយោបល់បន្ថែមៈ**

១. តើលោក-លោកស្រី មានជួបប្រទះការលំបាកអ្វីខ្លះ ក្នុងការជំរុញអំណានមុខវិជ្ជាភាសាខ្មែរ?

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

២. ពេលជួបការលំបាកខាងលើ តើលោក-លោកស្រី បានដោះស្រាយយ៉ាងដូចម្តេចខ្លះ?

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

សូមអរគុណ!

## តារាងទិន្នន័យព័ត៌មានទូទៅគណៈគ្រប់គ្រងសាលារៀន

| ល.រ | បរិយាយ | | សរុបរួម | |
|---|---|---|---|---|
| | | | ចំនួន | ភាគរយ |
| ១ | ភេទ | ប្រុស | ១៣ | ៧២% |
| | | ស្រី | ០៥ | ២៨% |
| | | **សរុប** | **១៨** | **១០០%** |
| ២ | អាយុ | ២៥ - ៣០ ឆ្នាំ | ០០ | ០.% |
| | | ៣១ - ៣៥ ឆ្នាំ | ០១ | ៦% |
| | | ៣៦ - ៤០ ឆ្នាំ | ០៦ | ៣៣% |
| | | លើសពី៤០ឆ្នាំ | ១១ | ៦១% |
| | | **សរុប** | **១៨** | **១០០%** |
| ៣ | កម្រិតវប្បធ៌ម | បរិញ្ញាបត្រជាន់ខ្ពស់ | ០១ | ៦% |
| | | បរិញ្ញាបត្រ | ១០ | ៥៥% |
| | | ចប់ថ្នាក់ទី១២ | ០៧ | ៣៩% |
| | | ផ្សេងៗ | ០០ | ០.០% |
| | | **សរុប** | **១៨** | **១០០%** |
| ៤ | បទពិសោធន៍បង្រៀន | ១ ដល់ ៥ ឆ្នាំ | ០១ | ៦% |
| | | ៦ ដល់១០ឆ្នាំ | ០១ | ៦% |
| | | ១១ ដល់ ១៥ ឆ្នាំ | ០១ | ៦% |
| | | លើសពី១៥ឆ្នាំ | ១៥ | ៨២% |
| | | **សរុប** | **១៨** | **១០០%** |

# ឧបសម្ព័ន្ធ "គ"

# លិខិតឧទ្ទេសនាម និងឯកសារពាក់ព័ន្ធ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ: ០៥៣ ខជអ.

**លិខិតបង្គាប់ការ**

យោង៖ ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ និងទី៨ ឆ្នាំសិក្សា២០១៩-២០២០

បុគ្គលិកអប់រំនៃវិទ្យាស្ថានជាតិអប់រំ ដូចមានរាយនាមខាងក្រោមត្រូវបានចាត់តាំងជាគ្រូដឹកនាំបង្គោល និងគ្រូដឹកនាំរងរបស់និស្សិត រ៉េម នី ក្នុងការសរសេរនិក្ខេបបទបញ្ចប់វគ្គបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ នៅវិទ្យាស្ថានជាតិអប់រំ៖

១-គ្រូដឹកនាំបង្គោល

លោកបណ្ឌិត ឈាង សង្វាត

២-គ្រូដឹកនាំរង

លោក ម៉ន មុនិន្ទ

ឯកឧត្តម និងលោកដូចមានរាយនាមខាងលើត្រូវអនុវត្តភារកិច្ចតាមការចាត់តាំង ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃចន្ទ ៨រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមិនា ឆ្នាំ២០២០
ជ.នាយកវិទ្យាស្ថានជាតិអប់រំ
នាយករង

បណ្ឌិត. ឌួង_វីរ៉ា

**កន្លែងទទួល៖**
- ដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការ
- សាមីខ្លួន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារវិទ្យាស្ថានជាតិអប់រំ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**វិទ្យាស្ថានជាតិអប់រំ**
**លេខ** : ១៩៤ **ខជអ**.

**គោរពជូន**
**លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តព្រៃវែង**

**កម្មវត្ថុ៖** សម្រួលដល់ការស្រាវជ្រាវរបស់និស្សិតឈ្មោះ **ចែម នី** នៅតាមសាលាបឋមសិក្សា ក្នុងខេត្តព្រៃវែង។
**យោង៖** ផែនការបណ្តុះបណ្តាលនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនលោកប្រធានជ្រាបថានិស្សិត **ចែម នី** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧ បណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា បានសិក្សាលើប្រធានបទស្តីពី«**ការវាយតម្លៃទៅលើការបង្រៀនរបស់គ្រូ ស្តីពីអំណាននៅកម្រិតបឋមសិក្សា ក្នុងខេត្តព្រៃវែង**» ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សា។ និស្សិត **ចែម នី** មានគម្រោងចុះប្រមូលទិន្នន័យតាមប្រព័ន្ធអនឡាញ (ONLINE) ពីលោកគ្រូ-អ្នកគ្រូ និងគណៈគ្រប់គ្រងសាលារៀន នៅតាមសាលាបឋមសិក្សា ក្នុងខេត្តព្រៃវែង ដែលរួមមាន៖ សាលាបឋមសិក្សាព្រៃវែងក្រុង សាលាបឋមសិក្សារពាងដំរី សាលាបឋមសិក្សាបារាយណ៍កើត សាលាបឋមសិក្សាឃ្លាំង សាលាបឋមសិក្សាឈើកាច់ សាលាបឋមសិក្សាកំរ៉ែង សាលាបឋមសិក្សាឫស្សីទ្វារ សាលាបឋមសិក្សាសាវ៉ាំង និងសាលាបឋមអង្គក្អោត ដែលប្រព្រឹត្តទៅចាប់ពី**ថ្ងៃទី១៤ ខែកក្កដា ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០**។

អាស្រ័យហេតុនេះ សូមលោកប្រធានមេត្តាជួយសម្រួលដោយក្តីអនុគ្រោះ។
សូមលោកប្រធានទទួលនូវការគោរពរាប់អានដ៏ស្មោះពីខ្ញុំ

ថ្ងៃចន្ទ ៨រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២០

**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សឿង សុវណ្ណា

16.7.2020
ប៉ាវ សុធីរ